ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Feb-2015, 14:51
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៤១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena GHEZZI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក សួន វិសាល

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោក ឡេា ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី អេលីហ្សាបេត បេកឃ័រ(2-TCE-97) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោកស្រី អេលីហ្សាបេត បេកឃ័រ** (2-TCE-97)

សួរបន្តដោយលោក នីកូឡាស គូមជែន ផ្តើមពី ........................................ទំព័រ ៣

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ទំព័រ ៣២

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........................................ទំព័រ ៤១

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ទំព័រ ៤២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាទៅសហព្រះរាជអាជ្ញាអន្តរជាតិ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

មានបញ្ហាបកប្រែ ថាមានការបកប្រែផង។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពបកប្រែភាសា!

[០៩:០៣:៣៧]

*(មានបញ្ហាបច្ចេកទេស)*

[០៩:០៣:៥០]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិ--

*(មានបញ្ហាបច្ចេកទេស)*

[០៩:០៧:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាង

ក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

លោកស្រីអ្នកជំនាញ អេលីហ្សាបេត បេកយ័រ មានវត្តមានរួចហើយនៅបន្ទប់សាលសវនាសការនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ឥឡូវនេះអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការឲ្យនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការបង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៨:៤០]

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅអ.វ.ត.ក នេះ ដែលចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈធីងធោង ឈឺខ្នង មិនអាចអង្គុយយូរបានយូរ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យលោក នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញ១ថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម លោកស្រីបេកឃ័រ *(Elizabeth BECKER)*។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំចាប់ផ្តើមសុំសួរលោកស្រីឲ្យមើលឯកសារដែលចៅក្រម ឡាវែន៍ បានមើលគឺឯកសារ E3/333.1។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតៗផ្តល់ឯកសារមួយច្បាប់ទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[០៩:១១:០៦]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកស្រី បេកឃ័រ ម្សិលមិញលោកស្រីបានលើកឡើងថា ឃើញឯកសារ -- ធ្លាប់ឃើញឯកសារនេះជាច្រើនឆ្នាំរួចមកហើយ។ តើស្គាល់ឯកសារនេះដែរឬទេ? កថាខណ្ឌទី២ គឺលោកស្រីលើកឡើងថាអ្នកកាសែតអាមេរិក ជាពិសេសស្ត្រីគឺបានថតរូប ដូចជារូបថតកុមារឃើញគឺធ្វើការនៅខេត្តកំពង់ចាមកន្លែងផលិតថ្នាំ ហើយនិងកុមារគ្មានខោអាវធ្វើដំណើរដើរជាជួរទៅកាន់វាលស្រែ។ តើលោកស្រីនឹកឃើញទេ អំពីឯកសារដែលខ្ញុំលើកឡើងអំម្បាញ់មិញនេះ?

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** ខ្ញុំនឹកឃើញ។

**ស៖** ខ្ញុំផ្តោតលើចំណុចមួយចំនួនផ្សេងទៀត។ ទី១ គឺកថាខណ្ឌទី៤ នៅក្នុងឯកសារនេះ។ ចំណុចទី១ កថាខណ្ឌទី៤ នៅក្នុងឯកសារនេះ។ នៅក្នុងកថាខ័ណ្ឌទី៤នៃឯកសារនេះ គឺចុះប្រាំជួរទៅ គឺ

លើកឡើងថា សាស្ត្រាចារ្យជនជាតិអង់គ្លេសបានសួរ ដើម្បីឲ្យច្បាស់ទៅលើការប្រកបឃ្លាហ្នឹង គឺថាខ្ញុំឲ្យលោក សេង លាង គឺបញ្ជាក់ឈ្មោះ។

**លោក សេង លាង៖**

គឺ ចៅ សេង គឺឈ្មោះ ចៅ សេង, ភោគ ឆាយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សាស្ត្រាចារ្យអង់គ្លេសសួរអំពី ចៅ សេង និង ភោគ ឆាយ។ លោកស្រី បេកយ័រ តើធ្លាប់ស្គាល់ពីរនាក់ហ្នឹងដែរឬទេ?

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** ពួកគាត់គឺជាសិស្ស។

**ស៖** ដើម្បីឲ្យលោកស្រីចងចាំ។ ហើយប្រសិនបើមិនដឹងទេ ឆ្លើយថាមិនដឹង។ ឯកសារមួយនៅក្នុងសំណុំរឿងគឺ E3/1340 គឺចម្លើយរបស់ ចៅ សេង គឺគេដាក់ថា “ចៅ សេង គឺជាសមាជិកសភារបស់ហ្សាំង ហើយជាបេសកជនពិសេសនៅអឺរ៉ុប”។ តើលោកស្រីស្គាល់ទេ បុរសម្នាក់ហ្នឹងដែលមានងារ មុខនាទីដូចខ្ញុំលើកឡើង? គឺឯកសារនេះចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ៧៥។

**ឆ៖** ខ្ញុំអត់ស្គាល់ទេ អត់ដឹងទេ។

[០៩:១៤:០៦]

**ស៖** តើលោកស្រីនៅចាំទេ លោកស្រី បេកយ័រ, លោក ខាដវែល បានសួរអំពីបុគ្គលពីរនាក់នេះ។ តើនៅចាំទេថាគាត់បានសួរអំពីបុគ្គលពីរនាក់នេះ?

**ឆ៖** ខ្ញុំអត់ចាំទេ។

**ស៖** ដើម្បីកំណត់ហេតុ លោក លោកស្រីចៅក្រម ដើម្បីឲ្យយើងទាំងអស់គ្នាចាប់អារម្មណ៍នោះគឺថា មើលឯកសារផ្សេងទៀតនៅក្នុងសំណុំរឿង ឯកសារ D120, ERN ជាភាសាអង់គ្លេស 00242931។ D88 អង់គ្លេស ERN 00195605 ជាចម្លើយ -- ការស្តាប់ចម្លើយរបស់ ឌុច នៅចំពោះមុខចៅក្រមស៊ើបអង្កេតដែលគាត់រៀបរាប់អំពីការចាប់ខ្លួន ចៅ សេង ដោយសារដើរតាមការណែនាំរបស់ សុន សេន និង នួន ជា។ ខ្ញុំក៏ចង់លើកឡើងឯកសារ E31878 គឺចម្លើយសារភាពនៅស-២១ របស់ ភោគ ឆាយ ហៅ ធុច។ ឯកសារ D108/2686 អង់គ្លេស ERN គឺ 00873461 មានចំណងជើងថា “ឈ្មោះអ្នកទោសដែលត្រូវបានកម្ទេចនៅថ្ងៃទី៦ កក្កដា ឆ្នាំ១៩៧៧”។ ហើយ ភោគ ឆាយ ហៅ ធុច នៅក្នុង

លេខរៀងទី១២៣ ក្នុងបញ្ជីនេះ។ បញ្ជីនេះចុះថ្ងៃទី១៤ មីនា ឆ្នាំ១៩៧៧។ តើលោកស្រីនៅចាំទេថា នៅក្នុងពេលមកទស្សនកិច្ចនោះ តើបុគ្គលដែលលោកស្រីបានសួរនាំអំពីនោះ ត្រូវបានគេប្រាប់ថា បានចាប់ខ្លួន ហើយកម្ទេចសម្លាប់ចោលដែរឬទេ?

[០៩:១៦:២២]

**ឆ៖** ខ្ញុំមិនដែលត្រូវបានគេ -- គេមិនដែលប្រាប់ថា គេបានចាប់ខ្លួនអ្នកទាំងអស់នោះមួយចំនួន ហើយបានសម្លាប់ចោល ឬក៏ស្លាប់នោះទេ គេមិនដែលប្រាប់ទេ។

**ស៖** កថាខណ្ឌ៦ នៅក្នុងឯកសារហ្នឹង ប្រយោគទី២ ឬក៏ផ្នែកតូចទី២ នៃកថាខណ្ឌ៦ គឺលើកឡើងថា "អ្នកកាសែតអាមេរិកពីរនាក់នេះ ច្បាស់លាស់បម្រើរដ្ឋាភិបាលអាមេរិក និងសេ.អ៊ី.អា ដូចយើងបានកំណត់ច្បាស់លាស់"។ លោកស្រី បេកឃ័រ តើនៅក្នុងពេលទស្សនកិច្ចនោះ តើមាននរណាម្នាក់ក្នុងចំណោមអ្នកទាំងពីរហ្នឹងជា សេ.អ៊ី.អា ដែរឬទេ? ឬក៏ធ្វើការងារបម្រើឲ្យសេ.អ៊ី.អា?

**ឆ៖** អត់មានអ្នកណាធ្វើការបម្រើការងារសេ.អ៊ី.អា ហ្នឹងទេ។

**ស៖** ប្រសិនបើអត់ទេ លោកស្រីពីមុនគឺធ្លាប់បានសរសេរអត្ថបទរិះគន់អំពីតួនាទីរបស់អាមេរិកនៅក្នុងសង្គ្រាមក្នុងប្រទេសកម្ពុជា។ តើមានទេ?

**ឆ៖** ខ្ញុំមានសរសេរអត្ថបទរិះគន់អ៊ីចឹងមែន។

**ស៖** លោក ឌុដម៉ាន ដែលជាអ្នកកាសែតអាមេរិកមួយរូបទៀតនៅក្នុងដំណើរទស្សនកិច្ចនោះ ផងដែរក៏បានសរសេរអត្ថបទរិះគន់អំពីតួនាទីអាមេរិកនៅក្នុងសង្គ្រាមនៅក្នុងទ្វីបអាស៊ី វៀតណាម ជាពិសេសកម្ពុជាផងដែរ។ តើគាត់ធ្លាប់បានសរសេរអ៊ីចឹងដែរឬទេ?

[០៩:១៨:១៣]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរទាំងពីរនេះ ហើយបើសិនជាតំណាង លោកសហព្រះរាជអាជ្ញាចង់សួរចំណុចនេះ គួរតែបង្ហាញឯកសារជាក់លាក់ ថាតើអត្ថបទណាមួយដែលអ្នកទាំងពីរនោះបានសរសេរផង។ សូមអរគុណ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំ -- លោកប្រធាន ខ្ញុំទទួលយកតាមសំណើសុំរបស់មេធាវី។ ខ្ញុំនឹងបង្ហាញ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកស្រី បេកយ័រ, លោក ឌុដម៉ាន បានសរសេរសៀវភៅតូចមួយ ថ្ងៃ -- "៤០ថ្ងៃជាមួយនឹងខ្មាំង ឬក៏សត្រូវ"។ សៀវភៅនេះបោះពុម្ពក្នុងឆ្នាំ១៩៧១ ដែលពិភាក្សាអំពីការចាប់ខ្លួនដែលគេចាប់ខ្លួនគាត់៤០ថ្ងៃ។ គឺអ្នកប្រឆាំងនឹងសម័យ លន់ នល់ បានចាប់ខ្លួនគាត់ឃុំ៤០ថ្ងៃ ហើយគឺកងកម្លាំងវៀតណាមជាមួយនឹងខ្មែរក្រហមនោះជាប់ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ឃុំខ្លួនគាត់នោះ។ តើត្រឹមត្រូវដែរឬទេលោក ឌុដម៉ាន បានសរសេរសៀវភៅនេះ? សំណួរ តើមានផ្នែកណាមួយដែលលោកស្រីមិនអាចពន្យល់បាន គឺសូមជម្រាបខ្ញុំ។

[០៩:១៩:៤៤]

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** គឺ បាទ គាត់បានសរសេរមែន។

**ស៖** តើលោកស្រីពិពណ៌នាយ៉ាងម៉េច តើក្នុងសៀវភៅនោះគេនិយាយថាអាមេរិកនោះគាត់ប្រព្រឹត្តចំពោះយ៉ាងម៉េចតួនាទីរបស់គាត់នៅក្នុងសង្គ្រាមនៅអាស៊ីអាគ្នេយ៍ ជាពិសេសនៅក្នុងប្រទេសកម្ពុជា?

**ឆ៖** ខ្ញុំ លោកលើកឡើងថាលោក ឌុដម៉ាន បានរិះគន់ការពាក់ព័ន្ធរបស់អាមេរិកនៅក្នុងប្រទេសកម្ពុជាជាពិសេសនៅក្នុងសង្គ្រាមនេះ។

**ស៖** ដើម្បីឲ្យៗខ្ញុំយល់បន្ថែមទៀតចំពោះលោក ឌុដម៉ាន និងប្រវត្តិសាវតាររបស់លោកស្រី ខ្ញុំនឹងលើកឡើងអំពីការជ្រើសរើសរបស់លោកស្រីមកធ្វើទស្សនកិច្ចនៅក្នុងប្រទេសនេះ។ កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ដែលលោកស្រីធ្វើការងារជាអ្នកកាសែតនៅទីនោះ ថាតើកាសែតនៅអាមេរិកនោះ គេរៀបរាប់ថារចនាសម្ព័ន្ធរបស់កាសែតហ្នឹងគឺយ៉ាងម៉េចបើធៀបជាមួយនឹងកាសែតផ្សេង?

**ឆ៖** កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍នេះ គឺជាកាសែតមួយដែលសំខាន់ល្បី គឺកាសែតឲ្យខាង វ័ធធីហ្គេត គឺ វ័ធធីហ្គេត។ ការស៊ើបអង្កេតរបស់ វ័ធធីហ្គេត ហ្នឹងនាំឲ្យមានការចុះចេញពីតំណែងរបស់និចសុន ហើយនៅក្រោមការបោះពុម្ពផ្សាយ ប្រ៊េតលី គឺថាគាត់ជាអ្នកថ្នាក់លើនៅក្នុងកាសែតនេះផងដែរ។

**ស៖** លោក ឌុងម៉ាន នៅពេលនោះគឺថាធ្វើការនៅកាសែតមួយទៀតផងដែរ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** គឺគាត់ធ្វើនៅកាសែតមួយទៀត តែក្រុមជាមួយនឹងគ្នា។

**ស៖** តើលោកស្រីរៀបរាប់យ៉ាងដូចម្តេច កាសែតនេះ ថារៀបរាប់យ៉ាងម៉េចដែរ ចំពោះកាសែតមួយនេះ នៅក្នុងឋានៈ ឬក៏ចំណាត់ថ្នាក់របស់គេនៅក្នុងសម័យនោះ នៅអាមេរិក?

**ឆ៖** កាសែតនេះ វាជាកាសែតមួយដែលក្នុងតំបន់ល្បីល្បី រីឆាដ ឌុងម៉ាន ដោយសារគាត់ធ្វើការងារនៅទីនោះយូរ នៅវ៉ាស៊ីនតោន គឺគាត់សរសេរអំពីគោលនយោបាយអាមេរិក គោលការណ៍បរទេសរបស់អាមេរិក។ ហើយគាត់មាន -- កាសែតនេះ គឺថាមានឈ្មោះល្បីជាងកាសែតផ្សេង។

[០៩:២២:៣៤]

**ស៖** សូមអរគុណ។ ម៉ាល់ខូម ខាដវែល នៅក្នុងសៀវភៅរបស់លោកស្រី ទំព័រ៤២០ អង់គ្លេស 0023--

**អ្នកបកប្រែ៖**

បាទ អនុញ្ញាតសូមឱ្យ លោកប្រធានសូមឱ្យសហព្រះរាជអាជ្ញាជួយបញ្ជាក់លេខ ERN ឱ្យបានយឺតៗ។

**លោក នីកូឡាស គូមជែន៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ដូចមានបញ្ហា បញ្ហាដកប្រែភាសា។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពបកប្រែភាសា។

[០៩:២៣:២៨]

*(មានបញ្ហាបច្ចេកទេស)*

[០៩:២៤:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ។ ហើយសូមសំណួរចុងក្រោយអំមិញសាឡើងវិញ ព្រោះអត់មានការបកប្រែភាសាទេ ហើយសូម ទី២ សូមឱ្យលោកបញ្ជាក់ កាលមានយោង

ទៅលើលេខឯកសារ សូមបញ្ជាក់ឲ្យបានយឺតៗ។ បើអាចធ្វើបានគឺ ពីរដងជាការល្អប្រសើរ ដើម្បីឲ្យការបកប្រែភាសាហ្នឹងបានច្បាស់លាស់លើលេខឯកសារ និងលេខ ERN ផង។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកស្រី បេកឃ័រ ខ្ញុំនឹងអានប្រយោគខ្លីមួយដែលលោកស្រីបានសរសេរនៅក្នុងសៀវភៅចំណងជើងថា “នៅពេលសង្គ្រាមរលត់ទៅ” នោះ គឺឯកសារ E3/20, ទំព័រ៤២០, ERN ជាភាសាអង់គ្លេស 00238133, បារាំងគឺទំព័រ៤០៩, ERN ជាបារាំងគឺ 00638669, ខ្មែរទំព័រ៥៥៦, ERN ជាភាសាខ្មែរគឺ 00232554។ លោកស្រីបានសរសេរថា “ខាងវែល បានចាត់ខ្លួនគាត់ថាជាមិត្តរបស់ខាងបដិវត្តន៍ វៀតណាម ថៃ ហើយនិងកម្ពុជា។ ហើយលោក ខាងវែល គាត់ស្រងាកចិត្តអំពីសង្គ្រាមរវាងកម្ពុជា និងវៀតណាម”។ តើលោកស្រីបានសរសេរអំពីបុរសម្នាក់នេះដែលត្រូវបានគេសម្លាប់នៅយប់១ថ្ងៃមុនពេលដែលគាត់ចាកចេញដែរឬទេ?

[០៩:២៦:៣៩]

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** បាទ ខ្ញុំពិតជាបានសរសេរអំពីគាត់មែន។

**ស៖** នៅក្នុងពេលលោកស្រីធ្វើទស្សនកិច្ចចុងឆ្នាំ១៩៧៨ តើមានប្រទេសមួយដែលជាសម្ព័ន្ធមិត្តហើយធ្វើការរិះគន់អំពីយោធាដែលបានចូលរួមពាក់ព័ន្ធនៅក្នុងជម្លោះជាមួយនឹងវៀតណាម និងកម្ពុជាដែរឬទេ?

**ឆ៖** ជាការពិតដូច្នោះមែន។

**ស៖** តើចិននៅក្នុងទីក្រុងភ្នំពេញក្នុងពេលដែលលោកស្រីមកនេះ តើមានដែរឬទេ?

**ឆ៖** មាន ខាងជនជាតិចិន។ យើងមកតាមប្រទេសចិន ដូច្នេះយើងមកតាមយន្តហោះចិន។ ហើយនៅលើយន្តហោះនោះ គឺមានជនជាតិចិនជិះជាមួយយើង ហើយយើងឃើញច្រើនដែរ។

**ស៖** តាមលោកស្រីយល់អំពីស្ថានភាពនេះ តើមានអ្វីដែលវាធ្វើឲ្យមានការប៉ះទង្គិចរវាងទំនាក់ទំនងរវាងវៀតណាមនិងកម្ពុជា? ដូចជាបញ្ហានៃការសម្លាប់មន្ត្រីចិននៅក្នុងប្រទេសកម្ពុជាដែលបញ្ហានេះនាំឲ្យមានការប៉ះពាល់ទៅដល់បញ្ហាយោធាដែរឬទេ?

**ឆ៖** វាជាសម្មតិកម្មតែប៉ុណ្ណោះ។ ខ្ញុំមិនអាចឆ្លើយតបបាននោះទេ។

**ស៖** ខ្ញុំអរគុណ ហើយខ្ញុំក៏មិនចង់ឲ្យមានការប៉ានស្មានដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[០៩:២៨:៤០]

**លោក គង់ សំអុន៖**

ខ្ញុំថានឹងជំទាស់ដែរអំមិញ។ អ្នកជំនាញគាត់បានឆ្លើយបញ្ជាក់អំពីចម្លើយរបស់គាត់ទៅនឹងសហព្រះរាជអាជ្ញាហើយដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកចៅក្រម។ ដូច្នេះ សាក្សីនេះគាត់ជាអ្នកជំនាញ។ ដូច្នេះខ្ញុំមានសិទ្ធិក្នុងការសួរគាត់ឲ្យគាត់ធ្វើការសន្និដ្ឋានបាន ហើយប្រសិនបើលោកស្រីគាត់ថាគាត់មិនអាចសន្និដ្ឋានបានទេ គឺគាត់មានសិទ្ធិថាគាត់មិនអាចធ្វើទៅបាន។ បាទ ខ្ញុំសុំបន្តទៅមុខទៀត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នៅពេលនេះ ខ្ញុំចង់ឲ្យលោកស្រីមើលមានកំណត់សម្គាល់ កំណត់ហេតុមួយគឺឯកសារ E31171 ឯកសារកំណត់ហេតុដែលលោកស្រីបានធ្វើនៅពេលទស្សនកិច្ច។

**លោក នីកូឡាស គូមជែន៖**

លោកប្រធានខ្ញុំសុំអនុញ្ញាតឲ្យសាក្សី ឲ្យគាត់មានឱកាសពិនិត្យមើលកំណត់ហេតុនេះ។ សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[០៩:៣០:១០]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ឯកសារ E31171 ឯកសារនេះខ្ញុំចង់សួរអំពីចំណុចមួយដែលវាមាន ERN អង់គ្លេស គឺ

នៅខាងឆ្វេងទំព័រ 0087871, ERN ជាភាសាខ្មែរ 00726621, បារាំងមានលេខ ERN 00764046 គឺលេខ ERN ហ្នឹងនៅខាងឆ្វេង ផ្នែកខាងឆ្វេងនៅចុងទំព័រខាងលើ។ ដើម្បីជាបរិបទ សូមឱ្យលោកស្រីមើលទំព័រខាងមុខមួយទំព័រ តើវាត្រឹមត្រូវដែរឬទេ គឺឯកសារនេះត្រង់ ERN 871 លោកស្រីបានពណ៌នាអំពីការទៅទស្សនកិច្ចទំនប់ ៦មករា។

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** ខ្ញុំបានទៅទស្សនកិច្ចទំនប់ ៦មករា មែន។

**ស៖** តើត្រឹមត្រូវដែរឬទេ? លោកស្រីបានសរសេរឡើងវិញព័ត៌មានដែលគេប្រាប់លោកស្រីនៅក្នុងកថាខណ្ឌទីមួយ នៅក្នុងហ្នឹងគឺថាលោកស្រីសរសេររៀបរាប់ឡើងវិញ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

[០៩:៣២:០៥]

**ស៖** តើនរណាគេជាអ្នកប្រាប់ព័ត៌មាននេះដល់លោកស្រី តើលោកស្រីនៅចាំទេ?

**ឆ៖** នៅទំព័របន្ទាប់ពីទំព័រនុំង ខ្ញុំបានសរសេរថា៖ "កម្មាភិបាលនិយាយជាមួយនឹង*កាម៉ារ៉ាត*មាឃ ដែលគាត់មានអាយុ២៦ឆ្នាំ។ គឺនៅក្នុងទំព័រ៨៧១ ហ្នឹងលោកប្រាកដជាបានឃើញហើយ។

**ស៖** នៅក្នុងទំព័រ៨៧១ គឺលោកដាក់ថា ទំព័រ១៧ ដែលលោកស្រីសរសេរកត់សម្គាល់នៅពីលើនោះ តែវាដាច់ទៅ ជួរទី៣គឺបានសរសេរថា៖ "មនុស្ស២០០០នាក់ គឺធ្វើទ្វារបិទទឹក។ ២០.០០០នាក់ទៅកសាងទំនប់ និងលើកប្រឡាយ និងជីកប្រឡាយ"។ តើលោកស្រីពិតជាបានសរសេរចំណុចហ្នឹង ហើយវាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**ស៖** នៅពេលដែលលោកស្រីទៅពិនិត្យការដ្ឋានហ្នឹង តើគេកំពុងដំណើរការឬ?

**ឆ៖** ចាស គេកំពុងតែដំណើរការ។

**ស៖** ចុះទៅពីរទំព័រខាងក្រោម ពីរកថាខណ្ឌខាងក្រោម គឺមានការសរសេរដោយអក្សរដៃ គឺសរសេរថា៖ "នៅពេលដែលខ្ញុំទៅថតរូប រូបថតរបស់កងទ័ពនៅការដ្ឋានទំនប់ទឹកហ្នឹង ពួកគេរត់គេចកម្មាភិបាលនោះបដិសេធថាពួកគេមិនមែនជាកងទ័ពទេ។ ហើយគេមិនទាំងប្រាប់ថាតើមានចំនួនប៉ុន្មានហើយនិងហេតុអ្វីបានជាគេត្រូវការមកកសាងទំនប់នេះទេ"។ តើខ្ញុំបកស្រាយការសរសេររបស់លោកស្រីនេះត្រឹមត្រូវឬទេ?

[០៩:៣៤:១៦]

**ឆ៖** ចាស ត្រឹមត្រូវ។

**ឆ៖** ដូច្នេះនៅពេលដែលលោកស្រីនៅការដ្ឋានហ្នឹង ថាតើមានកម្មករ មានពលកម្មជាងរាប់ពាន់នាក់ដែលមានជាសុទ្ធតែជាទាហាន។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** នៅពេលដែលលោកស្រីទៅទស្សនកិច្ចនៅទីនោះ ថាតើប្រជាជននៅក្នុងសហករណ៍ គេរស់នៅដោយសេរី ដោយមានសេរីភាពដែរឬទេ?

**ឆ៖** អត់ទេ។ គេអត់ប្រាប់យើងថាប្រជាជនទាំងអស់នោះរស់នៅដោយមានសេរីភាពនោះទេ។

**ស៖** តើគេមានប្រាប់អ្វី ឧទាហរណ៍ដូចជាប្រព័ន្ធនៃការគ្រប់គ្រង ការផ្លាស់ទីលំនៅអីជាដើម តើគេមានប្រាប់លោកស្រីទេ?

**ឆ៖** ព្រោះថា ខ្ញុំចេញទៅក្រៅដោយពួកគេអនុញ្ញាតឲ្យខ្ញុំចេញទៅក្រៅនោះ ព្រោះថា គេប្រាប់ខ្ញុំអំពីការព្រួយបារម្ភអំពីសុវត្ថិភាព ហើយដែលថា ខ្ញុំត្រូវតែមានការអនុញ្ញាត ទើបខ្ញុំអាចចាកចេញទៅក្រៅបាន។

**ស៖** សូមអភ័យទោស សូមចាំមួយភ្លែតសិន។ សូមអរគុណ ខ្ញុំសូមបន្តទៅមុខទៀត។ កាលពីម្សិលមិញមានការបង្ហាញថា លោកស្រីស្នើសុំទៅជួបសម្តេច សីហនុ ហើយសំណើរបស់លោកស្រីត្រូវបានគេបដិសេធ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតជាអ៊ីចឹងមែន។

[០៩:៣៧:០៣]

**ស៖** តើគេមានបានបញ្ជាក់ប្រាប់លោកស្រីថា តើសម្តេច សីហនុ គង់នៅទីកន្លែងណាទេ?

**ឆ៖** គេគ្រាន់តែប្រាប់ថាគាត់រវល់។ គាត់មានការប៉ុណ្ណោះ។

**ស៖** គេ -- ហើយមានការបញ្ជាក់ថា លោកស្រីក៏បានស្នើសុំជួប ហ៊ូ នឹម ហើយនិង ហ៊ូ យន់ផងដែរ។ តើលោកស្រីទទួលបានចម្លើយយ៉ាងម៉េចដែរ នៅពេលដែលលោកស្រីស្នើសុំជួបលោកទាំងពីរនាក់នេះ គឺ ហ៊ូ នឹម, ហ៊ូ យន់ រួមជាមួយ ខៀវ សំផន នោះ?

**ឆ៖** គេមិនឆ្លើយតបអ្វីទាល់តែសោះជាមួយសំណើរបស់ខ្ញុំ។

**ស៖** ឥឡូវនេះ ខ្ញុំចង់បកបន្តិចទៅលើការសម្ភាសដែលលោកស្រីធ្វើជាមួយ អៀង សារី ដែល

និយាយអំពីសហករណ៍ ដែលខ្ញុំគួរតែសួរលោកស្រីតាំងពីម្សិលមិញ ប៉ុន្តែខ្ញុំមិនបានសួរ គឺការសម្ភាសរបស់លោកស្រីជាមួយ អៀង សារី។ ប្រហែលជាលោកស្រីមានឯកសារនេះហើយ។ ប្រសិនបើយើងមើលទៅទំព័រចុងក្រោយ គឺឯកសារ -- នៅទំព័រចុងក្រោយ ឯកសារ E3/94 គឺមាន ERN ភាសាអង់គ្លេស 00342504, ភាសាខ្មែរមានលេខ ERN 00578899, ហើយភាសាបារាំងគឺមានលេខ 00602002។ គេ -- លោកស្រីបានសួរសំណួរថា៖ "តើមានប្រព័ន្ធយុត្តិធម៌ដែរឬទេ?" ហើយចម្លើយរបស់ អៀង សារី គឺតាមកំណត់ត្រានោះ បានបញ្ជាក់ថា៖ "ក្នុងឆ្នាំ៧៥ នៅពេលដែលជម្លៀសចេញពីទីក្រុង និងទីប្រជុំជននានា យើងមិនបានបំបែកប្រជាជនតាមរយៈបណ្ដាញ ឬក៏មូលដ្ឋាននោះទេ ប៉ុន្តែមានការច្របូកច្របល់។ ហើយនៅក្នុងឆ្នាំ៧៦ យើងចាប់ផ្ដើមបែងចែកប្រជាជន គឺមានការច្របូកច្របល់ខ្លាំងមែនទែននៅក្នុងឆ្នាំ៧៦ សូម្បីតែប្រជាជនដែលជាប្រជាជនមូលដ្ឋាន ក៏ត្រូវបានគេចាត់ទុកថាជាភ្នាក់ងារដែរ។ អ្នកដែលបែងចែកប្រជាជនដាក់ជាក្រុមផ្សេងៗគ្នានោះគឺ សោ ភឹម និង វស់ ញឹម។ វាមិនមែនជាបញ្ហាចេញពីថ្នាក់លើទៅថ្នាក់ក្រោមនោះទេ។ ប៉ុល ពត មិនបានបញ្ជាឲ្យមានការបែងចែកប្រជាជនឲ្យដាក់ជាក្រុមនោះឡើយ។ ក្រោយមកទៀត នៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំមួយ នៅក្នុងឆ្នាំ១៩៧៦ ការបែងចែកនេះត្រូវបានទទួលយកដោយថ្នាក់ដឹកនាំ។ ការសម្រេចនេះត្រូវបានធ្វើឡើងជាសមូហភាព។ មានពីរ ឬបីនាក់ដែលជំទាស់ទៅលើរឿងនេះ។ ប៉ុន្តែយើងមិនចង់ឲ្យមានការញែកយោបល់គ្នានោះទេ។ ក្នុងនាមជាប្រធាន ប៉ុល ពត សរុបៗរឿងនេះជាសមូហភាពតែម្តង។ នៅពេលនោះ យើងបែងចែកទៅជា ១) ប្រជាជនមូលដ្ឋាន ២) ប្រជាជនក្រីក្រមកពីទីក្រុង និង៣) ប្រជាជនគាំទ្រ លន់ នល់"។ តើលោកស្រីចាំដែរ ឬទេថា អៀង សារី បានផ្ដល់ចម្លើយនេះជូនលោកស្រី?

**ឆ៖** គាត់ពិតជាផ្ដល់មែន។

[០៩:៤១:២០]

**ស៖** នៅពេលលោកស្រីសម្ភាសជាមួយជនភាគខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺតាំងតែពីពេលដួលរំលំនៃរបបកម្ពុជាប្រជាធិបតេយ្យមក តើលោកស្រីបានដឹងអំពីការបែងចែកបុគ្គល ឬក៏ប្រជាជនទៅប្រភេទផ្សេងៗគ្នានៅក្នុងរបបនោះដែរឬទេ?

**ឆ៖** ចាស។

**ស៖** តើមានអ្នកណាផ្សេង នៅពេលដែលលោកស្រីបានធ្វើដំណើរហ្នឹង បានពិភាក្សាជាមួយលោកស្រីអំពីការបែងចែកនេះដែរឬទេ?

**ឆ៖** គឺយើងបានពិភាក្សាជាទូទៅ មិនមែនជាការពិភាក្សាបែបមនោគមន៍វិជ្ជានោះទេ គឺយើងគ្រាន់តែនិយាយអំពីប្រជាជនថ្មី ប្រជាជនចាស់ មូលដ្ឋាន ប្រជាជនមកពីទីក្រុងទៅតាមជនបទជាដើម។

**ស៖** តើមានភាពខុសគ្នាយ៉ាងដូចម្តេចនៅពេលដែលគេបែងចែកទៅជាប្រភេទផ្សេងៗគ្នានេះ? ថាតើមានគោលដៅអ្វីនៅក្នុងការបែងចែកប្រជាជនទេ? តើប្រជាជនដែលមានប្រភេទខុសៗគ្នាហ្នឹងទទួលបានប្រព្រឹត្តដូចគ្នា ឬក៏ខុសគ្នា?

**ឆ៖** វាគឺជាប្រព័ន្ធនៃអភ័យឯកសិទ្ធិ ដែលថាប្រជាជនថ្មីត្រូវបានគេប្រព្រឹត្តដោយមិនសមរម្យដូចជាចំណីអាហារជាដើម ដូចជាពេលវេលាការងារ កម្លាំងពលកម្ម ក៏ដូចជាឋានានុក្រមជាដើម។

[០៩:៤៣:០២]

**ស៖** ទៅតាមប្រព័ន្ធម៉ាក្សបែបបុរាណ គឺថាប្រជាជនមកពីទីក្រុងគឺពួកអនុធន។ ហេតុអ្វីបានជាប្រជាជនក្រីក្រ គេបែងចែកនៅក្នុងប្រភេទនេះ គឺនៅពីក្រោមប្រជាជនមូលដ្ឋាន។ ហេតុអ្វីបានជាគេបែងចែក ថាចាំបាច់បែងចែកប្រជាជនមកពីជនបទ ឬមកពីទីក្រុងបែបនេះ?

**ឆ៖** នៅក្នុងបរិបទនេះ នៅក្នុងពេលចុងក្រោយនៃសង្គ្រាម នៅពេលដែលអាមេរិកទម្លាក់គ្រាប់បែប ក៏ដូចជាសង្គ្រាមរវាងខ្មែរក្រហម ហើយនិងខ្មែរសាធារណរដ្ឋជាដើម។ ប្រជាជននៅទីក្រុងភ្នំពេញមានការកើនឡើងដល់ទៅពីរបីដង គឺពួកគេរត់ចូលទៅក្នុងទីក្រុង។ ដូច្នេះ អ្នកនៅក្នុងទីក្រុងមិនមែនប្រាដកថាជាអ្នករស់នៅទីក្រុងភ្នំពេញនោះទេ។ ដូច្នេះ នៅពេលដែលយើងនិយាយថា អ្នកដែលចាកចេញពីទីក្រុងទៅជនបទ គឺភាគច្រើនគឺជាអ្នកដែលត្រូវបានគេ ដែលរត់គេចពីតំបន់ជនបទជាបណ្តោះអាសន្នរត់ចូលមកទីក្រុងតែប៉ុណ្ណោះ។ អានេះគឺជាអ្វីដែលគេចង់និយាយ។

[០៩:៤៤:២៧]

**ស៖** លោកស្រី បេកយ័រ លោកស្រីស្នាក់នៅក្នុងប្រទេសកម្ពុជាពីឆ្នាំ៧២ ដល់៧៤។ លោកស្រីបានឃើញការរត់គេចរបស់ប្រជាជនពីទីជនបទមកទីក្រុងភ្នំពេញ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតជាអ៊ីចឹងមែន។

**ស៖** អ៊ីចឹង ខ្ញុំគិតថា ប្រហែលជាគេមកដោយសារហេតុផលផ្សេងៗគ្នា។ អ៊ីចឹង លោកស្រីអាចពន្យល់បានទេថា តើហេតុផលអ្វីដែលប្រជាជនរត់គេចពីភូមិស្រុកមកទីក្រុងភ្នំពេញនោះ?

**ឆ៖** គឺថាការរត់គេច សំខាន់ទី១គឺដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិក។ យើងពិបាកក្នុងការបញ្ជាក់ឲ្យច្បាស់ ព្រោះថាការទម្លាប់នោះ វាមានលក្ខណៈធំ ហើយប្រជាជន ហើយភូមិត្រូវបាន

បំផ្លាញក៏មានច្រើន។ ដូច្នេះ ផ្នែកទី១ គឺរហូតដល់ថ្ងៃ១៥ ខែ៨ ឆ្នាំ៧៣ គឺនៅដែលគេបញ្ចប់ការទម្លាក់គ្រាប់បែកហ្នឹងគឺមានការរត់គេច។ ហើយការសម្ភាសរបស់ខ្ញុំជាមួយនឹងជនភៀសសឹកមួយចំនួន ពួកគេនិយាយអំពីការទម្លាក់គ្រាប់បែក។ ព្រោះថាពួកគេមិនមានកន្លែងណារត់ទៅក្រៅពីទីក្រុង ហើយគេមិនដឹងថា រត់ទៅទីណាដែលមានសុវត្ថិភាពជាងទីនេះទៀតទេ។

**ស៖** លោកស្រីបាននិយាយអំពីការទម្លាក់គ្រាប់បែក ហើយនិងការបញ្ចប់ ប៉ុន្តែប្រជាជននៅតែបន្តរត់គេចមកទីក្រុង។ គឺខ្ញុំចង់និយាយអំពីការទម្លាក់គ្រាប់បែករបស់អាមេរិក។

[០៩:៤៦:០៨]

**ឆ៖** គឺថាមានការទម្លាក់គ្រាប់បែកច្រើន មិនមែនត្រឹមតែអាមេរិកទេ សូម្បីតែខ្មែរក្រហមហ្នឹងរត់ ទាំងទាហានសាធារណរដ្ឋខ្មែរក៏ទម្លាក់ដែរ។ ដូច្នេះហើយគឺថា១ ប្រទេសត្រូវបានបែកចែកដោយកងកម្លាំងផ្សេងៗគ្នា ហើយប្រជាជនកម្ពុជារត់ចូលទៅទីក្រុងដោយសារតែមានការផ្គត់ផ្គង់ ដើម្បី -- ហើយជនភៀសសឹករត់គេចពីតំបន់ខ្មែរក្រហម គឺមានការបែងចែកច្បាស់លាស់ នៅពេលនោះគឺមានការបែងចែកជាតំបន់ខ្មែរក្រហមជាដើម។ អ្នកខ្លះរត់គេចពីតំបន់ខ្មែរក្រហម អ្នកខ្លះរត់ដើម្បីស្វែងរកសាច់ញាតិ ហើយភាគច្រើនគឺរត់គេចពីការវាយប្រយុទ្ធ។ ដូច្នេះហើយពួកគេមិនយល់ដឹងថា តើសង្គ្រាមហ្នឹងគឺកើតឡើងដោយសារអ្វី មូលហេតុនយោបាយអ្វី ដូច្នេះគេគ្រាន់តែរត់គេចពីសង្គ្រាម។

[០៩:៤៧:២៣]

**ស៖** លោកស្រីបាននិយាយថា ប្រជាជនមួយចំនួនរត់គេចពីតំបន់ខ្មែរក្រហម។ ហេតុអ្វីក៏ពួកគេរត់គេចចេញពីតំបន់ខ្មែរក្រហម តំបន់កាន់កាប់ដោយខ្មែរក្រហមនោះ?

**ឆ៖** សក្ខីកម្មដែលពេញលេញ និងគួរឲ្យទុកចិត្តបំផុតគឺសៀវភៅរបស់ មែននីង គឺការ -- សៀវភៅរបស់ អ៊ិត សារិន១ ដែលផ្តល់នៅក្នុងឆ្នាំ៧២ ឬក៏៧៣ ដែលថា ប្រជាជន -- គឺថាគាត់នៅពេលហ្នឹង អ៊ិត សារិន ជានាយកសាលា ជាអធិការកិច្ចនៅសាលារៀន។ វាហាក់ដូចជាទិនានុលេខន៍ដែលនិយាយអំពីតំបន់ខ្មែរក្រហម នូវការអត់អាហារ ការងារធ្ងន់ធ្ងរ ហើយប្រជាកសិករត្រូវបានគេធ្វើបាប។ ហើយនៅពេលនោះយើងអាចយល់អំពីទស្សនៈនៃ១ គេហៅថា "ភ្នែកម្នាស់"១ ជាដើម អាហ្នឹងគឺជាបញ្ហាដែលយើងយល់។ ដូច្នេះហើយអានេះគឺវាមានបញ្ហាច្រើននៅពេលនោះ ដែលគេមិនចង់ចូលរួមជាមួយនឹងអ្នកដែលមានលក្ខណៈថា "ផ្តាច់ការ" នោះឯង។ នេះគឺជាឯកសារដ៏សំខាន់ដែលអាចឲ្យសាធារណជនពិនិត្យមើលបាន។ គឺថាប្រជាជនគាត់មិនយល់អំពីបញ្ហានយោបាយ បញ្ហាមនោគមន៍វិជ្ជាអ្វីទេ គាត់

គ្រាន់តែរត់គេចពីសង្គ្រាមពីការវាយប្រយុទ្ធតែប៉ុណ្ណោះ។

[០៩:៤៩:៣០]

**ស៖** មុនពេលដែលដួលរលំភ្នំពេញ នៅពេលដែលខ្មែរក្រហម -- មុនពេលខ្មែរក្រហមចូលកាន់កាប់ថ្ងៃ១៧ មេសា ៧៥ នោះ តើវណសិរ្សរួមរួបជាតិមានបានផ្សព្វផ្សាយតាមវិទ្យុ ដែលបានអំពាវនាវដល់ប្រជាជននៅទីក្រុងភ្នំពេញដែរឬទេ? តើលោកស្រីមានចាំថាមានការអំពាវនាវអ្វីដែរឬទេ?

**ឆ៖** ពិតជាមាន។

**ស៖** តើគេអំពាវនាវឲ្យប្រជាជននៅទីក្រុងភ្នំពេញធ្វើអ្វី?

**ឆ៖** តើលោកចង់សួរមុនខែមេសា ឆ្នាំ៧៥ មែនទេ?

**ស៖** គឺខ្ញុំសួរក្នុងពេលសង្គ្រាមមុន ខែមេសា ៧៥។ ប្រសិនបើលោកស្រីមិនប្រាកដ អត់អីទេ។

**ឆ៖** គេផ្សព្វផ្សាយការអំពាវនាវជាញឹកញាប់ ហើយនិងការអំពាវនាវឲ្យងើបបះបោរប្រឆាំងរបបសាធារណរដ្ឋខ្មែរ គឺអំពាវនាវក្នុងនាមព្រះបាទសម្ដេច នរោត្តម សីហនុ ដូចជាថាសម្ដេច សីហនុឲ្យប្រជាជននៅទីជនបទជាដើម គាំទ្រទៅដល់រណសិរ្សរួបរួមជាតិកម្ពុជាជាដើម។ នេះគឺជាៗការអំពាវនាវ ដែលគេធ្វើជាបន្តបន្ទាប់រហូតទៅ។

**ស៖** តើគេមានអំពាវនាវឲ្យប្រជាជនទីក្រុងភ្នំពេញចាកចេញពីទីក្រុងដែរឬទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** លោកស្រីទើបតែបញ្ជាក់រួចហើយ អំពីសម្ដេច សីហនុ។ ខ្ញុំចង់សួរលោកស្រីមួយចំនួនអំពីសម្ដេច សីហនុ។ ក្នុងនាមលោកស្រីជាអ្នកសារព័ត៌មាន រាយការណ៍អំពីប្រទេសកម្ពុជា តើលោកស្រីមានបានសិក្សាអំពីប្រវត្តិដ៏គួរឲ្យចាប់អារម្មណ៍របស់សម្ដេច សីហនុ ដែរឬទេ?

**ឆ៖** ខ្ញុំពិតជាបាន។

[០៩:៥១:៤៩]

**ស៖** តើលោកស្រីធ្លាប់ជួបសម្ដេច ដោយផ្ទាល់ដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ជួប។

**ស៖** តើលោកស្រីអាចរៀបរាប់អំពីការប្រាស្រ័យទាក់ទងរបស់លោកស្រីជាមួយនឹងសម្ដេចបានដែរឬទេ?

**ឆ៖** ក្រោយខែមករា ឆ្នាំ៧៥ ខ្ញុំបានជួបសម្ភាសជាមួយសម្ដេចជាច្រើនដង នៅសហរដ្ឋ

អាមេរិក។ នៅពេលនោះ គឺនៅៗពេលដែលព្រះអង្គគឺជាសមាជិករបស់រណសិរ្សរួបរួម ហើយខ្ញុំបានសរសេរអំពីការសម្ភាសជាមួយសម្តេច ហើយខ្ញុំបានជួបព្រះអង្គមួយសាទៀត នៅពេលដែលអ៊ុនតាក់ចូលមកគឺនៅពេលដែលមានការបោះឆ្នោត គឺខ្ញុំជួបនៅទីក្រុងភ្នំពេញមួយដងទៀត។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំចង់អាននូវផ្នែកមួយចំនួននៅក្នុងសៀវភៅរបស់លោកស្រីដែលនិយាយអំពី សម្តេច សីហនុ។ បន្ទាប់មកខ្ញុំស្នើសុំឲ្យលោកស្រីបញ្ជាក់ទៅលើបញ្ហាមួយចំនួន គឺឯកសារ E3/20 កថាខណ្ឌទី១ គឺថាមាន ERN 00238146 ទំព័រ៤៣៣, ភាសាបារាំងមានលេខ 00638681 នៅទំព័រ៤២២, និងភាសាខ្មែរមានលេខ 00232570 ទៅដល់ -- និងទំព័របន្តបន្ទាប់ ទំព័រ៥៧២-៥៧៣។

[០៩:៥៣:៤៩]

លោកស្រីបានសរសេរថា៖ “ពីរថ្ងៃមុនពេលដែលវៀតណាមចូលកាន់កាប់ភ្នំពេញ សម្តេច សីហនុ បានរត់គេចចេញពីការឃុំខ្លួនក្នុងផ្ទះ គឺមានការតវ៉ាយ៉ាងខ្លាំងពីខាងចិន។ សម្តេច សីហនុ ជាមួយនឹង សម្តេច ម៉ូនិច ហើយនិងក្រុមគ្រួសាររបស់ព្រះអង្គ បាននាំ -- ត្រូវបានគេនាំទៅជួប ប៉ុល ពត ដែលប្រាប់គាត់ថា គឺថាយើងឥឡូវហ្នឹង កំពុងជួបការលំបាកហើយ។ ដោយគ្មានការស្ទាក់ស្ទើរ សម្តេច សីហនុ បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំង ជាទីដែលព្រះអង្គបានធ្វើសន្និសីទកាសែតជាមួយឯកអគ្គមានរយៈពេល ៦ម៉ោង។ ព្រះអង្គបាននិយាយពីការជាប់ឃុំនៅក្នុងព្រះរាជដំណាក់៣ឆ្នាំ។ នៅក្នុងរយៈពេលនោះព្រះអង្គផ្ទំបានតែបីម៉ោងប៉ុណ្ណោះក្នុងមួយយប់។ ព្រះអង្គយាងបោះជំហានវែងទៅមកៗ នៅក្នុងបន្ទប់នានានៃអាគារដ៏តូចដែលគេរៀបចំឲ្យព្រះអង្គគង់នៅព្រះបរមរាជវាំង។ ព្រះអង្គរៀបចំបាយទឹកដោយផ្ទាល់ និងស្តាប់វិទ្យុបរទេស។ ក្នុងរយៈពេលពីរឆ្នាំដំបូង សម្តេច ព្រះសីហនុ និងអ្នកនៅជុំវិញព្រះអង្គមិនដែលឃើញមនុស្សណាម្នាក់ក្រៅពី ខៀវ សំផន ឡើយ។ ឆ្នាំចុងក្រោយគឺឆ្នាំ១៩៧៨ ព្រះអង្គត្រូវគេនាំដើរកំសាន្តទៅជនបទនានាជារៀងរាល់ថ្ងៃ ដើម្បីលើកទឹកចិត្តប្រជាជនឡើងវិញដោយមានការសន្និដ្ឋានទុកជាមុនអំពីការឈ្លានពានរបស់វៀតណាម”។ ដូច្នេះ សំណួរទី១ ដែលខ្ញុំចង់សួរលោកស្រីគឺថា តើអ្នកណាដែលមើលព្រះអង្គ ដែលឃុំព្រះអង្គនៅក្នុងវាំងអស់រយៈពេលពីរបីឆ្នាំដំបូងនោះ?

**ឆ៖** គឺមេដឹកនាំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនោះ។

[០៩:៥៥:៥៥]

**ស៖** លោកស្រីក៏បាននិយាយអំពីមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងទំព័រ២០៥, ២០៦

ភាសាអង់គ្លេសមានលេខ 00237910 និងទំព័របន្តបន្ទាប់, ភាសាបារាំងគឺមានលេខ 00638469 ទំព័រ ២០៧ និង ២០៨, និងខ្មែរមានលេខ 00232273 គឺទំព័រ ២៧៥ និង ២៧៦។ លោកស្រីបានសរសេរ ដូចតទៅនេះ ទាក់ទងទៅនឹង អៀង សារី៖ "យើងបានមកដល់ឆាប់រហ័សក្នុងនាមជារដ្ឋមន្ត្រីក្រសួងការ បរទេស។ សីហនុ មិនមានបញ្ហាអ្វីនោះទេគឺយើង -- គឺ អៀង សារី បានប្រាប់អង្គការសហប្រជាជាតិ ថា ការជម្លៀសខ្លួនត្រូវបានធ្វើឡើងដោយមានការបង្ហូរឈាម ហើយប្រជាជនត្រូវបានគេធ្វើបាប ហើយ ការបដិវត្តឈរលើជំហរខ្លួន ឧបត្ថមខ្លួន ហើយមិនត្រូវការជំនួយបរទេសឡើយ"។ ហើយបន្តទៅទំព័រ ខាងក្រោយ៖ "បេសកកម្មរបស់ព្រះអង្គបានបំពេញចប់សព្វគ្រប់។ សម្ដេចព្រះ នរោត្តម សីហនុ បាន យាងចាកចេញពីទីក្រុងញូវយ៉ក ហើយបានប្រកាសឲ្យដឹងជាសាធារណៈថា ព្រះអង្គនឹងយាងទស្សនកិច្ច នៅប្រទេស១១ទៀត ដូចជាអាល់បានី សូម៉ាលី អារ៉ាប់ យេមេន ជាដើមមុននឹងវិលត្រឡប់មកកាន់ប្រទេស កម្ពុជាវិញ។ ជនជាតិកម្ពុជាដែលធ្លាប់បម្រើព្រះអង្គជាសហការីនៅក្រុងប៉េកាំងក្នុងរយៈពេលនៃការ និរទេសខ្លួនជាច្រើនឆ្នាំមកហើយនោះ បានសម្រេចចិត្តបោះបង់មុខតំណែងចោលទាំងអស់។ ជាឯកជន សម្ដេចធ្លាប់មានបន្ទូលប្រាប់ឲ្យពួកនោះឲ្យដឹងពីគ្រោះថ្នាក់ផ្សេងៗដែលពួកគេអាចនឹងជួបប្រទះ ហើយ អ្នកទាំងនោះបានស្វែងរកសិទ្ធិជ្រកកោននៅប្រទេសបារាំង។ នៅទីក្រុងប៉ារីស ជនជាតិកម្ពុជាទាំងនោះ បាននិយាយបដិសេធនូវសេចក្ដីថ្លែងការណ៍ទាំងអស់របស់សម្ដេច ព្រះនរោត្តម សីហនុ ស្ដីពីពួកខ្មែរ ក្រហមដែលព្រះអង្គបានថ្លែងនៅអង្គការសហប្រជាជាតិ។ ពួកគេបានអះអាងបញ្ជាក់ថា អ្នកបដិវត្តន៍ថ្មី បានបោះចោលនូវកម្មវិធីសេរីនិយម ដែលធ្លាប់សន្យាសង្គ្រាម ហើយពួកគេបានលើកឡើងដោយលើក សក្ខីកម្មផ្សេងៗ ដែលលើកឡើងដោយពួកជនភៀសខ្លួន"។ តើអ្វីដែលលោកស្រីសរសេរនោះ ជាការ ត្រឹមត្រូវដែរឬទេ អំពីសម្ដេច សីហនុ?

[០៩:៥៨:៤២]

**ធ៖** ពិតជាត្រឹមត្រូវ។

**ស៖** មុននឹងខ្ញុំសួរបន្ថែមលម្អិត ខ្ញុំចង់អានជូនលោកស្រីនៅមួយផ្នែកទៀតគឺទំព័រ៤៤៥ ជាភាសា អង់គ្លេសគឺមានលេខ 00238158, ខ្មែរមានលេខ 00232579។ លោកស្រីបានសរសេរថា៖ "ភរិយា របស់ព្រះអង្គ គឺម៉ូនិច មិនចង់ទៅកម្ពុជាវិញឡើង។ នៅពេលបន្ទាប់ នៅព្រឹកថ្ងៃបន្ទាប់ពីទ្រង់ភ្ញាក់ពីបន្ទប់ ព្រះអង្គទ្រង់ស្ងន់ស្ញោចំពោះច្រវាក់កាទូតអន្តរជាតិដែលបានដាក់នៅជុំវិញព្រះកាយព្រះអង្គ។ ពេលនោះ ទ្រង់ក៏បានបញ្ជូនសារមួយទាំងផ្លូងទៅឲ្យអគ្គរដ្ឋទូតអាមេរិកប្រចាំនៅអង្គការសហប្រជាជាតិ ស្នើសុំនូវ

សិទ្ធិជ្រកកោនផ្នែកនយោបាយ។ ភ្លាមនោះលោកអគ្គរដ្ឋទូត យ៉ាំង ក៏បានពិភាក្សារឿងនេះជាមួយថ្នាក់លើរបស់គាត់នៅក្រសួងការបរទេសឯទីក្រុងវ៉ាស៊ីនតោន។ ក្រោមការបញ្ជាពីថ្នាក់លើរបស់គាត់ គាត់ក៏បានដាក់ឱ្យទ្រង់ចូលសម្រាកពេទ្យ ពេទ្យលេណុកហៀលនៅទីនោះ។ លោក យ៉ាំង បានទូលព្រះអង្គថា ការជ្រើសរើសយកការនិរទេសខ្លួន គឺជាការសម្រេចចិត្តខុសឆ្គងមួយ។ រីឆាដ ហូប្រ៊ុក ដែលជាជំនួយការរបស់លោករដ្ឋលេខាធិការប្រចាំអាស៊ីបូព៌ាបាននិយាយថា ពួកយើងបានទូលទ្រង់ថា ការជ្រើសរើសយកការនិរទេសខ្លួនរបស់ព្រះអង្គនៅសហរដ្ឋអាមេរិកគឺធ្វើឱ្យបាត់នូវភាពជាអ្នកដឹកនាំឯករាជ្យរបស់ទ្រង់នៅពេលនោះ"។ តើលោកស្រីនៅពេលនោះបានដឹងអំពីហេតុការណ៍ដែលថា សម្តេច សីហនុ បាននិយាយជាមួយអង្គការសហប្រជាជាតិដែលនិយាយលើកសរសើរអំពីខ្មែរក្រហមជាបន្តបន្ទាប់ ដោយនិយាយនូវពាក្យពេចន៍ដែលរៀបចំឡើងដោយ អៀង សារី ហើយក្រោយមកទៀតស្នើសុំសិទ្ធិជ្រកកោនផ្នែកនយោបាយនោះដែរឬទេ?

[១០:០០:៤១]

**ឆ៖** ប្រហែលជាគ្រាន់តែជាការរាយការណ៍ ជាព័ត៌មានសាធារណៈតែប៉ុណ្ណោះ។

**ស៖** តើអ្នកណាជាអ្នករៀបចំសុន្ទរកថារបស់ព្រះអង្គ ដែលព្រះអង្គអាននៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ នៅខែមករា ឆ្នាំ៧៩ នោះដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** នៅពេលនោះ តើលោកស្រីដឹងថា តើសម្តេច សីហនុ មានព្រះរាជបុត្រាបុត្រី និងចៅប៉ុន្មានអង្គ?

**ឆ៖** ខ្ញុំដឹង។

**ស៖** តើលោកស្រីដឹងដែរឬទេថា តើបុត្រាបុត្រី និងចៅរបស់ព្រះអង្គហ្នឹងស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលសម្តេច សីហនុ ទៅអង្គការសហប្រជាជាតិដើម្បីថ្លែងព្រះរាជសុន្ទរកថានោះដែរឬទេ?

**ឆ៖** ពិតជាមាន។

**ស៖** នៅពេលដែលសម្តេច សីហនុ ទ្រង់គង់នៅទីក្រុងញូវយ៉កដើម្បីថ្លែងព្រះរាជសុន្ទរកថាជាមួយអង្គការសហប្រជាជាតិ តើព្រះអង្គដឹងដែរឬទេថា ព្រះរាជបុត្រាបុត្រី និងចៅរបស់ព្រះអង្គ ស្នាក់នៅក្នុងទីក្រុងភ្នំពេញ ហើយថាតើព្រះអង្គដឹងថា ពួកគេមានជីវិត ឬក៏អត់ទេ នៅទីក្រុងភ្នំពេញនោះ?

**ឆ៖** នៅពេលដែលខ្ញុំបាននិយាយជាមួយសម្តេច សីហនុ និងព្រះអង្គម្ចាស់ម៉ូនិច គឺថាព្រះអង្គដឹងថា នៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែយើងមិនបាននិយាយអំពីព័ត៌មានលម្អិតនោះឡើយ។

**សៈ** តើនៅពេលក្រោយមកលោកស្រីដឹងដែរឬទេ ឬក៏ថានៅពេលថាមុនព្រះអង្គមកទីក្រុងញូវយ៉ក គាត់ស្ថិតនៅក្នុងការឃុំខ្លួននៅក្នុងព្រះរាជវាំង។ ហើយគេអាចដាក់ព្រះអង្គនៅឆ្ងាយពីអ្នកដទៃដោយសារព្រះអង្គអាចស្តាប់តែវិទ្យុ និងជួបតែ ខៀវ សំផន តែប៉ុណ្ណោះ។ តើអ៊ីចឹងមែនទេ?

[១០:០២:៥៣]

**ឆ៖** ពិតជាអ៊ីចឹង។

**សៈ** តើនៅពេលក្រោយមកលោកស្រីដឹងដែរឬទេ ថាតើមានព្រះរាជបុត្រាបុត្រី និងចៅរបស់ព្រះអង្គប៉ុន្មានអង្គ ត្រូវបានគេសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា មានមួយចំនួនត្រូវបានគេសម្លាប់ចោល។

**សៈ** ក្រោយមក នៅត្រង់ទំព័រ៤៧៨ សៀវភៅរបស់លោកស្រី អង់គ្លេស ERN 00238191, ខ្មែរគឺ 00232618 នៅទំព័រ៦២០។ អត់មានបកប្រែជាភាសាបារាំងនោះទេ ដោយសារតែអត់មានបកប្រែ។ លោកស្រីបានសរសេរនៅក្នុងកិច្ចសម្ភាសន៍មួយថា សម្តេច សីហនុ ដឹងថាវៀតណាមនឹងដកចេញពីប្រទេសកម្ពុជា។ ហើយគ្រោះមហន្តរាយនេះនឹងមិនអាចចៀសបាននោះទេ នឹងកើតឡើង។

នៅក្នុងទំព័របន្ទាប់លោកស្រីបានសរសេរថា សម្តេច សីហនុ បានលើកឡើងថា៖ “តើវាមានន័យយ៉ាងម៉េច ប្រសិនបើយើងចង់ឲ្យវៀតណាមនោះដកចេញ ហើយអនុញ្ញាតឲ្យបនប្រល័យពូជសាសន៍ ប៉ុល ពត ត្រឡប់មកជាមួយប្រជាជនវិញ? ប្រសិនបើអនុញ្ញាត តើវាមានន័យយ៉ាងម៉េចប្រសិនបើយើងទាមទារឲ្យកងកម្លាំងវៀតណាមដកខ្លួនចេញ ហើយបែរជាផ្តល់ឱកាសឲ្យអំពើប្រល័យពូជសាសន៍ខ្មែរក្រហមកើតមានមកលើប្រជាជនខ្មែរជាថ្មីវិញនោះ?”។ នៅពេលលោកស្រីបាននិយាយជាមួយនឹងសម្តេច សីហនុ នៅក្នុងទសវត្សរ៍៨០ តើទ្រង់បានពន្យល់អំពីការយល់ឃើញរបស់ទ្រង់អំពីការ -- គេកត់ត្រាអំពីអំពើរំលោភសិទ្ធិមនុស្សរបស់ខ្មែរក្រហមដែរឬទេ? ហើយខ្មែរក្រហមធ្វើយ៉ាងម៉េចចំពោះកម្ពុជា -- ប្រជាជនកម្ពុជា?

[១០:០៥:១៧]

**ឆ៖** បាទ គឺដូច្នោះមែន ខ្ញុំបានមើលឃើញ។

**សៈ** តើគេ -- តើទ្រង់លើកឡើងយ៉ាងម៉េច ចំពោះបញ្ហាខ្មែរក្រហមនោះ?

**ធ៖** ទ្រង់ គឺគាត់និយាយអត់ស៊ីសង្វាក់គ្នានោះទេ ពេលខ្លះនិយាយអំពីរបបប្រល័យពូជសាសន៍ ដូចដែលដកស្រង់នៅក្នុងហ្នឹង។ ពេលខ្លះទ្រង់លើកឡើងអំពីភាពចាំបាច់ត្រូវតែធ្វើការងារជាមួយខ្មែរក្រហម។

**ស៖** តើចម្លើយទាំងពីរនោះ យោបល់របស់ទ្រង់ទាំងពីរនោះមិនស៊ីសង្វាក់គ្នា ហើយទ្រង់ សីហនុ គឺដែលលើកឡើងបដិសេធ ចំពោះការរំលោភសិទ្ធិមនុស្សនៅក្នុងសម័យខ្មែរក្រហមដែរឬទេ?

**ធ៖** ខ្ញុំដូចជាអត់ចាំទេ។

[១០:០៦:២៥]

**ស៖** ខ្ញុំសូមចូលប្រធានបទមួយទៀត គឺដោយសង្ខេបខ្លីតែប៉ុណ្ណោះ។ ពាក់ព័ន្ធនឹងបញ្ហាវៀត-ណាម ជនរងគ្រោះវៀតណាមនៅក្នុងរបបខ្មែរក្រហម។ លោកស្រីបានសរសេរនៅក្នុងទំព័រ២៤២, អង់គ្លេស ERN 00237947 ទំព័រ២៤២, បារាំង 00638502 ទំព័រ២២២, ខ្មែរគឺ 00232320 ទំព័រ៣២៣ -- ៣២២ គឺវាមានការណែនាំថ្មីមួយនៅក្នុងឆ្នាំ១៩៧៧ គឺសម្លាប់អ្នកដែលមានញាតិសន្តានជាវៀតណាម។ នៅពេលនោះ គឺគេមានបុគ្គលម្នាក់ គឺគាត់លាក់បាំងប្រវត្តិរបស់ពួកគេ។ គេចាប់ផ្តើមខ្មែរក្រហម គេចាប់ផ្តើមសម្លាប់អ្នកណាដែលមានញាតិសន្តានដែលមកពីកម្ពុជាក្រោម។ សំណួរ តើលោកស្រីអាចបញ្ជាក់ទេ តើ ស៊ី សូផា នេះតើជានរណា ដែលគាត់បានរៀបរាប់សម្តីអម្បាញ់មិញនេះ?

**ធ៖** គាត់ គឺជាសមាជិកម្នាក់នៅក្នុងគ្រួសារនុ៎ង ហើយខ្ញុំបានជួបគាត់ ហើយបានសួរគាត់។

**ស៖** តើលោកស្រីបានសម្ភាសគាត់តែម្តង ឬច្រើនដង?

**ធ៖** ខ្ញុំសម្ភាសគាត់ច្រើនដង។

**ស៖** តើស៊ីសូផា នោះ តាមខ្ញុំយល់ គឺគាត់គឺជាអ្នកដែលជាកូនចៅដែលមកពីកម្ពុជាក្រោមដែរឬទេ?

**ធ៖** បាទ គឺពិតដូច្នោះមែន គាត់មកពីកម្ពុជាក្រោម។

[១០:០៨:៣៣]

**ស៖** តើគាត់កើតនៅប្រទេសកម្ពុជា ឬក៏យ៉ាងម៉េច?

**ធ៖** ខ្ញុំជឿថា គាត់ប្រហែលជាកើតនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែខ្ញុំអត់ចាំច្បាស់ទេថា គាត់កើតនៅទីនេះ។

**ស៖** ខ្ញុំចង់បន្តសួរលោកស្រីអំពីជនជាតិចាមម្តង។ លោកស្រីបានរស់នៅក្នុងប្រទេសកម្ពុជាឆ្នាំ

៧២ ដល់៧៤ តើលោកស្រីអាចរៀបរាប់ដោយសង្ខេបយ៉ាងម៉េច ចំពោះជនជាតិចាមនៅក្នុងប្រទេសកម្ពុជា?

**ឆ៖** ចាម គឺជាជនជាតិភាគតិចម៉ូស្លីម។ នៅពេលដែលខ្ញុំរស់នៅក្នុងទសវត្សរ៍ឆ្នាំ៧០ វាមានការរើសអើងពូជសាសន៍។ គេចាត់ទុកថាជនជាតិចាមហ្នឹង គឺជាអ្នកដែលខ្ជិល -- ប្រទេសម៉ូស្លីមនៅក្នុងតំបន់ដូចជា ម៉ាឡេស៊ី ហើយនិងឥណ្ឌូនេស៊ី គឺថាមានយន្តការការពារជនជាតិបែបនេះ នៅក្នុងសង្គ្រាម ហើយនៅក្នុងសម័យខ្មែរកម្ពុជាប្រជាធិបតេយ្យជនជាតិចាមត្រូវបានគេកំណត់គោលដៅសម្លាប់ចោល។

[១០:០៩:៥២]

**ស៖** នៅពេលដែលលោកស្រីធ្វើដំណើរ ឬក៏ធ្វើ ដើរនៅតាមប្រទេសកម្ពុជានោះ តើលោកស្រីអាចមើលស្គាល់ថា នរណាជាជនជាតិចាមដែរឬទេ?

**ឆ៖** គឺតាមសម្លៀកបំពាក់។ យើងឃើញថា ស្ត្រីយើងអាចមើលឃើញថា គាត់ស្លៀកពាក់ប្លែក ហើយសហគមន៍របស់គេគឺថាជាទូទៅក៏យើងឃើញថារស់នៅខុសពីកម្ពុជាផងដែរ។

**ស៖** ចុះចំពោះការជួតក្បាលវិញ តើគេ -- គាត់ឃើញថាអាចមាន គាត់ពាក់អ្វីនៅលើក្បាលដែរឬទេ?

**ឆ៖** គឺយើងឃើញហើយស្ត្រីគឺថា មានដូចជាក្រមា កន្សែងគេអ៊ីចឹង ហើយជួតពីលើក្បាល។

**ស៖** ចុះបុរសវិញមានពុកចង្កាដែរឬទេ?

**ឆ៖** ចាស គឺមាន។

[១០:១០:៤៨]

**ស៖** លោកស្រីបានសរសេរនៅក្នុងទំព័រ២៥១, អង់គ្លេស ERN គឺ 00237956, បារាំងគឺ 00638511, ខ្មែរគឺ 00232322។ "គោលនយោបាយនៃការសម្លាប់ជនជាតិភាគតិចមួយចំនួន ហើយនិងចង់ឲ្យមានជនជាតិថ្មី ហើយវាប៉ះពាល់ដល់ជនជាតិចាម។ ហើយយើងឃើញគេសម្លាប់ចោលដោយសារតែប្រតិកិរិយារបស់អ្នកទាំងអស់នេះ។ ហើយពួកគេគឺថា មិនអាចចូលនៅក្នុងសាសនាព្រះពុទ្ធរបស់ខ្មែរបាន"។ ទំព័រ២៥២ "គេចាត់ទុកថាជនជាតិចាម គឺជាអ្នកវាយប្រឆាំងទៅនឹងប្រទេសកម្ពុជា ហើយជនជាតិចាមភាគច្រើនគឺបានចូលរួមជាមួយនឹងខ្មែរក្រហម។ នៅពេលនោះគឺថា នៅក្រោយមកមានការបង្កើតសហករណ៍ ហើយកុម្មុយនីស្តបានប្រកាសថា ជនជាតិចាមមានការរស់នៅ -- ជីវភាពរស់នៅដោយឡែក ហើយជាអ្នកប្រឆាំងទៅនឹងបដិវត្តន៍។ ហើយក្រោយជ័យជម្នះខ្មែរក្រហម គេវាយ

ប្រហារទៅលើជនជាតិចាមក្នុងលក្ខណៈចំហ ហើយជាលក្ខណៈប្រព័ន្ធ។ មេសហគមន៍ជនជាតិចាមត្រូវបានគេតាមសម្លាប់ចោល។ មេដឹកនាំសាសនាត្រូវបានសម្លាប់ចោល។ វិហារអ៊ិស្លាមជាច្រើនត្រូវគេកម្ទេចចោល ឬប្រមាថ ត្រូវប្រែក្លាយឱ្យទៅជាជម្រុកស្រូវ ទ្រុងជ្រូក ទុកដូចវត្តអារាមពុទ្ធសាសនាដែរ។ គេបានដុតគម្ពីគូរ៉ាន់ចោល សាលារៀនរបស់ចាមត្រូវបិទទ្វារដូចសាលារៀនផ្សេងទៀតនៅទីដទៃទៀត"។

[១០:១៣:១១]

ខ្ញុំអានតទៅទៀត មុនពេលដែលៗខ្ញុំសួរលោកស្រី ទំព័រ២៥០ ទៅដល់៥១។ បាទ សូមអធ្យា-ស្រ័យគឺទំព័រដដែលទេ។ បទប្បញ្ញត្តិផ្សេងៗដែលប្រជាជនកម្ពុជាម្នាក់ៗត្រូវតែប្រតិបត្តិតាម បន្ទាប់ពីថ្ងៃជ័យជម្នះក៏មានផលវិបាកនាំឱ្យវិនាសអន្តរាយសម្រាប់ជនជាតិចាមកាន់តែខ្លាំងថែមទៀត ដែលត្រូវបង្ខិតបង្ខំឱ្យធ្វើការជ្រើសរើសរវាងជំនឿចំពោះសាសនា អត្តសញ្ញាណរបស់គេ និងជីវិតផ្ទាល់របស់ខ្លួន។ ពួកគេត្រូវលះបង់ឈ្មោះដើមរបស់ខ្លួន ហើយជ្រើសរើសឈ្មោះថ្មីជាខ្មែរវិញ ដើម្បីបង្ហាញគេថា ឫកពាជាខ្មែរ ពួកគេបានកាត់សក់ កោរពុកមាត់ចេញ ស្លៀកពាក់ខោអាវខ្មែរដែលជាការបញ្ចប់នូវអត្តសញ្ញាណរបស់គេទាំងអស់។ ដើម្បីសាកល្បងទៅលើពួកគេ គេបានបង្ខំឱ្យហូបសាច់ជ្រូកក្រោមការគំរាមកំហែងដោយចុងអាវុធ។ គ្រួសារចាមជាច្រើនត្រូវបានគេបំបែកបំបាក់ចេញពីគ្នា ដើម្បីបញ្ចៀសកុំឱ្យពួកគេ -- ដើម្បីបញ្ចៀសកុំឱ្យពួកមនុស្សពេញវ័យចម្លងវប្បធម៌របស់គេទៅឱ្យពួកក្មេងៗដែលត្រូវបានបញ្ជូនឱ្យរស់នៅជាមួយកូនខ្មែរនៅកន្លែងដេករួមជាច្រើន ឬក្នុងកងចល័តយុវជន"។

ចំណុចចុងក្រោយ "ប៉ុន្តែពួកចាមបានបះបោរប្រឆាំង ភូមិចាមជាច្រើនបានចាប់កាន់អាវុធ ហើយបានត្រូវកម្ទេចដោយពួកខ្មែរក្រហម។ ភូមិជាច្រើនទៀតដែលតវ៉ាប្រឆាំងដោយមិនចេញមុខ ក៏ត្រូវពួកកម្មាភិបាលខ្មែរក្រហមបំផ្លិចបំផ្លាញរាបដល់ដីដូចគ្នា។ ពុំមានសហគមន៍ចាមណាមួយរួចផុតពីគ្រោះថ្នាក់ឡើយ។ ពួកចាមត្រូវបានគេបំបែកយកទៅដាក់ភូមិផ្សេងៗដែលមានខ្មែរច្រើនលើសលប់ជាងហើយត្រូវបង្ខំឱ្យខ្លួនដូចជាខ្មែរថែមទៀត។ ភាគច្រើននៃភូមិចាមច្រើនស្ថិតនៅតាមមាត់ទន្លេមេគង្គក្នុងភូមិភាគបូព៌ា និងភូមិភាគនិរតី ព្រមទាំងក្នុងអតីតភូមិភាគឧត្តរផង"។ តើនៅក្នុងការសិក្សាស្រាវជ្រាវរបស់លោកស្រី តើមានលោកស្រីសម្គាល់ហ្នឹងលើកឡើងប៉ុន្មានដងជាមួយនឹងជនជាតិចាម?

[១០:១៥:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ -- អ្នកជំនាញកុំអាលទាន់ឆ្លើយតប។

សូមអញ្ជើញ លោក វិចទ័រ កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណ លោកប្រធាន លោកស្រីចៅក្រម។ ដោយសារតែខ្ញុំយល់ឃើញថា ទោះបីជាខ្ញុំយល់ឃើញថាចាប់អារម្មណ៍ក៏ដោយ ក៏ប៉ុន្តែយើងត្រូវចាំអ៊ីម៉ែល ដែលមន្ត្រីច្បាប់ជាន់ខ្ពស់សរសេរមកកាន់យើងខ្ញុំនោះ គឺថាយើងគួរតែចាប់អារម្មណ៍លើចំណុចនេះ។ ការប្រព្រឹត្តចំពោះជនជាតិចាម ដូចជាមិនបានលើកឡើងនៅក្នុងប្រធានបទហ្នឹងទេ។ ខ្ញុំមិនមានបញ្ហាអ្វីនោះទេ ចំពោះការសួរសំណួរក៏ប៉ុន្តែ តើវាមានន័យយ៉ាងម៉េចដែរ ចំពោះខ្លឹមសារដែលមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើរំឭកយើងអំពីបញ្ហាហ្នឹង?

[១០:១៥:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៨:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ហ្វេនស៍ ដើម្បីឆ្លើយបញ្ជាក់ទៅភាគីបញ្ហានេះឲ្យបានច្បាស់លាស់។

បាទ សូមអញ្ជើញ លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហេតុផលនៅក្នុងអ៊ីម៉ែល គឺដើម្បីជៀសវាងឲ្យអ្នកជំនាញ កុំឲ្យពន្យារពេលស្តាប់សក្ខីកម្មគាត់រាប់អាទិត្យ។ អ្វីដែលជៀសមិនផុតនោះគឺបញ្ហាចាម ជាផ្នែកអង្គហេតុនៅក្នុងសំណុំរឿង០០២/០២ ដើម្បីធ្វើការថ្លឹងថ្លែងលើអង្គហេតុនេះ គឺយើងជាចៅក្រមស្នើសុំ ដូចបានស្នើសុំតាមអ៊ីម៉ែល កុំផ្តោតសំខាន់ច្រើនទៅលើអង្គហេតុនេះ។ ហើយសំណួរនោះគឺថា កម្រិតមួយចំនួនតិចបាន មួយចំនួនតូចបានហើយទៅលើអង្គហេតុនេះ។ តើសហព្រះរាជអាជ្ញាមានសំណួរច្រើនទេ ទៅលើអង្គហេតុនេះ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំអាចបញ្ចប់អង្គហេតុហ្នឹងត្រឹមតែ៥នាទី ឬក៏តិចជាងហ្នឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះហើយ គឺថាខ្ញុំស្នើសុំឲ្យភាគីទាំងសងខាងនេះថ្លឹងថ្លែងពេលវេលាប្រើប្រាស់ទៅលើអង្គហេតុនេះ គឺមានលក្ខណៈសមាមាត្រនឹងគ្នា។ សូមអញ្ជើញ!

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីសហមេធាវីនាំមុខ។

[១០:១៩:២៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមលើកឡើងដោយខ្លី ក្នុងចំណុចទាំងប្រាំនៃអ៊ីម៉ែលដែលបានផ្ញើជូនយើងខ្ញុំ "មានគោលនយោបាយពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះក្រុមជាក់លាក់"។ ហើយយើងមានអារម្មណ៍យល់ឃើញថាក្នុងក្រុមជាក់លាក់នេះ គឺបញ្ហាចាមក៏អាចដាក់បញ្ចូលដែរ លោកប្រធាន។ ដូច្នេះខ្ញុំចង់ គ្រាន់តែចង់ផ្តល់ព័ត៌មាននេះទៅដល់អង្គជំនុំជម្រះ ពីព្រោះយើងគិតថាចាមក៏ស្ថិតនៅក្នុងចំណុចទាំងប្រាំ ដែលអង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីធ្វើការពាក់ព័ន្ធនឹងការស្តាប់ចម្លើយរបស់អ្នកជំនាញបេកយ័រ នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ជាការលើកឡើងដ៏សមស្របហើយ ហើយឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់អ្នកជំនាញក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១០:២១ នាទីហើយចូលវិញនៅម៉ោង ១០:៣៨នាទី)*

[១០:៣៨:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ ហើយសំណួរចុងក្រោយគឺអ្នកជំនាញមិនទាន់បានឆ្លើយទេ លោកព្រះរាជអាជ្ញាអាចតាំងសំណួរសាជាថ្មីឡើងវិញ ទី១។ ទី២ ពេលដែលអានឯកសារ សូមព្រះរាជអាជ្ញាអានយឺតៗបន្តិច ពីព្រោះលោកអានលឿន អ៊ីចឹងអ្នកបកប្រែ ហ្នឹងគឺមានបញ្ហាប្រឈមនឹងបញ្ហាបកប្រែភាសា។

សូមអរគុណ។ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន**

សូមអរគុណលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកស្រី បេកយ័រ តើលោកស្រីមានបាននិយាយជាមួយជនជាតិចាមមុនឆ្នាំ៧៩ និងក្រោយឆ្នាំ៧៩ ដែរឬទេ?

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** ពិតជាធ្លាប់មែន។

**ស៖** តើលោកស្រីជួបសម្ភាសជាមួយជនជាតិចាមនៅក្រោយឆ្នាំ៧៩ នៅទីណា?

**ឆ៖** នៅក្នុងប្រទេសកម្ពុជា។

**ស៖** កន្លងមកយើងបានឃើញនៅក្នុងឯកសារ E3/1156 គឺជារបាយការណ៍របស់លោក មុត ដែលលោកស្រីបានជួប របស់ កង និង មុត ដែលលោកស្រីបានជួប។ តើនៅក្នុងឆ្នាំ៧៨, ៧៩ ហ្នឹងលោកស្រីមានបានជួបជាមួយនឹង -- ជួបសម្ភាសជាមួយចាមដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោកស្រីមានបានឃើញវិហារសាសនាចាមដែរឬទេ ក្នុងពេលមកធ្វើទស្សនកិច្ចនោះ?

**ឆ៖** អត់ទេ។

[១០:៤០:៥៧]

**ស៖** នៅពេលដែលលោកស្រីធ្វើទស្សនកិច្ច តើលោកស្រីមានបានឃើញវិហារសាសនាគ្រិស្តដែរឬទេ?

**ឆ៖** អត់ទេ។ តាមពិតទៅ វិហារមួយដែលខ្ញុំស្គាល់គឺជាវិហារសាសនាគ្រិស្តរបស់បារាំងដែល

នៅក្បែរអូតែលហ្នឹងត្រូវបានគេកម្ទេចចោលទាំងស្រុងតែម្តង។

**ស៖** ដូច្នេះគឺដើម្បីជាកំណត់ត្រាច្បាស់លាស់ថា មិនមានវិហារសាសនាគ្រិស្ត និងមិនមានវិហារចាមនោះទេ។

**ឆ៖** គឺវានៅក្បែរកាច់ជ្រុងសណ្ឋាគាររ៉ាហ្វល។ វាជាវិហារសាសនាគ្រិស្តដ៏ធំ ហើយវាបែរមុខទល់នឹងឡូភ្នំ។ គឺវាបែរទៅខាងទន្លេ នៅតាមផ្លូវមុនីវង្ស។

**ស៖** សូមអរគុណលោកស្រី។ នៅទំព័រ២២៦ នៃសៀវភៅរបស់លោកស្រី ជាភាសាអង់គ្លេសមានលេខ 002337931, ជាភាសាបារាំងមានលេខ 00638488, ភាសាខ្មែរមានលេខ 00232301 លោកស្រីបាននិយាយថា៖ "ជំហានបន្ទាប់គឺកម្ទេច គឺបំបាត់គ្រួសារដែលជាផ្នែកដ៏សំខាន់របស់សង្គម។ ក្រៅពីការរៀបចំប្រជាជនជាបីប្រភេទស្របតាមរដ្ឋធម្មនុញ្ញ គឺកម្មករ កសិករ និងកងទ័ព ពួកខ្មែរក្រហមបានរៀបចំឲ្យមានប្រភេទសិប្បនិម្មិតផ្សេងៗទៀត ដែលបង្កើតបានជាប្រព័ន្ធវណ្ណៈថ្មីមួយ។ គ្មានស្របតាមទ្រឹស្តីសោះ ដែលលៃតាមគ្រួសារដែលនិយាយថាជាគ្រួសារមិនពិត។ ប្រភេទទាំងនេះត្រូវបានកំណត់អត្តសញ្ញាណ និងឥរិយាបថច្បាស់លាស់ជាថ្មី។ ត្រូវជម្រុះចោលការជំពាក់ចិត្តនឹងគ្រួសារ ជំនួសដោយការស្មោះត្រង់ចំពោះបដិវត្តន៍វិញ ឬយ៉ាងហោចពួកខ្មែរក្រហម និងសង្គមដូច្នេះ"។ តើលោកស្រីអាចពន្យល់បានដែរឬទេ តើលោកស្រីមានន័យយ៉ាងដូចម្តេចនៅពេលដែលលោកស្រីនិយាយថាខ្មែរក្រហមលុបបំបាត់គ្រួសារដែលជាកោសិកាសំខាន់របស់សង្គម។

[១០:៤៣:៥៥]

**ឆ៖** គឺបានន័យថា គ្រួសារលែងរស់នៅជាមួយគ្នា កូនត្រូវបំបែកចេញពីឪពុកម្តាយ ហើយកូនត្រូវបានគេ គេមិនឲ្យនិយាយថា ឪពុកម្តាយជាឪពុកម្តាយបង្កើតនោះទេ ឲ្យនិយាយថា ខ្មែរក្រហម ឬក៏អង្គការជាឪពុកម្តាយរបស់ពួកគេ។ ហើយប្តីប្រពន្ធដែលរៀបការជាមួយគ្នា គឺមិនតម្រូវឲ្យនៅជាមួយគ្នានោះឡើយ គេបំបែកចេញពីគ្នា។ ហើយការដែលគ្រួសារនៅជាមួយគ្នាហ្នឹងគឺត្រូវបានគេបែងចែក ឲ្យទៅជារដ្ឋទៅវិញ។ ដូច្នេះអានេះគឺជាអ្វីដែលបានកើតឡើង។ គេថានៅក្នុងស្ថានភាពហ្នឹងគឺថា កូនៗ ទៅជាអ្នកប្រឆាំងជាមួយឪពុកម្តាយរបស់គេទៅវិញ។

**ស៖** តើចំណុចនេះ វាខុសគ្នាយ៉ាងម៉េចដែរ ពីស្ថានភាពនៅក្នុងឆ្នាំ៧៣ -- ឆ្នាំ៧២ ដល់ឆ្នាំ៧៤ នៅកម្ពុជានោះ?

**ឆ៖** វាខុសគ្នាដូចមេឃនិងដី ដូចថ្ងៃនិងយប់អ៊ីចឹង។ គឺថាយើងឃើញថា ឪពុកម្តាយយកចិត្តទុក

ដាក់ជាមួយកូនខ្លាំង ហើយយើងឃើញបងប្អូនសាច់ញាតិគឺថារស់នៅជុំគ្នា ហើយមានការទទួលខុសត្រូវខុសៗគ្នា។ ដូច្នេះគឺថាគ្រួសារ គឺដូចជាមជ្ឈមណ្ឌលមួយអ៊ីចឹង។ វាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ ដូចខ្ញុំបាននិយាយជាមួយលោកស្រី អៀង ធីរិទ្ធ គឺលោកស្រីប្រមូលផ្តុំគ្រួសារគាត់ដោយជុំគ្នា ហើយវាមានចំណងទាក់ទងយ៉ាងជ្រាលជ្រៅបំផុត។

**ស៖** ខ្ញុំចង់ត្រឡប់ក្រោយបន្តិច ព្រោះខ្ញុំភ្លេចសួរលោកស្រីបន្តិចអំពីបញ្ហាជនជាតិចាម។ លោកស្រីបានទៅខេត្តកំពង់ចាម នៅឆ្នាំ៧៨។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតជាអ៊ីចឹង។

[១០:៤៦:២១]

**ស៖** តើលោកស្រីធ្វើដំណើរតាមទន្លេ អ៊ីចឹងមែនទេ?

**ឆ៖** ពិតជាអ៊ីចឹង។

**ស៖** នៅពេលលោកស្រីធ្វើដំណើរ តើលោកស្រីអាចប្រាប់បានដែរឬទេ ថាវាមានចម្ងាយប្រហែលជាប៉ុន្មានគីឡូម៉ែត្រ នៅពេលដែលលោកស្រីធ្វើដំណើរនោះ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំសរសេរថា២០០។ ខ្ញុំគិតថាយើងចំណាយពេលវេលាច្រើនតាមជិះតាម -- ការជិះឡានក៏ដូចជិះកប៉ាល់។

**ស៖** តើលោកស្រីចាំដែរឬទេ ថាលោកស្រីឃើញមនុស្សប្រហែលជាប៉ុន្មាននាក់ដែលលោកស្រីអាចស្គាល់ថា ជាជនជាតិចាម ឧទាហរណ៍ដូចជាពាក់ៗកន្សែងគ្របក្បាល ឬក៏ពាក់សម្លៀកបំពាក់ដែលយើងមើលទៅដឹងថាជាចាមនោះ?

**ឆ៖** អត់មានទាល់តែសោះ សូម្បីតែមួយនាក់។

**ស៖** ខ្ញុំចង់សួរលោកស្រីនៅទំព័រ២៨១ នៃសៀវភៅរបស់លោកស្រី។ ជាភាសាអង់គ្លេសមានលេខ 00237986, ភាសាបារាំងមានលេខ 00638540, និងភាសាខ្មែរមានលេខ 00232370។ លោកស្រីបានសរសេរថា៖ "ខែកក្កដា ឆ្នាំ៧៧ គឺមានការកាប់សម្លាប់យ៉ាងធ្ងន់ធ្ងរនៅសហករណ៍កំពត។ ពីមុនគឺគេយកមនុស្សតែម្នាក់ដែលគេសង្ស័យថាជាអ្វីប៉ុណ្ណោះ មិនមែនយកទាំងគ្រួសារនោះទេ។ ការសម្លាប់រង្គាលនេះ គឺគេយកគ្រួសារទាំងអស់តែម្តង ទាំងកូនង៉ែត។ គ្រួសារប្រាំពីរ ឬប្រាំបី ត្រូវគេសម្លាប់ចោលរួមគ្នាតែមួយលើក យើងមិនដឹងថាហេតុអ្វីនោះទេ"។ ដូច្នេះខ្ញុំចង់សួរថា អ្នកណាជា កុម្មួត នោះ?

[១០:៤៩:១៥]

**ឆ៖** ម៉ី កុម្ភួត គឺជាអ្នកធ្វើការនៅធនាគារ នៅក្នុងរបបសាធារណរដ្ឋខ្មែរ។ ហើយខ្ញុំបានរៀបរាប់រឿងរបស់គាត់នៅក្នុងសៀវភៅហ្នឹង ហើយមានរូបថតរបស់គាត់នៅក្នុងសៀវភៅទី១របស់ខ្ញុំទៀតផង។ គាត់គឺជាបុគ្គលិកធនាគារ ដែលជាជនជាតិបារាំង-កាណាដា ហើយក៏ជាអ្នកសិក្សាបានខ្ពង់ខ្ពស់។ ហើយក៏ជឿជាក់ថាខ្មែរក្រហមនឹងនាំមកនូវរដ្ឋាភិបាលដ៏ល្អមួយ។ ហើយខ្ញុំសម្គាស់គាត់យ៉ាងច្រើននៅក្រោយឆ្នាំ៧៩។

[១០:៥០:០៨]

**ស៖** គាត់និយាយថា សូម្បីតែក្មេង សូម្បីតែទារកក៏ត្រូវគេសម្លាប់។ ដូច្នេះ ខ្ញុំចង់អាននូវអត្ថបទមួយទៀតនៅក្នុងឯកសារ E2133, ERN មានលេខ 00242285, ខ្មែរដែលជាឯកសារច្បាប់ដើមមានលេខ 00006728 គឺជាបញ្ជីដែលមានឈ្មោះ១៨នាក់ ហើយឈ្មោះចុងក្រោយ គឺជាឈ្មោះស្ត្រីបារាំង។ ហើយវាបានបញ្ជាក់ដូចតទៅនេះ៖ "អ្នកទោសទាំងអស់រួមបញ្ចូលទាំងក្មេង១៦០នាក់ ត្រូវបានកម្ទេចដោយ បងស្រេង គឺសរុបទាំងអស់១៧៨នាក់"។ ដូច្នេះឈ្មោះ១៨នាក់នោះ គឺមានក្មេង១៦០នាក់ហ្នឹង។ ដូច្នេះ សរុបទាំងក្មេងទាំងមនុស្សធំគឺ១៧៨នាក់។ ក្នុងនាមជាអ្នកស្រាវជ្រាវម្នាក់នៅក្នុងរបបខ្មែរក្រហម តើលោកស្រីអាចពន្យល់បានដែរ ឬទេថាហេតុអ្វីបានជាគេសម្លាប់ទាំងកុមារទាំងក្មេងទៀតផងនោះ?

[១០:៥១:៤០]

**ឆ៖** ខ្ញុំអាចនិយាយឡើងវិញនូវសនិទានកម្មរបស់ខ្ញុំ គឺជាប្រព័ន្ធបណ្ដាញ ដែលថាគេចោទប្រកាន់តាមរយៈបណ្ដាញ ហើយការសម្លាប់ គឺការសម្លាប់បែបរុញទម្លាក់ដាក់គ្នាទៅវិញទៅមក គឺថាមនុស្សពេញវ័យមានទំនាក់ទំនងជាមួយមនុស្សពេញវ័យ ហើយបណ្ដាញនេះគឺរួមបញ្ចូលទាំងក្រុមគ្រួសារទាំងមូល។ នេះគឺជាហេតុផល។ ប៉ុន្តែមិនមានអ្វីដែលអាចពន្យល់នូវមូលហេតុក្រៅពីនេះបានទេ។

**ស៖** លោកស្រីបានបញ្ជាក់នៅក្នុងចំណុចដើមនៃសក្ខីកម្មរបស់លោកស្រី ដែលនិយាយថា "នៅពេលសង្គ្រាមផុតរលត់ទៅ" លោកស្រីបានសរសេរសៀវភៅតូចមួយ គឺជាសៀវភៅអំពីបុប្ផាណា។ តើលោកស្រីអាចរៀបរាប់បន្តិចបានទេ អំពីសៀវភៅរបស់លោកស្រីឈ្មោះថា "បុប្ផាណា" នោះ?

**ឆ៖** រឿងរបស់ បុប្ផាណា ក៏មាននៅក្នុងសៀវភៅ "នៅពេលសង្គ្រាមផុតរលត់ទៅ" ដែរ។ នៅពេលដែលខ្ញុំទៅចូលមើលបណ្ណសារនៅទួលស្លែង ខ្ញុំ -- ពេលនោះ គឺខ្ញុំចង់ទៅរកជនរងគ្រោះជាស្ត្រីម្នាក់ដែលខ្ញុំអាចស្គាល់នៅពេលដែលខ្ញុំរស់នៅទីនោះ ហើយជាស្ត្រីម្នាក់ដែលទុកនូវប្រវត្តិសាស្ត្រដ៏ល្អមួយ។ ហើយខ្ញុំបាននិយាយជាមួយបុគ្គលិកបណ្ណសារ ហើយខ្ញុំស្នើសុំឯកសាររបស់បុប្ផាណា ហើយគេមានការ

រន្ធត់ ដោយសារតែវាជាឯកសារដ៏គួរឲ្យចាប់អារម្មណ៍របស់ពួកគេ។ ដោយសារបុប្ផាណាជាបុគ្គលដ៏ល្អម្នាក់ ដោយសារគាត់មាន -- ដោយសារឯកសារនោះមានសំបុត្រស្នេហារបស់គាត់ ដែលគាត់ផ្ញើទៅសង្សាររបស់គាត់ជាកម្មាភិបាល។

[១០:៥៣:៣៧]

ហើយបន្ទាប់មកទៀត គឺលោក រិទ្ធី ប៉ាន់ ដែលជាអ្នកផលិតភាពយន្ត គឺជាផលិតឯកសារ ដែលផ្អែកទៅលើរឿងនោះ។ ដូច្នេះគឺគេផ្តល់ជូនគាត់ដោយមិនគិតថ្លៃ គឺជារឿងហេតុអំពីភាពរន្ធត់ ភ័យខ្លាចនៅក្នុងប្រទេសកម្ពុជាធ្វើជាឯកសារបារាំង និងខ្មែរ។ ហើយយើងអាចមើលឃើញ គឺយើងខ្សែភាពយន្ត "បុប្ផាណា" ហ្នឹង គឺបញ្ចាំងពីរដងក្នុងរយៈពេល១ថ្ងៃ នៅទួលស្លែង ហើយក៏យើងមាននៅបណ្ណសារបុប្ផាណាមួយដែរ គឺជាមជ្ឈមណ្ឌលឯកសារបុប្ផាណា ដែលជាមជ្ឈមណ្ឌលប្រមូលផ្តុំនៅខ្សែភាពយន្ត និងខ្សែភាពយន្តឯកសារនានាពីទូទាំងប្រទេសកម្ពុជា។ គាត់ក្លាយទៅជាបុគ្គលដ៏សំខាន់ ដូច្នេះហើយទើបខ្ញុំមានសៀវភៅតូចមួយដែលសរសេរអំពីគាត់ដោយផ្ទាល់តែម្តង ហើយវាមានទាំងភាសាបារាំង ខ្មែរ និងអង់គ្លេស។

[១០:៥៤:៤៣]

**ស៖** លោកស្រីបាននិយាយថា លោកស្រីបានពិនិត្យនូវឯកសាររបស់បុប្ផាណា នៅទួលស្លែង។ តើក្នុងសំណុំឯកសាររបស់គាត់នៅទួលស្លែងហ្នឹង វាមានទំហំធំប៉ុនណាដែរ វាមានភាពស៊ីសង្វាក់គ្នាកម្រិតណាដែរ?

**ឆ៖** វាជាឯកសារធំជាងគេបំផុតនៅក្នុងបណ្ណសារនៅទីនោះ។ គេទុកគាត់យូរជាងគេ ព្រោះថាមានរបាយការណ៍នៃការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរខ្លាំងជាងគេ ដោយសារគាត់ជាស្ត្រីម្នាក់ដែលមានរូបដែលថាមានភាពទាក់ទាញខ្លាំង ហើយគេបានទាំងប្រព្រឹត្តអំពើហិង្សាផ្លូវភេទលើគាត់ទៀត ហើយម្យ៉ាងទៀតប្តីរបស់គាត់ក៏ត្រូវបានគេនាំយកមកទួលស្លែងផងដែរ។ គឺជា គឺមានការសរសេរប្រវត្តិរូបច្រើនដងម្តងហើយម្តងទៀត ហើយនិងមានការសរសេរអំពីម្តាយរបស់គាត់ ហើយមនុស្សជាច្រើនត្រូវបានសម្លាប់។ ហើយចំពោះសំបុត្រស្នេហារបស់គាត់ហ្នឹងហើយ គឺជាមូលហេតុដែលធ្វើឲ្យមានការសរសេរឡើងវិញនូវរឿងរ៉ាវរបស់គាត់។ វាហាក់ដូចជាកំណត់ត្រា ឬក៏ទិនានុលេខន៍ដែលរៀបរាប់អំពីបុគ្គលម្នាក់ដែលបានឆ្លងកាត់នូវរឿងរ៉ាវ។ វាបានឆ្លុះបញ្ចាំងអំពីមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅអំពីអារម្មណ៍របស់គាត់ ក៏ដូចជាការបង្ហាញ ក៏ដូចជាការឆ្លុះបញ្ចាំងអំពីរឿងរ៉ាវរបស់បារាំង និងរឿងរ៉ាវរបស់ព្រះរាម គឺព្រះ

រាម និងនាងសីតាជាដើម គឺថានៅពេលដែលព្រះនាងសីតាបានផ្ញើសំបុត្រចំពោះប្ដីរបស់គាត់ គឺវាជារឿងដ៏អស្ចារ្យមួយ គឺវាមានកម្រាស់ប្រហែលប៉ុណ្ណេះ ដូចដែលខ្ញុំធ្វើដៃអ៊ីចឹង។ ហើយវាជាការរន្ធត់ ក៏ដូចជារំភើបដែរ នៅពេលដែលពិនិត្យមើលទៅលើសំណុំឯកសាររបស់គាត់។

[១០:៥៦:៤១]

**ស៖** តើលោកស្រីអាចប្រាប់បានទេ ហេតុអ្វីបានគេនាំគាត់មកទួលស្លែង?

**ឆ៖** បុប្ផាណា និងប្ដីរបស់គាត់ គឺព្យាយាមរកមធ្យោបាយដើម្បីរស់ជាមួយគ្នា ហើយពួកគេផ្ញើសំបុត្រទៅរកគ្នាទៅវិញទៅមក។ ប្ដីរបស់គាត់ព្យាយាមសូមការអនុញ្ញាតឲ្យ ដើម្បីឲ្យទៅនៅជាមួយគាត់ ហើយមានការច្រណែន ក៏ដូចជាការសង្ស័យពីអ្នកភូមិរបស់ បុប្ផាណា។ ដូច្នេះហើយគឺនៅពេលនោះគឺពួកគេគាត់ទាំងពីរចង់រស់នៅជាមួយគ្នា។ ហើយគេ -- ក្រោយមកគេនាំពួកគាត់ទាំងពីរយកមកទួលស្លែង ហើយសម្លាប់ចោលទាំងពីរនាក់។

**ស៖** ខ្ញុំចង់ -- មុននឹងបញ្ចប់ ខ្ញុំសូមសាកសួរសំណួរពីរបីបន្តទៅទៀត អំពីអ្វីដែលយើងបាននិយាយអំពីខ្មែរក្រហម ក៏ដូចជាខ្មែរ -- ក៏ដូចជាវៀតណាមនៅក្រោយខ្នង ហើយនិងអាមេរិកជាដើម ហើយនិងរឿងវៀតណាមនិង សេ.អ៊ី.អា ជាដើម។ នៅទំព័រ៤៣៥ នៃសៀវភៅរបស់លោកស្រីគឺមាន ERN មានលេខ 00238148, ភាសាបារាំងមានលេខ 00238148។

[១០:៥៨:៤៨]

ខ្ញុំសូមអភ័យទោសដោយសារខ្ញុំមិនមាន ERN ជាភាសាខ្មែរ។ លោកស្រីបានសរសេរថា៖ “ឡឺហ្សិនស្គី បាននិយាយថាខ្ញុំគួរតែជំរុញចិនឲ្យគាំទ្រ ប៉ុល ពត។ ខ្ញុំជំរុញថៃឲ្យជួយកម្ពុជាប្រជាធិបតេយ្យ។ បញ្ហាគឺថា តើពួកគេជួយប្រជាជនកម្ពុជាដោយរបៀបណា? ប៉ុល ពត គឺជាមនុស្សមិនល្អ យើងមិនអាចគាំទ្រពួកគេបានទេ ប៉ុន្តែចិនអាចជួយបាន”។ ហើយ ឡឺហ្សិនស្គី ដែលលោកស្រីចង់និយាយ -- ដែលលោកស្រីបាននិយាយហ្នឹងជាអ្នកណាដែរ លោកស្រី បេកយ័រ អាចប្រាប់យើងបានទេ?

**ឆ៖** ឡឺហ្សិនស្គី គឺជាទីប្រឹក្សាខាងសន្តិសុខជាតិឲ្យលោកប្រធានាធិបតី។

**ស៖** តើលោកស្រីអាចបញ្ជាក់បានទេថា អ្វីដែលគាត់និយាយហ្នឹងគឺជាការត្រឹមត្រូវ ដែលថាសហរដ្ឋអាមេរិកជំរុញចិន គឺថានៅក្រោយឆ្នាំ៧៩ហ្នឹង ជំរុញចិនឲ្យគាំទ្រខ្មែរក្រហម? គឺថាគាំទ្រតាមកម្លាំងយោធា។

**ឆ៖** ភស្តុតាងបានបញ្ជាក់ថា ពិតជាអ៊ីចឹងមែន។ គឺមានការកត់ត្រានូវការសម្ភាស ដែលថា

សហរដ្ឋអាមេរិក បានដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការបង្កើតសម្ព័ន្ធភាពរវាងខ្មែរក្រហម សម្តេចសីហនុ ហើយនិង សឺន សាន ដែលជាអតីតរដ្ឋមន្ត្រី -- នាយករដ្ឋមន្ត្រី ដើម្បីឲ្យមានការគាំទ្រនៅតាមព្រំដែនកម្ពុជា-ថៃ។ ហើយពួកគេក្លាយទៅជាស្ថាប័ននយោបាយ និងកងទ័ពមួយដែលធ្វើឲ្យកម្ពុជាប្រជាធិបតេយ្យ អាចក្លាយជាសម្ព័ន្ធមិត្តជាមួយ សីហនុ។ ហើយកម្ពុជាប្រជាធិបតេយ្យអាចបន្តឋានៈរបស់ខ្លួនក្នុងនាមជាអ្នកតំណាងប្រទេសកម្ពុជានៅក្នុងអាសនៈអង្គការសហប្រជាជាតិ។

[១១:០០:៥៨]

**ស៖** នៅពេលដែលគាត់និយាយអំពី ប៉ុល ពត ជាមនុស្សមិនល្អ។ ថាតើហេតុអ្វីបានជាសហរដ្ឋអាមេរិកនៅពេលនោះចង់ដោះស្រាយជាមួយនឹងបុគ្គលរូបនេះ? គឺបានន័យថាហេតុអ្វីចង់គាំទ្រ ប៉ុល ពត កម្លាំងរបស់ ប៉ុល ពត ទោះបីជាគេដឹងអំពីលក្ខណៈរបស់ ប៉ុល ពត បែបនេះក៏ដោយ។

**ឆ៖** នេះគឺជាផ្នែកចុងក្រោយបំផុតរបស់កម្ពុជា។ សហរដ្ឋអាមេរិក បានគាំទ្រចិនដើម្បីប្រឆាំងជាមួយខាងសហភាពសូវៀត។ សហភាពសូវៀតគាំទ្រវៀតណាម អាមេរិកគាំទ្រចិន ដើម្បីគាំទ្រកម្ពុជាប្រជាធិបតេយ្យ។ ហើយនៅក្នុងការគាំទ្រនេះ សហរដ្ឋអាមេរិក គឺមានការខឹងសម្បាប្រឆាំងវៀតណាម។ ដូច្នេះមិនចម្លែកនោះទេ ក្រោយពេលដែលវៀតណាមឈ្លានពាននិងកាន់កាប់កម្ពុជា សហរដ្ឋអាមេរិក គឺអាចនឹងសហការជាមួយ គឺអាចចូលរួមជាមួយនឹងការប្រឆាំងកម្ពុជា។ នៅពេលនោះគឺថាកម្ពុជាទើបតែងើបចេញពីរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះវាមានបញ្ហាលំបាកទាំងចំណីអាហារ ស្បៀងអាហារក៏ដូចជាកងកម្លាំងជាដើម។ ដូច្នេះវាជាការចូលរួមរបស់ពិភពលោកប្រឆាំងនឹងកម្ពុជា ហើយប្រាកដជាការប្រឆាំងជាមួយនឹងវៀតណាមផងដែរ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់ការសួរសំណួររបស់ខ្ញុំ។ ហើយខ្ញុំសូមប្រគល់វេទិកាជូនទៅខាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន។

[១១:០៣:០១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកស្រី បេកយ័រ ខ្ញុំឈ្មោះ ម៉ារី ហ្គីរូដ៍ ខ្ញុំជាមេធាវី

តំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ យើងតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដែលស្ថិតនៅខាងក្រោយនេះ ដែលមកពីខាងខេត្តតាកែវ និងស្វាយរៀង។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

**ស៖** ខ្ញុំសូមចាប់ផ្ដើមសំណួរ ដែលត្រឡប់មកនិយាយអំពីឯកសារដែលបានលើកឡើងកាលពីព្រឹកមិញដោយការិយាល័យសហព្រះរាជអាជ្ញា ដែលបង្ហាញអំពីសំណើជាច្រើនរបស់លោកស្រី នៅពេលដែលលោកស្រីមកដល់ខែធ្នូ ឆ្នាំ១៩៧៨ គឺមកដល់កម្ពុជាប្រជាធិបតេយ្យ។ ឯកសារនេះគឺឯកសារ E3/1156, ERN ជាភាសាខ្មែរ 00032944, ជាភាសាបារាំង 00807143, ជាភាសាអង់គ្លេស 00524508។ នៅក្នុងសំណើទាំងប្រាំបួន ដែលលោកស្រីបានធ្វើនៅពេលលោកស្រីមកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ នៅលេខប្រាំពីរនោះ "មាននិយាយអំពីការជ្រើសរើសកងទ័ព" គឺលោកស្រីចង់ដឹងអំពីការជ្រើសរើសកងទ័ព។ អ៊ីចឹងលោកស្រីពេលនុ៎ង គឺលោកស្រីស្នើសុំចង់ដឹងអំពីការជ្រើសរើសកងទ័ព។ អ៊ីចឹងមែនទេ?

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** ដូច្នោះមែន។

[១១:០៥:៥៥]

**ស៖** លោកស្រីអាចពន្យល់បានទេថា ហេតុអ្វីបានជាលោកស្រីធ្វើសំណើបែបនេះ លោកកស្រីទទួលបានព័ត៌មានអ្វីខ្លះពាក់ព័ន្ធទៅនឹងការជ្រើសរើសកងទ័ព? ហើយលោកស្រីបានប្រមូលព័ត៌មានអ្វីខ្លះនៅពេលដែលលោកស្រីធ្វើដំណើរមកកម្ពុជា ហើយនិងលោកស្រីបានសម្ភាសមនុស្សមួយចំនួននោះ?

**ឆ៖** បញ្ហាហ្នឹងនោះគឺថា វាមានបញ្ហាពាក់ព័ន្ធទៅនឹងកងទ័ព ដោយសារតែការបោសសម្អាតនៅតាមភូមិភាគមួយចំនួន។ នៅពេលដែលយើងមកដល់មកប្រទេសកម្ពុជា ហេង សំរិន និង ហ៊ុន សែន គឺគាត់បានចូលរួមជាមួយនឹងវៀតណាមរួចទៅហើយ ដើម្បីរៀបចំឡើងដែលយើងមើលឃើញក្រោយមកថាជា"រណសិរ្ស"។ ដូច្នេះគឺបញ្ហានោះគឺថាពួកគេនឹងជួបប្រទះនឹងសង្គ្រាម។ វាមានការបាត់បង់ច្រើន ហើយកងទ័ពមួយចំនួនរត់គេចពីការបោសសម្អាត។ គេរត់ទៅប្រទេសវៀតណាម ហើយមានទាហានកងទ័ពមួយចំនួនស្លាប់នៅក្នុងការប៉ះទង្គិចគ្នា។ តើគេនឹងប្រឈមយ៉ាងម៉េច? វាជាការប្រឈមសមរភូមិមួយដែលវាធ្ងន់ធ្ងរជាមួយនឹងវៀតណាម។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវនេះ ដើម្បីត្រលប់មកនិយាយអំពីចម្លើយមុនរបស់លោកស្រី តើលោកស្រីមានព័ត៌មានដែរឬទេថា ពេលដែលលោកស្រីធ្វើដំណើរ ឬក៏សម្ភាសអំពីរបៀបនៃការដោះស្រាយការបាត់បង់នេះ? ហើយអ្នកណាជាអ្នកជ្រើសរើសកងទ័ពនេះ?

[១១:០៦:៥១]

**ឆ៖** ព័ត៌មានគឺថា វាបានមកដោយផ្ទាល់ជាជាងមើលដោយប្រយោល នៅពេលដែលខ្ញុំនៅជាមួយ ពិន នៅខាងបូព៌ា។ វាបានបង្ហាញឃើញថាទាហាននោះគឺក្មេងៗ។ ខ្ញុំបានថតរូបថតមួយចំនួនបង្ហាញអំពីទាហាន ដោយសារតែអាយុទាហានកងទ័ពនៅពេលនោះគឺថាក្មេងៗមែនទែន។

**ស៖** តើលោកស្រីអាចប្រាប់បានទេថា នៅពេលដែលលោកស្រីនិយាយអំពីទាហានក្មេងៗនោះដែលលោកស្រីបានឃើញលោកស្រីបានថត លោកស្រីអាចផ្តល់ចម្លើយបានទេថាតើក្មេងៗទាំងនោះមានអាយុប៉ុន្មានដែរ បើតាមការសង្កេតរបស់លោកស្រីនោះ?

**ឆ៖** ខ្ញុំស្មានទេ។ ឃើញអ្នកទាំងអស់នោះដូចជាមិនមែនជាក្មេងវ័យជំទង់ទេ។ ខ្ញុំលើកឡើងដូច្នេះដោយសារតែវាពិបាកក្នុងការស្មានអាយុរបស់ពួកគេ។ វាជាការចាប់អារម្មណ៍ វាងាយក្នុងការបង្ហាញអាយុអ្នកដែលធ្វើការនៅតាមកន្លែងផ្សេងៗ ក៏ប៉ុន្តែចំពោះកងទ័ពនេះ វាពិបាកក្នុងការស្មានថាតើគាត់អាយុប៉ុន្មានដែលថាក្មេងៗនោះ?

**ស៖** ដើម្បីបញ្ចប់ទៅលើប្រធានបទនេះ គឺលោកស្រីបានសួរអំពីអាយុរបស់ទាហាន ហើយអ្នកសន្ទនាជាមួយលោកស្រីនោះបានបដិសេធមិនឆ្លើយតបទេ ហើយគាត់ព្យាយាមឆ្លើយពង្វាង។ តើអ៊ីចឹងមែនទេលោកស្រី?

**ឆ៖** ដូច្នោះមែន។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំបន្តទៅលើឯកសារតទៅទៀត។ ឥឡូវខ្ញុំចង់ត្រឡប់មកចំណុចមួយដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិកាលពីព្រឹកមិញនេះគឺចំណុចទី៩ គឺលោកស្រីសំណួមពរចង់ដឹងអំពីប្រជាជនចាម។ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកស្រីចាប់អារម្មណ៍ជាពិសេសនៅសម័យនោះ ទៅលើជនជាតិចាមអ៊ីចឹង? តើលោកស្រីទទួលបានព័ត៌មានអ្វីខ្លះនៅសម័យនោះ មុនពេលលោកស្រីធ្វើដំណើរមកកម្ពុជាពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាមនោះ?

[១១:០៩:២៥]

**ឆ៖** តាមរបាយការណ៍ជនភៀសខ្លួននៅតាមព្រំដែន ជនជាតិចាមគឺយើងឃើញថាមានចំនួនច្រើន

នៅតំបន់ភៀសខ្លួននៅព្រំដែនថៃ-កម្ពុជា។ ជនជាតិចាមមួយចំនួនក៏ត្រូវបានគេកំណត់ដែរ ក្រៅពីជនជាតិចាមនោះ។

**ស៖** ដូច្នេះ បើសិនជាខ្ញុំយល់មិនច្រឡំនោះទេ គឺផ្អែកទៅលើព័ត៌មានដែលលោកស្រីទទួលបានពីជនភៀសខ្លួនដែលលោកស្រីគិតថាបញ្ហាជនជាតិភាគតិចចាមនេះតម្រូវឲ្យមានការស៊ើបអង្កេត។ អ៊ីចឹងមែនទេលោកស្រី?

**ផ៖** ក៏ប៉ុន្តែខ្ញុំមិនបានសម្ភាសជនភៀសខ្លួនដែលជាជនជាតិចាមនៅក្នុងប្រទេសថៃ ដូចដែលអ្នកផ្សេងមួយចំនួនបានធ្វើឡើងនោះទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកស្រីមានប្រតិកម្មតបទៅនឹងសំណួរចម្លើយដែលលោកស្រីបានលើកឡើងកាលពីម្សិលមិញពាក់ព័ន្ធនឹងបញ្ហាព្រះពុទ្ធសាសនា។ ខ្ញុំចង់ប្រើប្រាស់ព័ត៌មានចម្លើយរបស់លោកស្រីកាលពីម្សិលមិញដែលលោកស្រីបានរស់នៅពីរឆ្នាំនៅកម្ពុជានៅពេលដែលចៅក្រមឡាវ៉ែន៍ សួរលោកស្រីនោះ លោកស្រីបានឆ្លើយថា នៅពេលលោកស្រីស្នាក់នៅ លោកស្រីសង្កេតឃើញថា វត្តគឺអត់មានមនុស្សទេ ហើយកាលម្សិលមិញគឺនៅម៉ោង ១៣ និង៣៣នាទី នោះ គឺលោកស្រីថាវត្តហ្នឹង គេយកទៅធ្វើជង្រុកស្រូវ អត់មានមនុស្សទេ។ ហើយនៅពេលដែលលោកស្រីសួរពីបញ្ហានេះគេឆ្លើយថា "គេថាមានការបាត់បង់ទំនុកចិត្ត"។ ខ្ញុំចង់ឲ្យលោកស្រីឆ្លើយទៅនឹងសំណួរពាក់ព័ន្ធទៅនឹងបញ្ហាព្រះពុទ្ធសាសនានេះ។ ខ្ញុំចង់ដឹងថា តើលោកស្រីអាចគិតយ៉ាងម៉េចដែរ នៅមុនឆ្នាំ៧៥ ជាពិសេសផ្អែកលើរយៈពេលពីរឆ្នាំ ដែលលោកស្រីស្នាក់នៅនោះ តើបើតាមលោកស្រីយល់នោះ តើកម្ពុជាប្រជាធិបតេយ្យបានធ្វើយ៉ាងណាពាក់ព័ន្ធនឹងបញ្ហាព្រះពុទ្ធសាសនា ទៅតាមអ្វីដែលលោកស្រីបានសង្កេតឃើញកាលពីឆ្នាំ៧៨ នោះ?

[១១:១១:៤៨]

**ផ៖** អ្វីដែលខ្ញុំលើកឡើងកាលពីម្សិលមិញ ខ្មែរក្រហមគេហៅថា "ពួកប្រតិកិរិយា"។ ចំណុចហ្នឹងគឺថា ខ្ញុំបានលើកឡើងម្តងហើយម្តងទៀត។ ពុទ្ធសាសនាគឺជាប្រតិកិរិយា។ ចំណុចនេះវាជាការគួរឲ្យភ្ញាក់ផ្អើលដោយសារតែយើងដឹងហើយថា ពុទ្ធសាសនាគឺជាផ្នែកផ្លូវការ -- សាសនាផ្លូវការមួយ ហើយយើងឃើញដឹងហើយថា ពុទ្ធសាសនាគឺជាមុខងារដំណើរការនៅក្នុងសង្គម។ ហើយយើងឃើញប្រទេសនេះ ជាប្រទេសពុទ្ធសាសនា។ ដូច្នេះពុទ្ធសាសនាគឺជាជីវិតនៅក្នុងសង្គម។ ដូចថាពីព្រឹកឡើងយើងឃើញព្រះអង្គ ព្រះសង្ឃនិមន្តបិណ្ឌបាត្រ ហើយមានពុទ្ធសាសនាថ្ងៃសម្រាក នៅក្នុងប្រតិទិន

ហើយមានពិធីសាសនាពុទ្ធសាសនា វត្តអារាម ភាសា ក៏ឃើញមានភាសាប្រើប្រាស់តាមបែបពុទ្ធសាសនា។ ដូច្នេះវាពិបាកក្នុងការញែកឲ្យដាច់ណាស់។ ស្ថាប័នពុទ្ធសាសនាគឺជាស្ថាប័នមួយដែលជួយទៅដល់សង្គមនៅក្នុងប្រទេសកម្ពុជា។ យើងឃើញហើយនិមិត្តរូប ស្លាកសញ្ញាផ្សេងៗ យើងមើលនៅក្នុងបន្ទប់សវនាការនេះក៏វាអាចចេញមកពីទ្រឹស្តីនៃពុទ្ធសាសនាផងដែរ។ ដូច្នេះគោលគំនិតមួយដែលគេថា ជាប្រតិកិរិយានោះគឺមិនអាចទៅរួចនោះទេ។ គឺនៅក្នុងសម័យនោះ គេបានឲ្យព្រះសង្ឃលាចាកសិក្ខាបទ។ ហើយគេលុបចោលតែម្តងពុទ្ធសាសនា។

[១១:១៣:៥៣]

**ស៖** សូមអរគុណលោកស្រី។ នៅក្នុងអត្ថបទមួយដែលលោកស្រីសរសេរពាក់ព័ន្ធទៅនឹងទស្សនកិច្ចកាលពីឆ្នាំ៧៨ នេះគឺអត្ថបទនៅក្នុងវ៉ាស៊ីនតោនប៉ុស្តិ៍ ដែលនិយាយថា កម្ពុជាធ្វើ -- មានន័យថា"កម្ពុជាពុះពារដើម្បីឯករាជ្យ ខ្លួនទីពឹងខ្លួន តែត្រូវចំណាយជីវិតមនុស្សដ៏ច្រើន" គឺឯកសារលេខ E3/3391, ERN ជាភាសាអង់គ្លេស 00445257, ជាភាសាខ្មែរ 00703543, ជាភាសាបារាំង 00728919 ។ លោកស្រីសរសេរថា ខ្ញុំសូមដកស្រង់៖ "ខ្ញុំក៏បានឃើញថាវប្បធម៌ព្រះពុទ្ធសាសនាដែលជាមូលដ្ឋានគ្រឹះរបស់កម្ពុជា អស់រយៈពេលរាប់សតវត្សរ៍មកហើយនោះ ត្រូវបានលុបបំបាត់ចោលទាំងស្រុងហើយបញ្ហានេះបានបន្សល់ឲ្យខ្ញុំនូវអារម្មណ៍មួយដែលថា ខ្ញុំបានស្ថិតនៅក្នុងប្រទេសមួយដែលបាត់បង់អ្វីៗដែលកាលគ្រានោះខ្ញុំបានចាត់ទុកជាដួងព្រលឹងរបស់វា។ តើលោកស្រីអាចបញ្ជាក់បានទេថា នេះជាអារម្មណ៍របស់លោកស្រីមែននៅពេលនុះ នៅពេលដែលលោកស្រីធ្វើដំណើរទស្សនកិច្ចមកកម្ពុជានៅខែធ្នូ ឆ្នាំ១៩៧៨ នោះ?

**ឆ៖** ពិតជាដូច្នោះមែន។

**ស៖** សូមអរគុណលោកស្រី បេកយ័រ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកស្រីឆ្លើយតបទៅនឹងសម្តីដែលលោកស្រីបានឆ្លើយកាលពីម្សិលមិញ នៅពេលដែលលោកឆ្លើយទៅនឹងសំណួរមួយចំនួនរបស់ចៅក្រមឡាវែន៍ ។ ជាពិសេសនៅពេលដែលលោកចៅក្រមបាននិយាយនៅម៉ោង ១៣:៣៥:៣៣ វិនាទី ដែលនិយាយអំពីការរៀបអាពាហ៍ពិពាហ៍។ នៅពេលឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍ នៅកថាខណ្ឌ២៣ លោកស្រីថា "ត្រូវទទួលបានការអនុញ្ញាតដើម្បីរៀបការ"។ ខ្ញុំចង់ដឹងថា តើលោកស្រីអាចពន្យល់ឲ្យបានលម្អិតបន្តិចបានទេ ថាអ្នកណាជាអ្នកប្រាប់ដល់លោកស្រី ហើយប្រាប់ក្នុងឱកាសអ្វី? តើជាអ្នកលោកស្រីសម្ភាស ឬក៏ជាអ្នកជាមេដឹកនាំជាន់ខ្ពស់? អ្នកណាជាអ្នកប្រាប់លោកស្រីកាលពី --

ដែលលោកស្រីឆ្លើយកាលបីម្សិលមិញថា នៅពេលចង់រៀបការ ត្រូវទទួលការអនុញ្ញាតនុង់? ការអនុញ្ញាតនុង់ អនុញ្ញាតពីអ្នកណាដែរ?

[១១:១៦:៣០]

**ផ៖** ការអនុញ្ញាត គេបានប្រាប់ -- មេដឹកនាំសហករណ៍បានប្រាប់ខ្ញុំ បញ្ហានេះគឺជាប្រធានបទដែលខ្ញុំលើកឡើងច្រើនលើកច្រើនសាផងដែរនៅពេលនោះ ហើយខ្ញុំគិតថា ប្រសិទ្ធ ក៏បានចូលរួមលើកឡើងពីបញ្ហានេះផងដែរ។ ហើយមេដឹកនាំសហករណ៍ គឺបានលើកឡើងពីបញ្ហាហ្នឹង។ ខ្ញុំមិនអាចប្រាប់ជាក់ស្ដែងជាក់លាក់ ថាតើនៅពេលនោះក្នុងខេត្តណាទេ ដែលអ្នកដែលខ្ញុំទៅជួបនៅតាមសហករណ៍នោះ។

**ស៖** ជាទូទៅ តើបញ្ហារៀបការត្រូវបានលើកឡើងទេ នៅពេលដែលលោកស្រីបានសម្ភាសមួយចំនួនជាមួយមេដឹកនាំជាន់ខ្ពស់នោះ?

**ផ៖** ពិតជាមាន។ បញ្ហានេះ គឺថាយើងជជែកគ្នា ថាតើនៅពេលណាដែលពួកគេត្រូវរៀបការដើម្បីធានានូវកំណើនប្រជាជន ហើយអ្នកណាត្រូវ ឬគួរតែឲ្យរៀបការ។ តើអ្នកដែលរៀបការនោះ គួរតែរស់នៅ ឬក៏មិនគួររស់នៅជាមួយគ្នា។ នេះជាប្រធានបទដែលបានលើកឡើងនាពេលនោះ។

[១១:១៧:៤៧]

**ស៖** សូមអរគុណលោកស្រី បេកឃ័រ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកស្រីឆ្លើយតបទៅនឹងចំណុចបីដែលលោកស្រីលើកឡើង។ លោកស្រីបានធ្វើការផ្សាភ្ជាប់រវាងពេលរៀបអាពាហ៍ពិពាហ៍ នឹងបញ្ហាបង្កើនចំនួនប្រជាជន។ តើខ្ញុំយល់អ៊ីចឹងត្រូវទេនូវចម្លើយរបស់លោកស្រីហ្នឹង? គឺលោកស្រីបានផ្សាភ្ជាប់ចំណុចទាំងពីរនេះចូលគ្នា គឺមានន័យថា ការរៀបការ គឺដើម្បីបង្កើនចំនួនប្រជាជន។ អ៊ីចឹងទេ?

**ផ៖** ខ្ញុំអត់ៗបានភ្ជាប់ទំនាក់ទំនងទេ នៅពេលដែលការជជែករបស់ខ្ញុំនោះគឺថា តើការរៀបការហ្នឹងកើតឡើងដែរឬទេ។ គឺថាបានកើតឡើង ហើយក្រោយមកគឺមានការបង្កើនចំនួនប្រជាជន ហើយពេលណាដែលជាការពេលវេលាល្អឲ្យគេ ឲ្យប្រជាជនរៀបការនោះ។ ហើយគឺថាបានពិភាក្សាគ្នា ហើយគឺក៏គេបានលើកឡើងអំពីការបង្កើនចំនួនប្រជាជនផងដែរ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយពីចំណុចនេះវិញនៅពេលក្រោយ។ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ឲ្យលោកស្រីមានប្រតិកម្មតបទៅនឹងចំណុចពីរដែលលោកស្រីបានឆ្លើយ គឺថាអ្នកណាជាអ្នកត្រូវរៀបការ? អ្នកណាត្រូវរៀបការជាមួយអ្នកណា? ហើយតើគូស្វាមីភរិយាហ្នឹង ត្រូវរស់ រួមរស់

ជាមួយគ្នាទេ? លោកស្រីមានព័ត៌មានអំពីចំណុចទាំងនេះទេ? អ្នកណារៀបការជាមួយគ្នា ហើយតើប្ដីប្រពន្ធដែលរៀបការហ្នឹង គាត់រស់នៅជាមួយគ្នាទេ?

[១១:១៩:២០]

**ផ៖** ក្នុងពេលខ្ញុំមកធ្វើទស្សនកិច្ចក្នុងឆ្នាំ៧៨ៗ ខ្ញុំមិនបានទទួលព័ត៌មានលម្អិតគ្រប់បែបយ៉ាងនោះទេ។ នៅក្នុងឆ្នាំ១៩៧៨ គឺសហករណ៍ជាអ្នកឯកភាពយល់ព្រម ទៅលើការរៀបការ។ គេ -- ពួកគេមិនបានលើកឡើងថា អ្នកណាជាអ្នកសម្រេចអំពីឲ្យរៀបការនោះទេ។ ខ្ញុំបានលើកឡើងថា រៀបការយ៉ាងដូចម្ដេចនោះ គឺខ្ញុំបានលើកឡើងសួរដែរ ដោយសារតែខ្ញុំបានឃើញ ជាពិសេសនៅពេលដែលខ្ញុំដើរទៅក្រៅនោះតែម្នាក់ឯង។ មានក្រុមបុរសមួយចំនួនដែលថា គាត់រស់នៅជាលក្ខណៈជីវិតនៅលីវ ហើយបានឮអ្នក -- បុរសៗនោះ និយាយអំពីការបង្កើនចំនួនប្រជាជន។ ដូច្នេះ ចំណុចនេះវាហាក់ដូចជាផ្ទុយទៅនឹងកន្លែងដែលប្រជាជនបុរសៗនោះ គាត់រស់នៅជាលក្ខណៈជីវិតនៅលីវ។ ដូច្នេះ ដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង ខ្ញុំមិនបាន ទទួលបានព័ត៌មានលម្អិតទៅលើបញ្ហាទាំងអស់នេះនោះទេ។

**ស៖** នេះជាសំណួរមួយទៀតរបស់ខ្ញុំ គឺឲ្យលោកស្រីឆ្លើយតបទៅនឹងអ្វីដែលលោកស្រីបានលើកឡើងកាលពីម្សិលមិញពាក់ព័ន្ធទៅនឹងទស្សនកិច្ច។ មើលអ្នកដែលរៀបការជាប្ដីប្រពន្ធនុំង តើអ្នកណាប្រាប់លោកស្រីនៅពេលនោះ?

**ផ៖** ខ្ញុំមិនអាចប្រាប់ អ្នកណាប្រាប់ខ្ញុំឲ្យបានជាក់លាក់នោះទេ។ ប្រហែលជាអាចប្រាកដនោះប្រហែលជា ប្រសិទ្ធ ជាអ្នកប្រាប់ខ្ញុំ។ ប្រសិនបើខ្ញុំយល់មិនច្រឡំនោះទេ គឺគេឲ្យខ្ញុំ -- គឺការទស្សនកិច្ចរបស់ខ្ញុំនោះ ចំនួនពេលវេលាឲ្យមកខ្ញុំ គឺប្រាប់ខ្ញុំពេលវេលាជាក់លាក់ ឬចំនួនជាក់លាក់ ហើយគេមានវិធានក្រឹត្យក្រមរបស់គេ។ គេប្រាប់ឲ្យខ្ញុំ ហើយខ្ញុំបានកត់ត្រាទុកផងដែរ។ មានបទប្បញ្ញត្តិ ហើយវិធានក្រឹត្យក្រមរបស់គេ គេថាបុគ្គលមួយជាក់លាក់ហ្នឹង អាចមកទស្សនកិច្ចជួបប្ដីរបស់ប្រពន្ធរបស់គេហ្នឹងប៉ុន្មានដងៗក្នុងមួយសប្ដាហ៍ មួយខែជាដើម។

[១១:២១:៤៥]

**ស៖** នៅពេលដែលលោកស្រីនិយាយអំពីច្បាប់អនុញ្ញាតនោះ តើលោកស្រីចង់មានន័យយ៉ាងម៉េចដែរ គឺមាននិយាយពីឯកសារ មានអី គេមានផ្ដល់ឯកសារជាលាយលក្ខណ៍អក្សរអីឲ្យលោកស្រីទេនៅពេលលោកស្រីនិយាយអំពីភាសាអង់គ្លេស *–រូល អេន រីខ្យូឡេសិន?*

**ផ៖** អត់មានឲ្យឯកសារអីមកខ្ញុំទេ ទាក់ទងនឹង ទៅនឹងច្បាប់ និងក្រឹត្យក្រម។ ច្បាប់ និងក្រឹត្យ

ក្រមនេះ គឺគេគ្រាន់តែលើកឡើងថា "អ៊ិច" –បុគ្គលអ៊ិច– នេះអាចមកជួបប្ដីប្រពន្ធប៉ុន្មានដងក្នុងមួយសប្ដាហ៍ ឬក៏មួយខែ ហើយខ្ញុំមិននិយាយអំពីឯកសារច្បាប់ចែងជាក់លាក់នោះទេ។ ហើយគ្រាន់តែខ្ញុំនិយាយពីចម្លើយដែលខ្ញុំបានទទួលពេលនុ៎ង គេលើកឡើងថា "ក្រឹត្យក្រម" គេអ៊ីចឹង។

**ស៖** *(គ្មានការបកប្រែ)*

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកស្រីមេធាវីកុំឲ្យគាត់សួរលឿនពេក ព្រោះថា ចម្លើយមិនទាន់ចប់ផង គាត់សួរអ៊ីចឹង អ្នកបកប្រែបាត់ហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីចាប់ផ្ដើមសួរសាជាថ្មីម្ដងទៀតសំណួរចុងក្រោយ ហើយមុននឹងសួរសូមឲ្យបង្អង់បន្តិច ឲ្យអ្នកបកប្រែបកចម្លើយអ្នកជំនាញឲ្យចប់សិន សឹមចាប់ផ្ដើមបកប្រែ -- ចាប់ផ្ដើមតាំងសំណួរ។ ដូច្នេះ វាជាន់គ្នា មិនទាន់ចប់ផង ហើយលោកស្រីចាប់ផ្ដើមសួរទៀតទៅមានបញ្ហាក្នុងការបកប្រែ។ បាទ សង្ឃឹមថា លោកស្រីនឹងអនុវត្តបានល្អ។ ហើយការអានដូចគ្នាដែរ នៅពេលដែលអានដកស្រង់នូវឯកសារយោង គឺសូមអានឲ្យយឺត ឲ្យបានយឺតៗ ហើយជាការល្អដែលមេធាវីជាតិហ្នឹង ក៏ជួយចាំរំឭកគាត់ផង។

សូមអញ្ជើញបាទ!

[១១:២៣:៣៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សំណួរខ្ញុំអម្បាញ់មិញនេះ គឺពាក់ព័ន្ធទៅនឹងក្រឹត្យក្រម ដែលលោកស្រីបាននិយាយភាសាអង់គ្លេស *រូល អេន រ៉ិខ្យូឡេសិន*។ លោកស្រីបាននិយាយថា ដៃគូសន្ទនារបស់លោកស្រីនុ៎ង បាននិយាយច្បាស់លាស់ចំពោះបញ្ហាមួយចំនួន ក៏ប៉ុន្តែបញ្ហាខ្លះគឺមិនច្បាស់លាស់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើចម្លើយនោះគេប្រាប់លោកស្រីអំពីការរៀបអាពាហ៍ពិពាហ៍ ឬក៏ប្រាប់អំពីប្រធានបទផ្សេងទៀតដែលត្រូវបានជជែកពិភាក្សាគ្នានៅក្នុងពេលដែលលោកស្រីស្នាក់នៅ។ ឧទាហរណ៍លក្ខខណ្ឌការងារ កម្រិតនៃការបង្កបង្កើនផលស្រូវ...។ល។

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** ខ្ញុំមានសរសេរនៅក្នុងជំពូកមួយនៅក្នុងសៀវភៅរបស់ខ្ញុំ ហើយក្នុងនុ៎ង គឺថា ខ្ញុំក៏បានសរសេរថា បុគ្គល "អ៊ិច" នេះទទួលបានប៉ុន្មាន ហើយសិទ្ធិយ៉ាងម៉េចយ៉ាងម៉ាខ្លះនៅក្នុងជំពូកសៀវភៅរបស់ខ្ញុំ។ ហើយអ្នកទាំងអស់នោះហើយដែលគេចាត់ទុកថាជាលក្ខខណ្ឌតម្រូវក្រឹត្យក្រមរបស់គេនោះ។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំមានសំណួរមួយ -- ម៉ុំទៀត។ ខ្ញុំចង់ឲ្យលោកស្រីមានប្រតិកម្មតបពាក់ព័ន្ធនឹងទស្សនទានមួយ លោកស្រីបានលើកឡើងនៅក្នុងសៀវភៅ។ ខ្ញុំសូមនិយាយជាភាសាអង់គ្លេស ពីព្រោះបារាំងដូចជាមិនគ្រប់គ្រាន់។ គឺនិយាយពីកសិករកម្ពុជា -- ទស្សនទានអំពីកសិករកម្ពុជា -- សូមទោស គឺកសិករកម្ពុជា។ តើលោកស្រីអាចនិយាយពីបញ្ហានេះបានទេ – *ខេមបូឌាន ភីហ្សិន?*

**ឆ៖** តើខ្ញុំធ្លាប់ឮពីមុនដែរឬទេ បើខ្ញុំទៅមើលអ្នកទាំងអស់នោះពីមុន។

**ស៖** ដើម្បីឲ្យលោកស្រីឆ្លើយឲ្យបានលម្អិត តើលោកស្រីបានទៅកន្លែងហ្នឹងផ្ទាល់ លោកស្រីបានឮអំពីពាក្យហ្នឹងទេ? ហើយបើឮនោះ តើឮចេញពីមាត់អ្នកណាដែរ?

**ឆ៖** ជាការពិតខ្ញុំធ្លាប់ឮញឹកញាប់ ក៏ប៉ុន្តែខ្ញុំមិនបានកត់សម្គាល់ឲ្យជាក់លាក់ទៅលើបញ្ហាហ្នឹង។

**ស៖** លោកស្រីអាចពន្យល់ពីខ្លឹមសារនៃពាក្យហ្នឹងបានទេ *"ខេមបូឌាន ភីហ្សិន វើកឃ័រ"* មានន័យថាម៉េចដែរ?

[១១:២៦:១៨]

**ឆ៖** តាមខ្ញុំយល់នេះគឺមកពីការដែលខ្ញុំអាន -- មើលឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ។ ឯកសារផ្លូវការក្នុងអំឡុងឆ្នាំទាំងអស់នោះដែលគេបានផ្សព្វផ្សាយ ហើយខ្ញុំបានអានតាមរយៈអត្ថបទហ្វ៊ីប៊ីសផងដែរ ហើយវាជាសញ្ញាណមួយទូទៅ ដែលគេដឹង។ នៅក្នុងប្រព័ន្ធសង្គមដែលមានវណ្ណៈ គឺគេក៏បានគិតពិចារណាអំពីវណ្ណៈអនុធន ហើយនិងវណ្ណៈកម្មករ នៅក្នុងកម្មករ កសិករនេះ គឺយើងឃើញមានវណ្ណៈគេសាមញ្ញទូទៅ។ នេះគឺតាមអ្វីដែលខ្ញុំយល់លើបរិបទហ្នឹង។

**ស៖** ចំពោះលោកស្រីផ្ទាល់នុ៎ង តើពាក្យហ្នឹងនាំឲ្យមានៗ -- បង្កបញ្ហាទៅដល់អត្តសញ្ញាណទេ?

**ឆ៖** ទស្សនទាន បើសិនជាវាតែឯងនោះ គឺវាត្រូវការព័ត៌មានច្រើនលើទស្សនទាននេះ។ ប្រព័ន្ធវណ្ណៈទាំងមូលជាការពិតទៅគឺវាបានលុបបំបាត់នូវភាពឯកជន និងសហ -- ភាពជាសហគមន៍ដែលយើង កំណត់វាថាដូច្នេះ។

**ស៖** តើលោកស្រីធ្លាប់ស្ដាប់ឮទេនៅពេលដែលលោកស្រីសម្ភាសជាមួយមេដឹកនាំនូវការពន្យល់ពាក់ព័ន្ធទៅនឹងភាពបរិសុទ្ធ ឬក៏ភាពស្អាតស្អំផ្នែកជាតិពន្ធុ លោកស្រីធ្លាប់ឮពាក្យហ្នឹងទេ នៅពេលលោកស្រីសម្ភាសហ្នឹង បើសិនជាឮសូមលោកស្រីឆ្លើយពីចំណុចនេះ?

[១១:២៨:៥២]

**ឆ៖** អ្វីដែលខ្ញុំបានស្ដាប់ឮ គឺប្រជាជាតិកម្ពុជាតែមួយ ប្រជាជនកម្ពុជាតែមួយ។ ហើយនេះអ្វីដែលខ្ញុំបានឮ។ ខ្ញុំបានអានច្រើនអំពីភាពស្អាតស្អំជាជាងស្ដាប់ឮពីគេ។ នៅពេលដែលគេសួរខ្ញុំអំពីជាតិ -- ជនជាតិភាគតិចនេះគឺថា គេគ្រាន់តែប្រាប់ថា ជាតិកម្ពុជាតែមួយ ប្រជាជនតែមួយ។

**ស៖** នៅក្នុងសៀវភៅរបស់លោកស្រីៗ សរសេរនូវ ERN ជាភាសាអង់គ្លេស 00237951, ជាភាសាខ្មែរ 00232321, លោកស្រីនិយាយអំពីការចង់ឲ្យបានបរិសុទ្ធនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកស្រីចង់មានន័យថាម៉េចដែរ?

**ឆ៖** គឺក្រោយពេលខ្ញុំស្រាវជ្រាវ ក្រោយកម្ពុជាប្រជាធិបតេយ្យត្រូវបានគេផ្ដួលរំលំ។ ការសិក្សាស្រាវជ្រាវរបស់ខ្ញុំជាមួយនឹងអ្នកផ្សេងគឺវាពាក់ព័ន្ធទៅនឹងការបោសសម្អាតជនជាតិភាគតិច។ ក្នុងនោះខ្ញុំក៏បញ្ចូលកិច្ចសម្ភាសន៍ និងការស្រាវជ្រាវរបស់ខ្ញុំមួយចំនួនផងដែរ ដែលវាពាក់ព័ន្ធទៅនឹងពូជសាសន៍ គឺដែលវាពាក់ព័ន្ធទៅនឹងពូជសុទ្ធខ្មែរ ហើយខ្ញុំលើកឡើងនៅក្នុងជំពូកមួយដែលវាពាក់ព័ន្ធទៅនឹងបញ្ហាចាមនៅក្នុងនោះផងដែរ។

**ស៖** សូមអរគុណលោកស្រី។ លោកប្រធានខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ។

[១១:៣១:៣០]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំគ្រាន់តែចង់ឲ្យអង្គជំនុំជម្រះ និងភាគីបានជ្រាប។ ឯកសារមួយកាលពីម្សិលមិញ។ ខ្ញុំបានអានឈ្មោះបុគ្គលបួននាក់ដែល ប៉ែន យៀវនិន ឲ្យ ម៉ាលខូម ខាដវែល នេះសួរនាំអំពីមុនពេលធ្វើដំណើរមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ៧៩។ ឯកសារ E3129 ក្នុងនោះមានឈ្មោះបុគ្គលបួននាក់នោះ នៅក្នុងលេខរៀង ២, ៥, ៦, ៨ ដែលមានចំណាងជើងថា "ឈ្មោះអ្នកដែលមកពីបារាំងមិនទាន់បានសួរចម្លើយនៅក្នុងឯកសារស-២១"។ នៅក្នុងឯកសារនេះបានលើក

ឡើងថាបុគ្គលម្នាក់ៗក្នុងចំណោមទាំងបួននេះគឺចូលក្នុងស-២១ ថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៧៦។ ដូច្នេះ ខ្ញុំស្នើសុំឲ្យលោក សេង លាង អានឈ្មោះនោះឲ្យចំៗតែម្តង។

**លោក សេង លាង៖**

បាទ នៅក្នុងតារាងហ្នឹងគឺមានលេខ២ ឈ្មោះថា គី គឹមស្រ៊ី, លេខ៥ ឈ្មោះថា ឡាយ រ៉ូសេ, លេខ៦ ឈ្មោះថា អ៊ូ ឡាំ, លេខ៨ ឈ្មោះថា ជី វុធ។ អស់ហើយ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១១:៣៣:៣២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** មុននឹងបញ្ចប់វគ្គនេះ ខ្ញុំចង់បានការបំភ្លឺមួយដើម្បីឲ្យកត់ត្រាក្នុងប្រតិចារឹកសវនាការ។ កាលពីព្រឹកមិញនេះ លោកស្រី បេកយ័រ នៅពេលដែលសហព្រះរាជអាជ្ញាសួរហ្នឹង លោកស្រីនិយាយអំពីសៀវភៅមួយសរសេរដោយជនជាតិខ្មែរដែលចូលព្រៃតស៊ូជាមួយខ្មែរក្រហម។ លោកស្រីបានផ្តល់ឈ្មោះសៀវភៅជាភាសាអង់គ្លេស។ ខ្ញុំមិនដឹងថាបកបារាំងហ្នឹងត្រូវមិនត្រូវទេ អ៊ីចឹង សុំឲ្យលោកស្រីនិយាយម្តងទៀត លោកស្រីនិយាយអំពី "*រីគ្រេត អូហ្វ ឌឺ ខ្មែរ ស្ស៊ូ*"។ សៀវភៅនេះ ប្រហែលជាសរសេរដោយជនជាតិខ្មែរឈ្មោះ អ៊ិត សារិន ហើយលោកស្រីបានលើកឡើងនៅក្នុងសៀវភៅរបស់លោកគឺឯកសារ E3/20, ERN ជាភាសាអង់គ្លេស 00237845, ជាភាសាបារាំង 00638411។ ខ្ញុំមិនមាន ERN ជាភាសាខ្មែរទេ សុំអភ័យទោស។ ក៏ប៉ុន្តែ លោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់ទេថាសៀវភៅហ្នឹងមែនទេ? និយាយអំពី *រីគ្រេត អូហ្វ ឌឺ ខ្មែរ ស?*

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** ពិតជាសៀវភៅហ្នឹងហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោង មួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់អ្នកជំនាញរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយ និងសាមសិបនាទី។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនៅរសៀលនេះវិញឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៦ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម លោកស្រីមេធាវី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំចំណាប់អារម្មណ៍យ៉ាងខ្លាំងជាមួយនឹងចម្លើយរបស់ខ្ញុំ ហើយខ្ញុំមានសំណួរបន្ថែមមួយចំនួន។ សំណួរទី១ របស់ខ្ញុំគឺចង់ដឹងបន្ថែមអំពីសៀវភៅរបស់លោកស្រី។ សៀវភៅរបស់លោកស្រីបោះពុម្ពនៅឆ្នាំ១៩៩៨ គឺការបោះពុម្ពលើកទី២។ ១៩៩៨ បាទ ពិតហើយ។ ចំណែកការបោះពុម្ពលើកទី១ឆ្នាំ១៩៨៦។ តើលោកស្រីអាចប្រាប់យើងខ្ញុំបានទេថាតើការស្រាវជ្រាវចម្បង ឬក៏ការស្តាប់ចម្លើយ

សំខាន់ចុងក្រោយរបស់លោកស្រី គឺធ្វើឡើងនៅឆ្នាំណាដែរ?

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** គឺខ្ញុំគិតថាឆ្នាំ១៩៨៤ គឺប្រហែលជាដើមឆ្នាំ៩០។

**ស៖** តើអាចដែរឬទេ នៅក្នុងខែកក្កដា ឆ្នាំ៩២?

**ឆ៖** ប្រសិនបើនៅក្នុងសៀវភៅហ្នឹង គឺអ៊ីចឹងមែនហើយ។

**ស៖** ថាតើនៅក្នុងចន្លោះឆ្នាំ៩២ និងនៅពេលបោះពុម្ពលើកទី២ ឆ្នាំ៩៨ ហ្នឹង លោកស្រីបំពេញការងារឬក៏លោកស្រីធ្វើការងារអ្វីខ្លះទាក់ទងការសរសេរសៀវភៅនេះ។

**ឆ៖** ខ្ញុំគឺជាអ្នករាយការណ៍ព័ត៌មាន និងជាអ្នកនាយក -- និពន្ធនាយកពេញម៉ោង។

**ស៖** ខ្ញុំចង់សួរអំពីការងារទាក់ទងនឹងសៀវភៅរបស់លោកស្រី?

**ឆ៖** ខ្ញុំសរសេរអត្ថបទដោយឯករាជ្យ ខ្ញុំជាអ្នកសរសេរអត្ថបទឯករាជ្យ គឺជាអ្នកសរសេរអត្ថបទពាក់ព័ន្ធទៅនឹងកម្ពុជា។ ខ្ញុំបានមកប្រទេសកម្ពុជានៅក្នុងឆ្នាំ៩៥ គឺថាខ្ញុំមកកម្ពុជាក្នុងឆ្នាំ៩៥ មុនពេលខ្ញុំបោះពុម្ពសៀវភៅជាលើកទី២ នេះ។

**ស៖** តើលោកស្រីមានធ្វើការស្រាវជ្រាវសំខាន់ណាមួយទាក់ទងទៅនឹងកម្ពុជា ឬក៏ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីសៀវភៅរបស់លោកស្រីនេះដែរឬទេ?

**ឆ៖** ខ្ញុំ -- លោកចង់សួរខ្ញុំក្រោយឆ្នាំ៩៨ មែនទេ?

[១៣:៣៧:៤៨]

**ស៖** ត្រឹមត្រូវហើយប្រសិនបើនេះ។

**ឆ៖** ខ្ញុំបានធ្វើការសម្ភាសន៍នៅពេលក្រោយមែន ប៉ុន្តែគឺខ្ញុំសម្ភាសទាក់ទងទៅនឹងកម្ពុជាសម័យទំនើបហ្នឹង។

**ស៖** តើខ្ញុំអាចនិយាយបានថាការស្រាវជ្រាវជាសំខាន់របស់លោកស្រីគឺនៅមុនពេល គឺថាលោកស្រីធ្វើការស្រាវជ្រាវលម្អិតសំខាន់នៅមុន ឆ្នាំ៨៦ ហើយក្រោយមកទៀតនៅមុនឆ្នាំ៩៨ លោកស្រីបានធ្វើការស្រាវជ្រាវបន្ថែមទៀត។ តើអ៊ីចឹងមែនទេ?

**ឆ៖** សៀវភៅហ្នឹង គឺថាខ្ញុំធ្វើហើយប្រហែលជាឆ្នាំ៩២។

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ដែលថាលោកស្រីមិនបានធ្វើការស្រាវជ្រាវអ្វីសំខាន់នៅក្នុងរយៈពេលប្រហែលជា ២២-២៣ ឆ្នាំ កន្លងមកហ្នឹង?

**ឆ៖** ការស្រាវជ្រាវសំខាន់ៗអត់មានមែន ក៏ប៉ុន្តែខ្ញុំប្រមូលព័ត៌មានបន្ទាប់បន្សំ។

**ស៖** ហេតុផលដែលខ្ញុំសួរលោកស្រីបែបនេះ គឺថាខ្ញុំបានសង្កេតឃើញ មានអត្ថបទបន្ទាប់បន្សំមួយចំនួនអត់មាននៅក្នុងសៀវភៅរបស់លោកស្រីទេ ព្រោះថាអត្ថបទមួយចំនួនធំនោះ គឺនៅក្រោយឆ្នាំ ៩៨។ ខ្ញុំចង់និយាយទៅលើចំនួនពីរ ទី១ គឺរបស់ ស្ទីវិន ម៉ូរេស ជាអ្នកស្រាវជ្រាវអាមេរិក ដែលប្រើប្រាស់ទិន្នន័យភាគច្រើនពីបណ្ណសាររបស់សូវៀត។ ហើយសៀវភៅមួយទៀតគឺ របស់អ្នកសារព័ត៌មានកម្ពុជា និងអ្នកសារព័ត៌មានអាមេរិក គឺ ថេត សម្បត្តិ។ តើលោកស្រីធ្លាប់អានសៀវភៅទាំងពីរក្បាលនេះដែរឬទេ?

[១៣:៤០:០៣]

**ឆ៖** ខ្ញុំដឹងអំពីខ្សែភាពយន្តរបស់ សម្បត្តិ ហើយខ្ញុំជាអ្នកស្នើឱ្យបញ្ចូលនៅក្នុងការប្រកួតប្រជែងដើម្បីពានរង្វាន់ ប៉ុន្តែខ្ញុំមិនបានចាំអំពីសៀវភៅស្រាវជ្រាវរបស់គាត់បានទេ។

**ស៖** សៀវភៅរបស់គាត់ គឺក្រោយឆ្នាំ៩៩ ដូច្នេះហើយទើបលោកស្រីមិនអាចដាក់បញ្ចូលសៀវភៅរបស់គាត់ ទៅក្នុងសៀវភៅរបស់លោកស្រីបាន។

**ឆ៖** តើលោកសួរសំណួរខ្ញុំ ឬក៏អត់ទេ?

**ស៖** ថាតើលោកស្រីមានបានបញ្ចូលសៀវភៅរបស់ ថេត សម្បត្តិ ទៅក្នុងសៀវភៅរបស់លោកស្រីដែរឬទេ?

**ឆ៖** ដោយសារតែយើងនិយាយភាសាអង់គ្លេសដូចគ្នា ទើបខ្ញុំនិយាយលឿន ហើយដូច្នេះខ្ញុំនឹងបន្ថយល្បឿនបន្តិច សូមអរគុណ។

**ស៖** ចំណុចមួយទៀតដែលខ្ញុំចង់សួរ គឺថាខ្ញុំសង្កេតឃើញថា -- ប្រសិនបើខ្ញុំនិយាយខុស គឺកែខ្ញុំផង។ ប៉ុន្តែខ្ញុំសង្កេតឃើញថា មានអត្ថបទតិចតួចដែលចេញប្រភពមកប្រទេសចិន។ គេថាហាក់ដូចជាមានអត្ថបទតិចតួចដែលនិយាយទាក់ទងនឹងការយល់ឃើញរបស់ចិន នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៣:៤១:៤៣]

**ឆ៖** ខ្ញុំគិតថា វាហាក់ដូចជាមិនត្រឹមទេ វាមានអត្ថបទមួយចំនួនអំពី *អាន់ឌ្រិច* ដែលជាការបោះពុម្ពផ្សាយអំពីកម្ពុ -- របស់ចិនអំពីទំនាក់ទំនងចិននៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយសៀវភៅនេះរៀបរាប់លម្អិតអំពីប្រទេសចិនជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ។

**ស៖** ខ្ញុំសូមលើកឧទាហរណ៍ជាក់ស្តែងមួយជូនលោកស្រី ហើយខ្ញុំពិនិត្យមើលសៀវភៅលោកស្រី ហើយមិនមានការនិយាយយោងណាមួយទាក់ទងនឹងរបាយការណ៍សម្ងាត់ ដែលបោះពុម្ពដែលចេញនៅខែមករា ឆ្នាំ៧៩ ដែលព្រាងដោយ ហ្គេង ប៊ីយ៉ាវ *(Geng Biao)*។ អត្ថបទហ្នឹង គឺផ្ទុះបញ្ចាំងពីទស្សនៈរបស់ចិនចំពោះអ្វីដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើខ្ញុំនិយាយអ៊ីចឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវហើយ។

**ប្រធានអង្គជំនុំ៖**

លោក១ លោក វ៉ិចទ័រ កូប៉េ ផ្អាកបន្តិច។ សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៤២:៤៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោក កូប៉េ លោកសួរសំណួរថា ហេតុអីបានជាអ្នកជំនាញមិនសួរពាក់ព័ន្ធនឹងឯកសារ។ គាត់មិនបានបង្ហាញអំពីឯកសារមួយចំនួននៅក្នុងសៀវភៅគាត់ដែលត្រូវបានបោះពុម្ពផ្សាយ។ បញ្ហានោះគឺថា យើងមិនដឹងថាឯកសារហ្នឹងត្រូវបានបោះពុម្ពនៅពេលណាទេ ឯកសារដែលលើកឡើងនោះ។ ប្រសិនបើលោកយោងទៅលើឯកសារណាមួយជាក់លាក់ សូមលោកផ្តល់លេខយោងផង ហើយថាឯកសារនុងបោះពុម្ពនៅឆ្នាំណាខែណាផង។ អ៊ីចឹង យើងមិនដឹងថា លោកសួរសំណួរហ្នឹងវាពាក់ព័ន្ធយ៉ាងម៉េចទេ បើសិនជាលោកមិនឱ្យឯកសារយោងនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចង់និយាយយោងទៅលើឯកសារទូទៅ ប៉ុន្តែឥឡូវនេះ -- ប្រសិនបើនេះ ខ្ញុំនឹងជម្រាបជូន ខ្ញុំនិយាយយោងទៅលើឯកសារ E307/5.2.1, ERN គឺថាមានតែភាសាអង់គ្លេសទេ គឺ01001620 គឺជារបាយការណ៍របស់ ហ្គេង ប៊ីយ៉ាវ អំពីស្ថានភាពនៅក្នុងឧបទ្វីបឥណ្ឌូចិន។ ហើយវាមាននៅលើសំណុំរឿងផងដែរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប៉ុន្តែសៀវភៅហ្នឹងបោះពុម្ពនៅពេលណា? ប្រសិនបើលោកចង់សួរសំណួរ ហេតុអីបានជាលោកស្រីមិនដាក់សៀវភៅនេះចូលទៅក្នុងសៀវភៅរបស់លោកស្រីនុង លោកគួរតែបញ្ជាក់ឱ្យបានច្បាស់អំពីកាលបរិច្ឆេទនៃការបោះពុម្ពសៀវភៅហ្នឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

ចៅក្រម ឡាវែន៍ នៅពេលបើក -- នៅទំព័រដំបូង គឺថាខ្ញុំបានបញ្ជាក់ថា ឯកសារដំបូងត្រូវបានបញ្ចេញដោយប្រភពព័ត៌មានតៃវ៉ាន់ នៅក្នុងខែមករា ឆ្នាំ៨១ ដែលបានបោះពុម្ពផ្សាយ។ ដូច្នេះ ខ្ញុំគិតថា ឯកសារនេះ គឺជាឯកសារឆ្នាំ៨១ ដែលនិយាយយោងនៅក្នុងសៀវភៅ ណាយ៉ាន់ ចាន់ដា និងសៀវភៅរបស់ ស្ទីវិន ម៉ូរេស។ ហើយដើម្បីបញ្ជាក់ឲ្យបានច្បាស់ទៀត សៀវភៅរបស់ ណាយ៉ាន់ ចាន់ដា គឺបោះពុម្ពផ្សាយនៅក្នុងឆ្នាំតែមួយជាមួយនឹងសៀវភៅបោះពុម្ពផ្សាយរបស់លោកស្រី។

[១៣:៤៥:៣០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំមានសំណួរមួយទៀតសាកសួរទៅលើលោកស្រីផងដែរ គឺជាសំណួរបន្តពីខាងព្រះរាជអាជ្ញា។ គឺជាការប្រើប្រាស់សៀវភៅកន្លងមករបស់អ្នកស្រាវជ្រាវ ដូចជា ណាយ៉ាន់ ចាន់ដា, ហេដឌ័រ ហើយខ្ញុំបានកត់ត្រានៅក្នុងសៀវភៅ -- កំណត់ត្រារបស់ខ្ញុំ លោកស្រីបាននិយាយថា "ក្នុងចំណោមក្រុមទាំងអស់នេះ លោកស្រីបានចែករំលែកព័ត៌មានយ៉ាងច្រើន"។ ដូច្នេះ តើលោកស្រីអាចពន្យល់បានដែរឬទេ ថាតើពាក្យដែលលោកស្រីនិយាយចែករំលែកច្រើនហ្នឹង ចង់មានន័យយ៉ាងដូចម្ដេច?

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** គឺថាអ្នកដែលធ្វើការងារជាមួយ -- គឺអ្នកធ្វើការងារទៅលើបញ្ហាហ្នឹង គឺថាបើសិនបើគេស្គាល់គ្នា គេចែករំលែកគ្នាទៅវិញទៅមក។

**ស៖** តើលោកស្រីអាចប្រាប់បានដែរឬទេថា យើងពឹងផ្អែកទៅលើអ្នកស្រាវជ្រាវម្នាក់ឬក៏ច្រើននាក់ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ឧទាហរណ៍ដូចជា ណាយ៉ាន់ ចាន់ដា គាត់ចែករំលែកព័ត៌មានយ៉ាងច្រើនជាមួយខ្ញុំ។ ឧទាហរណ៍ដូចជា ណាយ៉ាន់ ចាន់ដា គាត់ជាអ្នកស្រាវជ្រាវទាក់ទងវៀតណាម គាត់ផ្ដល់ព័ត៌មានជាច្រើនទាក់ទងវៀតណាម។ ចំណែកខ្ញុំជាអ្នកស្រាវជ្រាវពីកម្ពុជា ដូច្នេះខ្ញុំចែករំលែកព័ត៌មានយ៉ាងច្រើន។ ដូច្នេះ ខ្ញុំចង់បញ្ជាក់ថា ខ្ញុំចែករំលែកព័ត៌មានជាមួយ ណាយ៉ាន់ ចាន់ដា ច្រើន។ ចំណែក ប៊ែន ឃៀរនិន គាត់រកឃើញឯកសារមួយអំពីការសម្លាប់ ម៉ាល់ខូម ខាដវែល ហើយចំពោះ ស្ទីវិន ហេដឌ័រ គឺថាគាត់អាចបកប្រែឯកសារជាភាសាខ្មែរបាន។ ហើយ ដេវីដ គាត់ជាអ្នកប្រមូលរូបថតជាច្រើន ដូច្នេះ គាត់ជាអ្នកប្រគល់ រូបថតជាច្រើនឲ្យខ្ញុំឲ្យមើល កាលហ្នឹងវាអាស្រ័យទៅតាមប្រធានបទនីមួយៗ។

**សៈ** សូមអរគុណលោកស្រី។ ឥឡូវនេះ ខ្ញុំចង់បន្តសំណួរបន្ថែមទៀតពីព្រះរាជអាជ្ញា។ នៅក្នុងបរិបទរបស់លោកស្រី គឺមកពីខាងក្រសួងការបរទេស។ នៅក្នុងបរិបទនោះ តើលោកស្រីមានបានជជែកជាមួយអ្នកណាម្នាក់ឈ្មោះ -- ជាមួយបុរសម្នាក់ឈ្មោះ ដាកឃ័រ ស្ប៉ាយ *(Douglas Pike)* មកពីខាងក្រសួងការបរទេសរបស់អាមេរិកដែរឬទេ?

**ឆៈ** ដុកទ័រ ស្ប៉ាយ*(Pike)* គឺជាអ្នកជំនាញខាងវៀតណាម។ ដូច្នេះ ខ្ញុំនិយាយជាមួយគាត់នៅពេលក្រោយរបបកម្ពុជាប្រជាធិបតេយ្យទេ។

**សៈ** តើគាត់មានបានរៀបរាប់ប្រាប់លោកស្រីអំពីសមាជនៅក្រោយ -- នៅពេលក្រោយដួលរំលំដែរឬទេ?

**ឆៈ** ខ្ញុំបាននិយាយជាមួយនឹងខាងសមាជជាច្រើនអំពីបញ្ហានេះ ប៉ុន្តែមិនមែននិយាយជាមួយដុកទ័រ ស្ប៉ាយ នោះទេ។

**សៈ** អ្វីដែលខ្ញុំចង់សួរគឺថា តើលោកមានបានប្រើប្រាស់របាយការណ៍របស់គាត់ដើម្បីសរសេរនូវអត្ថបទមួយចំនួននៅក្នុងសៀវភៅរបស់លោកស្រីដែរឬទេ?

[១៣:៤៨:៥៩]

**ឆៈ** ខ្ញុំបានសរសេរ។ នេះគឺជាប្រភពព័ត៌មានបន្ទាប់បន្សំនៅក្រោយឆ្នាំ៧៩។

**សៈ** ហេតុផលដែលខ្ញុំចង់សួរ គឺថាខ្ញុំអត់មានឃើញនៅក្នុងឯកសារយោងរបស់លោកស្រី។ ប៉ុន្តែ តើលោកស្រីអាចប្រាប់បានឬទេថា ដុកទ័រ ស្ប៉ាយ គាត់មានជំនាញអ្វីពិសេសទាក់ទងនឹងប្រទេសវៀតណាម?

**ឆៈ** ខ្ញុំមិនស្គាល់ពីប្រវត្តិរូបគាត់ឲ្យបានច្បាស់លាស់នោះទេ។

**សៈ** ឥឡូវនេះ យើងបន្តទៅមុខទៀត។ ទៅលើអ្នកសារព័ត៌មានអាមេរិកាំង រីឆាត ឌុដម៉ាន។ លោកស្រីបាននិយាយអំពីគាត់ច្រើនដងរួចមកហើយ តើវាជាការត្រឹមត្រូវដែរឬទេ ដែលថាខ្ញុំអាចនិយាយថាគាត់គឺមនុស្សម្នាក់ គឺជាអ្នកដែលមានជំនាញ ឬក៏ជាអ្នកសារព័ត៌មានដែលមានជំនាញយ៉ាងខ្លាំងនៅក្នុងអំឡុងឆ្នាំ៧៥ហ្នឹង តើជាការត្រឹមត្រូវដែរឬទេ?

**ឆៈ** គាត់ គឺជាអ្នកសារព័ត៌មានដែលមានបទពិសោធន៍ខ្លាំងទាក់ទងទៅនឹងគោលនយោបាយរបស់អាមេរិក។

**សៈ** ឥឡូវនេះ ខ្ញុំគិតថាគាត់អាយុ៩០ឆ្នាំហើយ ហើយគាត់នៅរស់នៅឡើយ។ តើលោកស្រីអាច

ប្រាប់អ្វីបន្ថែមទៀតទាក់ទងទៅនឹងគុណវុឌ្ឍិរបស់គាត់ទាក់ទងទៅនឹងសារព័ត៌មានបានទេ?

**ឆ៖** គាត់មានកេរ្តិ៍ឈ្មោះល្អ ក្នុងការសរសេរសៀវភៅ ហើយគាត់ជាអ្នកសារព័ត៌មានទាក់ទងដែលរៀបរាប់អំពីក្រសួងការបរទេសរបស់អាមេរិក។

**ស៖** ខ្ញុំបានស្រាវជ្រាវតាមហ្គូហ្គល ហើយឃើញថា គាត់ទទួលបានពាន់រង្វាន់ ចច ឡៃហ្វថែមស៍ តើលោកស្រីអាចប្រាប់បានដែរឬទេ តើពាន់រង្វាន់ដែលខ្ញុំនិយាយហ្នឹងវាជាពាន់រង្វាន់អ្វីដែរ? វាមានអ្វីពាក់ព័ន្ធដែរ?

**ឆ៖** នេះគឺជាពាន់រង្វាន់ចំពោះអ្នកសារព័ត៌មាន ដែលទទួលការងារគ្រោះថ្នាក់ គឺពេលនោះកម្ពុជាឆ្នាំ៧៨ គឺជាប្រទេសដែលមានគ្រោះថ្នាក់យ៉ាងធ្ងន់ -- យ៉ាងខ្លាំង។

[១៣:៥១:៣៤]

**ស៖** តើវាជាប្រភេទពាន់រង្វាន់អ្វីដែរ?

**ឆ៖** ចម្លើយពិតហើយ។

**ស៖** ខ្ញុំចង់និយាយបន្ថែមបន្តិចអំពី រីឆាត ឌុដម៉ាន ខ្ញុំមិនប្រាកដថាតើខ្ញុំបានបញ្ជូន -- ខ្ញុំចង់ពិភាក្សាជាមួយលោកស្រី អំពីអត្ថបទមួយដែលគាត់បានសរសេរនៅក្នុងសារព័ត៌មានញូវយ៉កថែម គឺឯកសារថ្ងៃ១៧ ខែសីហា ឆ្នាំ៩០ គឺE307/5.2.16, អង់គ្លេសមានលេខ 01002091។ សំណួរទី១ ដែលខ្ញុំចង់សួរ គឺថាតើលោកស្រីមានបានអានអត្ថបទរបស់គាត់ដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់អាន។

**ស៖** តើលោកស្រីមានមតិ ឬការយល់ឃើញអ្វីជាទូទៅអំពីអត្ថបទរបស់គាត់នោះដែរឬទេ?

**ឆ៖** ខ្ញុំមិនយល់ស្របជាមួយនឹងអត្ថបទនោះ។

**ស៖** លោកស្រីអាចពន្យល់បានទេ ហេតុអ្វីបានលោកស្រីមិនយល់ស្រប ហើយមិនយល់ស្របទៅលើអ្វី?

[១៣:៥៣:១១]

**ឆ៖** ត្រឹមឆ្នាំ៩០ អ្វីៗទាំងអស់ គឺថាមានការបង្ហាញច្បាស់នៅលើសារមន្ទីរទួលស្លែង គេបើកជាសាធារណៈ ហើយគាត់បានលាឈប់ពីការងារតាំងពីយូរណាស់មកហើយ គាត់មិនដែលត្រឡប់មកកម្ពុជាក្រោយឆ្នាំ៧៨ វិញទៀតទេ។ ខ្ញុំពេញចិត្ត ខ្ញុំគិតថា វាជាការល្អដែលគាត់សរសេរ ប៉ុន្តែព័ត៌មានហ្នឹងវាផ្ទុយនឹងអ្វីដែលជាការជាក់ស្តែង។

**សៈ** ប្រសិនបើមិនប្រកាន់ទេ ខ្ញុំនឹងអានអត្ថបទពីរបីជួរនៅក្នុងអត្ថបទនេះ ហើយដើម្បីឲ្យយើងឃើញថា គាត់និយាយដូចម្ដេចខ្លះ។ ចំណងជើងនៃអត្ថបទនេះ ខ្ញុំមិនដឹងថា ជាអត្ថបទរបស់គាត់ ឬក៏អត់នោះទេ ប៉ុន្តែគឺនិយាយថា "ប៉ុល ពត កាចសាហាវពិតហើយ ប៉ុន្តែមិនមែនជាឃាតកសម្លាប់រង្គាលនោះឡើង" ហើយអត្ថបទនេះ បានសរសេរថា "ការស្អប់ ប៉ុល ពត ដោយមិនគិតអ្វីទាំងអស់ ធ្វើឲ្យអាមេរិកមានការផ្លាស់ប្ដូរគោលនយោបាយ ដែលនាំទៅដល់ការបំផ្លាញកម្ពុជាទាំងស្រុងតាមរយៈការឈ្លានពានដោយវៀតណាម"។ បន្ទាប់មកទៀត គាត់បានរៀបរាប់ថា "មុនពេលដែលយើងបោះបង់ចោលនូវសម្ព័ន្ធមិត្ត យើងត្រូវពិនិត្យមើលថា តើមានការស្អប់ខ្ពើមដែរឬទេ ហើយនៅក្នុងសមាជ គឺថា ប៉ុល ពត និងខ្មែរក្រហម គឺមិនមែនជាអ្នកផ្ដល់នូវការសម្លាប់រង្គាលនោះឡើយ ប៉ុន្តែជាអ្នកបង្កឲ្យមានបញ្ហា។ ភស្តុតាងបានបង្ហាញថាគឺរួមមានការមិនយល់ស្របជាមួយគ្នាទៅវិញទៅមក គឺថាវាមានឈ្មោះរបស់ខ្មែរក្រហមនៅក្នុងជំរំប្រជាជនកម្ពុជា ហើយនិងបដិវត្តន៍របស់ប៉ុល ពត ហើយនិងមកពីវៀតណាមដែលបានចូលមកក្នុងប្រទេសកម្ពុជា។ សូមអភ័យទោស តើលោកស្រីយល់យ៉ាងម៉េចដែរចំពោះកថាខណ្ឌទាំងពីរនេះ?

[១៣:៥៥:៥២]

**ឆៈ** អ្វីដែលគាត់សរសេរ គឺវាហួសសម័យរួចទៅហើយ គាត់មិនទាំងបានរៀបរាប់អំពីបណ្ណសារដែលគេរកឃើញនៅពេលដែលវៀតណាមចូលមកប្រទេសកម្ពុជានោះឡើយ។ ដូច្នេះ មិនមានបញ្ហាអ្វីដែលគួរឲ្យកត់សម្គាល់នោះឡើយ ព្រោះថាឥឡូវហ្នឹងយើងមានភស្តុតាងយ៉ាងច្រើន ព្រោះថា ខ្ញុំគិតថាវាមានភស្តុតាងយ៉ាងច្រើនដែលផ្ទុយពីនេះ ហើយសោកស្ដាយដែរដែលគាត់សរសេរបែបនេះ។

**សៈ** សូមអរគុណលោកស្រី។ បន្ទាប់មកទៀត ខ្ញុំនឹងដកស្រង់ការសរសេរចុងក្រោយនៅក្នុងអត្ថបទនេះ គឺជាការសង្ខេបអំពីរបាយការណ៍ វីកឃីរី នៅថ្ងៃនៅខែមករា ឆ្នាំ៧៩ ហើយខ្ញុំសូមដកស្រង់សារជាថ្មីម្ដងទៀត គឺគាត់និយាយអំពីការធ្វើទស្សនកិច្ចរបស់គាត់ ហើយគាត់បានបញ្ជាក់ថា "នៅមានព័ត៌មានដែលខ្ញុំបានទទួលជាច្រើនពីមុនមក ហើយភាគច្រើនគឺជាព័ត៌មានដែលធ្វើឲ្យខ្ញុំយល់ខុស។ បាទដោយបានឃើញប្រជាជនកម្ពុជារាប់រយនាក់ ខ្ញុំបានឃើញថាប្រជាជនភាគច្រើនមានសុខភាពល្អ ភាគច្រើនគឺថាមានទាំងបុរសស្ត្រី កុមារ និងកូនង៉ែតនៅក្នុងដៃ ហើយនិងមានម្ដាយដែលបំបៅដោះកូនយ៉ាងច្រើន។ ខ្ញុំមើលដោយការឈឺចាប់ទៅលើក្បាលពោះ ទៅលើសក់ដែលមានពណ៌ត្នោត ធ្វើការចាប់ពីម៉ោង ប្រាំពីរព្រឹកដល់ម៉ោងប្រាំពីរយប់គឺមិនមែនជាការងារថាមិនសមហេតុផលនោះឡើយសម្រាប់ការប្រមូលផលរោងចក្រ ក៏ដូចខាងឧស្សាហកម្មផលិតឱសថជាដើមឡើយ គឺថាត្រូវបានប៉ះពាល់ដោយសារ

តែការនាំចេញ ហើយខ្ញុំសុំបន្តទៅផ្នែកបន្ទាប់ទៀតគឺ នៅក្នុងឆ្នាំ៩០ គឺជាសេចក្ដីសង្ខេបថា តើលោកស្រីយល់ឃើញយ៉ាងម៉េចដែរចំពោះកថាខណ្ឌនេះ?

**ឆ៖** នេះគឺជាការដែលយើងហៅថារបាយការណ៍ ឬក៏របាយការណ៍ដែលមានប្រភពតែមួយគឺជារបាយការណ៍ដែលឲ្យបុគ្គលតែម្នាក់ធ្វើការសម្រេចថា តើអ្នកណាដែលយើងនិយាយជាមួយ អ្នកណាដែលយើងមិនគួរនិយាយជាមួយ? ហើយនេះគឺជាប្រភពព័ត៌មានដែលទទួលបានតែមួយប៉ុណ្ណោះ តែម្ខាងប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង គឺខ្ញុំមិនឯកភាពជាមួយទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់បង្ហាញជូនលោកស្រីនូវកថាខណ្ឌមួយដែលសរសេរនៅក្នុងឆ្នាំ៩០ ដោយអ្នកស្រាវជ្រាវជនជាតិហូឡង់ គឺសៀវភៅមួយដែលយើងហៅថា "ភ្នែកម្ចាស់" ដែលសរសេរដោយ រូលប៊ឺហ្គ័រ លោកប្រធាន។ គឺឯកសារ E30715.2.17, ERN គឺមានលេខ 01002473 ហើយខ្ញុំគិតថាប្រហែលជាមិនមានការបកប្រែជាភាសាខ្មែរ និងបារាំងនោះទេ។ ហើយជើងទំព័រនៅត្រង់ទំព័រ៥៥២ គឺជាហ្វូតណូតជាភាសាអង់គ្លេស ហើយគាត់បានពន្យល់ថា៖ "តើគាត់វិភាគនិងស្រាវជ្រាវដោយរបៀបណាអំពីក្នុងនាមជាប្រតិភូមកកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ៧៨?"។ ហើយជើងទំព័របានសរសេរដូចតទៅនេះ ខ្ញុំនឹងបកស្រាយ– ឌុតម៉ាន៖ "ហើយតាមទស្សនៈរបស់ខ្ញុំគឺជាអ្នកដែលមកស្រាវជ្រាវដ៏លម្អិត ហើយបន្ទាប់មកទៀតមាន បេកឃ័រ ឆ្នាំ៧៩, ភីតធ័រ ឆ្នាំ៧៨, ស្ពានិក ៧៨...។ល។"

[១៤:00:១0]

តើលោកស្រីយល់ឃើញយ៉ាងដូចម្ដេចដែរអំពីរបាយការណ៍របស់គាត់ទាក់ទងទៅនឹងរបាយ-ការណ៍របស់អ្នកដទៃ រួមទាំងរបាយការណ៍របស់លោកស្រីផងនោះ។

**ឆ៖** ខ្ញុំមិនរិះគន់អំពី ឌុដម៉ាន ទេក្នុងនាមជាមនុស្សដូចគ្នា។ ប៉ុន្តែខ្ញុំជឿជាក់ថារបាយការណ៍របស់ខ្ញុំត្រូវបានគេដកស្រង់ជាច្រើននៅពេលកន្លងមកនោះ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោក វ៉ិចទ័រ កូប៉េ។ សូមអញ្ជើញលោក ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន័។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន័៖**

លោក កូប៉េ ខ្ញុំមិនបានស្ដាប់ឮថា អ្នកណាជាអ្នកនិពន្ធសៀវភៅដែលលោកកំពុងតែនិយាយនេះទេ សូមលោកបញ្ជាក់។

**លោក វិចទ័រ កូប៉េ៖**

គឺអ្នកនិពន្ធមួយឈ្មោះ រូល បឺហ្គ័រ។ ហើយសៀវភៅរបស់គាត់មានចំណងជើងថា "ភ្នែកម្ចាស់" គឺបោះពុម្ពដោយសកលវិទ្យាល័យ ណាមេ។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** លោកស្រី បេកឃ័រ ឥឡូវនេះ ខ្ញុំចង់បន្តទៅមុខទៀត ទាក់ទងទៅនឹងរបាយការណ៍របស់ វីរឆាត ឌុដម៉ាន ដែលគាត់បានសរសេរក្រោយពេលដែលគាត់បានមកកម្ពុជាប្រជាធិបតេយ្យជាមួយ លោកស្រី។ នេះគឺជាការដកស្រង់លម្អិត។ ហើយខ្ញុំចង់ឲ្យលោកស្រីផ្តល់មតិលម្អិតទៅលើចំណុចទាំង អស់នេះ។ លោកស្រី បេកឃ័រ ខ្ញុំ-- លោកប្រធានខ្ញុំចង់និយាយយោង គឺ E3290 ហើយភាសាអង់គ្លេស មានលេខ 00419207 មិនមានឯកសារជាភាសាខ្មែរ និងបារាំងទេ។ ខ្ញុំចង់ដកស្រង់ទំព័រទី៣ គឺនៅជួរ ខាងមុខ ហើយខ្ញុំសូមអានជូនលោកស្រីដូចតទៅនេះ៖ "ទោះបីថាការធ្វើទស្សនកិច្ចអាចចាត់ទុកថាជា ដំណើរទេសចរណ៍ក៏ដោយ ប៉ុន្តែយើងមានការសន្ទនាតិចតួចបំផុតជាមួយប្រជាជនកម្ពុជាទូទៅ ហើយ យើងមិនមានឱកាសជួបជាមួយនឹងមន្ត្រីជាន់ខ្ពស់ណាមួយឡើយ។ យើងមានឱកាសច្រើនក្នុងការសង្កេត មើល ក្នុងចំណោមខេត្ត១១ ក្នុងចំណោមខេត្តកម្ពុជាទាំងអស់"។ ហើយបន្តិចខាងក្រោមមកទៀត គាត់ បានសរសេរដូចតទៅនេះ "ទោះបីជាមានការរារាំងក៏ដោយ ចំពោះសកម្មភាពនិងការពិនិត្យក៏យើងអាច ប្រមូលបានព័ត៌មានសំខាន់ៗទាក់ទងទៅនឹងកម្ពុជាជាលើកដំបូងនៅពេល ចាប់តាំងពីកុម្មុយនីស្តបាន ចូលមកកាន់កាប់អស់រយៈពេលប្រហែលជាបួនឆ្នាំមកនេះ។

តើលោកស្រីយល់ឃើញយ៉ាងម៉េចដែរ ឬក៏តើលោកស្រីឯកភាពដែរឬទេ ជាមួយការសង្កេត ឃើញរបស់លោក ដាច់មិន នេះ។

[១៤:០៣:៥០]

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** ខ្ញុំយល់ស្របថាយើងត្រូវបានគេរិតត្បិត។ ប៉ុន្តែខ្ញុំមិនយល់ស្របជាមួយនឹងគាត់និយាយថា មានឱកាសធ្វើការ -- យើងធ្វើដំណើរទៅតាមខេត្តជាច្រើន។ ប៉ុណ្ណឹងទេអស់ហើយ។

**ស៖** នៅលើប្រធានបទជាក់លាក់នេះ តើលោកស្រីដែលធ្លាប់បាននិយាយទៅកាន់គាត់ទេ ទាក់ទង ទៅនឹងអត្ថបទមួយនេះ?

**ឆ៖** មិនមែនតែជាមួយគាត់ទេ គឺយើងបាននិយាយគ្នាញឹកញាប់នៅតាមទូរទស្សន៍។

**ស៖** តើនៅក្នុងឆ្នាំ៧៩ ឬក៏មិនមែនទេ?

**ឆ៖** ខ្ញុំសូមបន្តទៅការដកស្រង់មួយទៀតគឺ ERN 00419208 ឯកសារតែមួយទេ។ គាត់និយាយថា៖ "ក្នុងពេលជាមួយគ្នានេះ គឺស្ថានភាពរស់នៅគឺថា មានការរីកចំរើនច្រើនសម្រាប់កសិករ ជាពិសេសសម្រាប់ប្រជាជនភាគច្រើនដូចដែលរដ្ឋាភិបាលនេះបានអះអាង។ ហើយគាត់បានតសរសេរថា "កុម្មុយនីស្តថ្មីនៅកម្ពុជា ប៉ុន្តែប្រជាជន មិនមែនធ្វើការរហូតដល់ស្លាប់ ឬក៏អត់ឃ្លានរហូតដល់ស្លាប់ដូចដែលៗគេថានោះទេ។ អ្វីដែលខ្ញុំបានរកឃើញក្នុងរយៈពេលពីរសប្តាហ៍ហើយនៅក្នុងរបប ថ្ងៃនេះខ្ញុំមានឱកាសធ្វើការកត់សម្គាល់ជាច្រើន គឺជីវិតរស់នៅសម្រាប់ការងារដ៏លំបាកសម្រាប់ប្រជាជនកម្ពុជាភាគច្រើន។ ក៏ប៉ុន្តែ មានការរីកចំរើនច្រើនទាក់ទងទៅនឹងបញ្ហាផ្ទះសម្បែង ហើយធានាឲ្យមានម្ហូបអាហារគ្រប់គ្រាន់។ ខ្ញុំមិនបានរកឃើញនូវរូបភាពដែលគេបង្ហាញអំពីជនភៀសខ្លួនដែលគេបានទៅគេចខ្លួននៅប្រទេសថៃនៅពេលមានការឈ្លានពានពីវៀតណាមនោះទេ។ អ្នកធ្វើការកម្មករ កសិករ គឺ ធ្វើការដោយខ្លួនឯងដូចមិនមានការបញ្ជាដោយមានអ្នកយាមកាមបង្ខំឲ្យអ្នកនោះធ្វើការនោះទេ ទោះបីជាមានបុគ្គលមួយចំនួនយល់ផ្សេងពីនេះក្តី"។ នេះគឺជាសម្រង់មួយទៀតពីរបាយការណ៍របស់គាត់ នៅក្នុងខែមករា ៧៩ លោកស្រីមានមតិយោបល់យ៉ាងម៉េចដែរពាក់ព័ន្ធទៅនឹងការកត់សម្គាល់របស់គាត់នេះ?

[១៤:០៦:៣៧]

**ឆ៖** ចាស ការមិនយល់ស្របគ្នាភាគច្រើនរវាង រីឆាត ឌុដម៉ាន និងខ្ញុំ គឺថាគាត់មិនដែលស្គាល់ប្រទេសកម្ពុជាទេពីមុន។ កត្តាដែលគាត់ថាផ្ទះសម្បែងមានការរីកចំរើន គាត់ប្រៀបធៀបទៅនឹង -- មិនបានប្រៀបធៀបទៅនឹងអ្វីទេ។ គាត់ធ្លាប់បានមកប្រទេសកម្ពុជាតែម្តងទេ នៅពេលដែលត្រូវបានគេចាប់ខ្លួននៅក្នុងសង្គ្រាមវៀតណាមនោះ។ យើងធ្វើការពិភាក្សាគ្នាជាទៀងទាត់ ដូចខ្ញុំបាននិយាយ លោកត្រូវដឹងថា យើងបានទៅកាន់កន្លែងគំរូមួយចំនួនតែប៉ុណ្ណោះ ប៉ុន្តែយើងអ្វីដែលយើបានឃើញនោះ គឺថាមិនមានការរីកចម្រើនដូចយើងថានោះទេ។ យើងបានឃើញអ្នកយាមប្រដាប់ទៅដោយអាវុធ គេបញ្ឈប់យើងជាញឹកញាប់ ដោយទាហានប្រដាប់ទៅដោយប្រដាប់អាវុធនោះ។

**ស៖** ខ្ញុំសូមបន្តទៅសម្រង់ផ្សេងៗទៀត។ សំណួរបន្ទាប់គឺ ERN 00419209 ហើយខ្ញុំសូមដកស្រង់ ម្តងទៀតនៅម៉ោងដប់មួយព្រឹក គឺថ្ងៃត្រង់មកដល់កសិករ ដល់ពេលហូបបាយថ្ងៃត្រង់ គឺជាកន្លែងសហករណ៍ហូបរួមគ្នា ក្រោយមកខ្ញុំឃើញមនុស្សជាច្រើនសម្រាកពេលថ្ងៃ ដេកថ្ងៃ ដេកយោលអង្រឹងនៅក្រោមផ្ទះ ហើយយើងក៏ចាប់ផ្តើមធ្វើការនៅម៉ោងមួយរសៀល មិនមានអ្វីគួរសង្ស័យនោះទេ។

ហើយយើងបញ្ចប់ការងារនៅម៉ោងប្រាំល្ងាច នៅទីណាក៏ដោយ នៅតាមទីជនបទ ស្ត្រី កុមារ គឺចាកចេញពីស្រែ បញ្ចប់ការងារបោកខោអាវ បោសសម្អាតផ្ទះសម្បែង ហើយបន្ទាប់មកក៏កាន់ មកកាន់សហករណ៍សម្រាប់បាយល្ងាចទៀត។ កម្មាភិបាលនិយាយថា ការច្រូតកាត់ជួនកាលនៅ ធ្វើនៅពេលយប់នៅពេលណាដែលមានខែភ្លឺ”។ ហើយទំព័រដដែលនេះប្រជាជនកម្ពុជាម្នាក់ថា៖ “បីឆ្នាំជាងនេះ គឺថាមានការរីកចំរើនយ៉ាងច្រើន” គាត់បាននិយាយថាយ៉ាងដូច្នេះ ហើយក៏បាននិយាយអំពីផ្ទះសម្បែងនោះផងដែរ ហើយនៅទំព័រដដែលនេះ លោកស្រី បេកឃ័រ គាត់និយាយ ខ្ញុំសូមដកស្រង់៖ “ខ្ញុំមិនបានឃើញភស្តុតាងណាមួយបង្ហាញថាមានការអត់ឃ្លាននោះទេ។ ប្រជាជនកម្ពុជាទូទៅគឺ នេះទាក់ទងទៅនឹងស្ថានភាពដូចដែលបានលើកឡើង។ ខ្ញុំអាចជម្រាបថាគឺយើងមានកុមារតូចៗ លេងសប្បាយ អ្នកខ្លះស្រាត ឈរ ប្រលែងលេងនៅក្បែរផ្ទះហ្នឹង ហើយមិនមាននិយាយពីរឿងបញ្ហាអត់ឃ្លាន ឬក៏ថា ការអត់អាហារអ្វីនោះទេ។ ខ្ញុំឃើញស្ត្រីខ្លះគឺថាហាក់មានសុខភាពល្អ ប្រជាជនភៀសខ្លួនដែលខ្លះនិយាយថាស្ត្រីខ្លះគឺថាគាត់ក៏មានបញ្ហា គឺថាកើតទៅជាអំពើហឹង្សាហើយនៅទំព័រ បន្ទាប់ គឺ00419208 ទាក់ទងទៅនឹង គឺការរីកចម្រើនយ៉ាងខ្លាំង ពាក់ព័ន្ធទៅនឹងបញ្ហានេះការ -- នៃឈើ។ លោកស្រី តើលោកស្រីមានយោបល់អីទេ ពាក់ព័ន្ធទៅនឹងការកត់សម្គាល់ពិសេសមួយនេះ?

[១៤:១០:៣១]

**ឆ៖** នៅពេលយប់មកដល់ គេមិនដែលឲ្យយើងចេញទៅក្រៅទេ ម៉ោងប្រាំ គឺថាគេមិនឲ្យយើងចេញក្រៅទេ យើងមិនអាចធ្វើការកត់សម្គាល់ទេ។ ខ្ញុំមិនដឹងគាត់និយាយអំពីអ្វីនោះទេ ប៉ុន្តែផ្ទះសម្បែងដែលយើងឃើញនោះ ពីផ្ទះពីរបីនោះ គឺថាជាផ្ទះថ្មី សាងសង់ថ្មី ប៉ុន្តែមិនមានលក្ខណៈល្អដូចផ្ទះសម្បែងពីដើមនោះទេ។ គេនិយាយពីផ្ទះ១០០ខ្នង ដែលយើងឃើញនោះ គឺមិនៗបានផ្ទុះបញ្ហាំងទៅលើផ្ទះរាប់លានខ្នងនោះទេ យើងបានដឹងហើយថាការនាំចេញស្រូវនេះ គឺជាតម្រូវការ។ យើងបានឃើញកប៉ាល់នាំស្រូវចេញមែន ប៉ុន្តែនេះបញ្ជាក់ -- ប៉ុន្តែខ្ញុំមិនបានឃើញថាមានអ្វីរីកចម្រើនគួរឲ្យកត់សម្គាល់ទេ។

**ស៖** ខ្ញុំសូមបន្តទៅប្រធានបទមួយផ្សេងទៀត លោកស្រី បេកឃ័រ ព្រោះវាធ្វើឲ្យខ្ញុំមានលក្ខណៈស្មុគស្មាញច្រើនដោយសារ រីឆាត ឌុដម៉ាន គាត់និយាយអំពីបដិវត្តន៍ ចន កេណ្ណឺឌី ដែលហាក់ដូចជាថាមានលក្ខណៈខុសគ្នាច្រើនរវាងការកត់សម្គាល់របស់គាត់នៅឯអឺរ៉ុបនោះ។ លោកស្រីបាននិយាយថាលោកស្រីមានការនិយាយគ្នាដំបូងឆ្នាំ៧៩ ។ តើលោកស្រីអាចបង្ហាញជូនអង្គជំនុំជម្រះថា ហេតុអ្វីក៏មានលក្ខណៈខុសគ្នាចន្លោះប្រហោងយ៉ាងនេះនៅក្នុងការកត់សម្គាល់របស់លោកស្រី?

[១៤:១២:០៨]

**ឆ៖** ដូចខ្ញុំបាននិយាយហ្នឹង ក៏មិនដែលស្គាល់ប្រទេសកម្ពុជាពីមុនទេ ហើយក្រោយមកទៀត ក៏មិនបានត្រឡប់មកកាន់កម្ពុជាវិញដែរ។ នេះមិនមែនជាលើកទី១ ដែលវាមានកើតឡើងរបៀបហ្នឹង។

**សៈ** ខ្ញុំយល់ចម្លើយរបស់លោកស្រី ក៏ប៉ុន្តែការកត់សម្គាល់ដែលថាក្មេងៗខ្វះចំណីអាហារ ស្លេកស្លាំង មិនមានសុខភាពល្អ គឺមិនតម្រូវឲ្យវាទាក់ទងទៅនឹងការមកស្គាល់ប្រទេសកម្ពុជា ឬទស្សនកិច្ចកម្ពុជាពីមុននោះទេ។

**ឆ៖** យើងមិនបានឃើញភស្តុតាងថាមានក្មេងៗហ្នឹងគឺថាមានជំងឺខ្វះចំណីអាហារ យើងៗឃើញ កុមារមានការស្លេកស្លាំង ឬខ្វះចំណី -- ខ្វះជីវជាតិ យើងៗឃើញមាន។

**សៈ** ខ្ញុំនឹងវិលត្រឡប់មកកាន់ចំណុចនេះវិញ។ លោកស្រី បេកយ័រ ដូចខ្ញុំនិយាយអំពី ដូក្លាស របាយការណ៍ដែលគាត់បានសរសេរនៅមុនសមាជឆ្នាំ១៩៧៨ ខែតុលា ជាមួយរបាយការណ៍ដែលខ្ញុំ មាននៅក្នុងដៃ ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត។ នេះទាក់ទងទៅនឹងជំហរ ហើយនិងតួនាទី របស់វៀតណាម ពាក់ព័ន្ធទៅនឹងកម្ពុជាប្រជាធិបតេយ្យ ជាពិសេសគឺអាស៊ីអាគ្នេយ៍តែម្តង។

គាត់បានសរសេររបាយការណ៍នេះ ដែលតាមខ្ញុំយល់គឺថា ពីសមាជដែលគាត់ឆ្លុះបញ្ចាំងអំពី ជំហររបស់គាត់ ជំហររបស់ក្រសួងការបរទេស ទាក់ទងទៅនឹងបញ្ហានេះ ហើយជារបាយការណ៍មួយ ដែលគួរឲ្យចាប់អារម្មណ៍ណាស់។ ចំណុចមួយដែលគាត់និយាយនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់ គឺដូច ខាងក្រោមនេះ ខ្ញុំសូមដក់ស្រង់ដូចតទៅ។ ហើយខ្ញុំសូមសួរមើល៍ តើលោកស្រីមានប្រតិកម្មយ៉ាងម៉េច ដែរ។ លោកប្រធានឯកសារនេះ គឺ E3/2370។ ខ្ញុំយោងទៅ ERN ជាភាសាអង់គ្លេស 00187396។ ខ្ញុំគិតថា មានការបកប្រែតែជាភាសាបារាំងប៉ុណ្ណោះ។ ERN ជាភាសាបារាំង 00344747។

[១៤:១៥:០៥]

នេះជាសេចក្តីសន្និដ្ឋានគាត់បានដាក់ជូនទៅសមាជ។ ខ្ញុំសូមដកស្រង់៖ “កុម្មុយនីស្តវៀតណាម បានគិតគូរអំពីបញ្ហាសហព័ន្ធឥណ្ឌូចិនសម្រាប់ឧបទ្វីបមួយនេះ។ ជាការចាំបាច់ វាតម្រូវឲ្យកម្ពុជា ឡាវ ឬក៏យ៉ាងហោចណាស់ ក៏ត្រូវមានមេដឹកនាំណាមួយសម្រាប់ប្រទេសណាទាំងពីរក្នុងការបង្កើតសហព័ន្ធ ឥណ្ឌូចិន គឺវៀតណាមយល់អំពីបញ្ហានេះ”។ នេះជាផ្នែកមួយនៃសេចក្តីសន្និដ្ឋានរបស់គាត់។ ខ្ញុំសូមយឺត បន្តិចដោយសារបញ្ហាបកប្រែ។ ខ្ញុំសូមដកស្រង់ម្តងទៀត៖ “ប្រធានាធិបតី បរឌី វ៉ីរ គាត់ឃើញសញ្ញាណ នៃទំនាស់រវាងកុម្មុយនីស្តនៅក្នុងឆ្នាំ១៩៧០ ភាគីទាំងពីរមិនអាចត្រូវបានរិះគន់ថាអ្នកណាម្នាក់ជាអ្នកៗ

ញុះញង់នោះទេ”។ ហើយគាត់បន្តនិយាយថា សូមដកស្រង់៖ “ឥរិយាបថកម្ពុជានៅក្នុងសង្គ្រាមមិនមែនជាការរើសអើងប្រកាន់ដូចដែលការចោទប្រកាន់នោះទេ។ នេះវាជាយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជាទាក់ទងទៅនឹងប្រវត្តិសាស្ត្រកម្ពុជា”។ ហើយផ្នែកចុងក្រោយនៃសេចក្តីសន្និដ្ឋានរបស់គាត់ ខ្ញុំសូមសួរលោកស្រីផងដែរ ខ្ញុំសូមដកស្រង់៖ “អនាគតនៃសង្គ្រាមនោះគឺត្រូវតែយកមកពិចារណា មានន័យថាធ្វើម៉េចឲ្យមានស្រូវយ៉ាងច្រើន ក្រោយពីសង្គ្រាមមក។ ហើយជាលទ្ធផល កម្ពុជាក្លាយទៅជារដ្ឋមួយជាអតិថិជនសម្រាប់ប្រទេសវៀតណាម”។ ខ្ញុំសូមអធ្យាស្រ័យដោយសារថាមានសម្រង់ច្រើនពេកនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់នេះ ប៉ុន្តែដោយសារថាលោកស្រីជាអ្នកជំនាញទៅលើផ្នែកនេះ ខ្ញុំយល់ឃើញថាលោកស្រីអាចយកសម្រង់ទាំងអស់នេះមកពិចារណារួមគ្នា ហើយថាតើមានប្រតិកម្មយ៉ាងដូចម្តេចដែរ?

[១៤:១៧:៤២]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

នេះគ្រាន់តែជាសេចក្តីផ្តើមទៅនឹងសំណួររបស់លោក កូប៉េ គាត់បង្ហាញនូវឯកសារមួយនេះ ហើយគាត់និយាយថា វាឆ្លុះបញ្ចាំងអំពីទស្សនៈនៃជំហររបស់ក្រសួងការបរទេសអាមេរិក។ នេះបញ្ជាក់ថាមិនត្រឹមត្រូវទេ។ មិនមែនគ្រាន់តែជាសាធារណជនដែលត្រូវធ្វើឲ្យយល់ខុសបែបនេះនោះ វាបញ្ជាក់ថាការសិក្សាគឺត្រូវ ដូក្លាស ផាយ *(Douglas Pike)* ដែលគាត់ជាអ្នកព័ត៌មានអន្តរជាតិ ជាការសិក្សាស្រាវជ្រាវរបស់សមាជមួយ។ ការរកឃើញហ្នឹងបង្ហាញឲ្យឃើញថា ទោះបីជា លោក ផាយ *(Pike)* តែប៉ុណ្ណោះ តែមិនមែនឆ្លុះបញ្ចាំងនូវសមាជិកនៃគណៈកម្មាធិការដែលឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ក្រសួងការបរទេសអាមេរិកនោះទេ។ ហើយឯកសារនេះផ្ទាល់ បើយើងមើលទៅក្នុងការរកឃើញសំខាន់ៗ នៅត្រង់ទំព័រ៦ និយាយអំពី កម្ពុជា-វៀតណាម ដែលលើកឡើងអំពីប្រភពពីរ ខៀវ សំផន ហើយនិងកម្មាភិបាល គឺឯកសារនេះបានមកពីកម្ពុជាប្រជាធិបតេយ្យ នេះគឺជាប្រភពដែលលោក ផាយ គាត់បានដកស្រង់។

[១៤:១៩:១៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** វាជា លោក ផាយ *(Pike)* ធ្លាប់ធ្វើការឲ្យក្រសួងការបរទេស ហើយក៏ជាសាស្ត្រាចារ្យផ្នែកខាងប្រវត្តិសាស្ត្រផងដែរ។ សម្រង់ដែលខ្ញុំបានឮហ្នឹងគឺ មិនមែនជាយោបល់ឬក៏ទស្សនៈរបស់សភាអាមេរិកនោះទេ។ ក៏ដោយសារថាយើងនិយាយជាមួយនឹងអ្នកជំនាញ ខ្ញុំយល់ឃើញថាលោកស្រីបេកឃ័រ អាចនឹងឆ្លើយទៅនឹងសំណួររបស់ខ្ញុំបាន។

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** សូមអរគុណ។ កាលណានិយាយអំពីសហព័ន្ធឥណ្ឌូចិន ហើយវៀតណាមមានបំណងយ៉ាងណាយ៉ាងណើ ដូក្លាស ផាយ ពេលដែលគាត់ធ្វើការជាអ្នកកាសែត គាត់ៗសិក្សាអំពីទ្រឹស្តីដែលបង្ខំឲ្យសហរដ្ឋអាមេរិកធ្លាក់ចូលទៅក្នុងសង្គ្រាម មិនមែនតែក្នុងវៀតណាមហើយនិងកម្ពុជាទេ នៅក្នុងអាស៊ីអាគ្នេយ៍តែម្តង។ ខ្ញុំសរសេរយ៉ាងច្រើនអំពីបញ្ហានេះ ហើយយើងបានបង្ហាញនូវលក្ខណៈខុសគ្នា។ មិនមាន ជាពិសេសក្រសួងការបរទេសនៅត្រង់ចំណុចនេះ គឺលោក ផាយ ខ្លួនឯងផ្ទាល់ ក្នុងសមត្ថភាពផ្ទាល់ខ្លួនរបស់គាត់។ លោក ឌុដម៉ាន និងក្រសួងការបរទេសប្រាប់ខ្ញុំ គេសង្ស័យថា វៀតណាម និងបញ្ឆប់ ហើយនិងដកថយក្រោយទៅវិញ ហើយចំណុចចុងក្រោយមកទៀតពាក់ព័ន្ធ -- គេនិយាយអំពីការពួនស្ទាក់នៅក្នុងសង្គ្រាមដែលបង្ហាញថា ចិន កុម្មុយនីស្តរុស្ស៊ី ហើយនិងកុម្មុយនីស្តនៅសហព័ន្ធឥណ្ឌូចិន គេចង់ឲ្យ -- គេថា ហូជីមិញ អាចនឹងធ្វើបែបនេះបាន ដើម្បីៗគ្រប់គ្រងទៅនឹងបញ្ហានេះបាន។

[១៤:២១:៣៤]

**ស៖** ខ្ញុំនិយាយអំពីទស្សនទានរបស់កុម្មុយនីស្តឥណ្ឌូចិននៅពេលក្រោយ បើខ្ញុំយល់លោកស្រីមិនច្រឡំទេ គឺសូមឲ្យលោកស្រីបញ្ជាក់មានប្រតិកម្មទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានដែលខ្ញុំលើកបង្ហាញនេះ។

**ឆ៖** លោកអានច្រើន។ គាត់ស្មានៗរឿងមួយជាច្រើន នៅក្នុងផ្នែក ក, ផ្នែក គ។ ចំណុចមួយដែលថាកម្ពុជាមិនមានបញ្ហានៃការរើសអើងណាមួយដោយភាគីណាមួយទេ។ យើងបានចង្អុលបង្ហាញហើយថា សង្គ្រាមនៅតាមព្រំដែននេះ គឺថាបន្តមានយូរមកហើយ។

**ស៖** ត្រឹមត្រូវហើយ ខ្ញុំអានសេចក្តីសន្និដ្ឋានច្រើន។ កុម្មុយនីស្តវៀតណាម គឺថាបានគិតគូរអំពីបញ្ហា គឺជាគោលបំណងផ្នែកខាងនយោបាយរបស់វៀតណាមពាក់ព័ន្ធទៅនឹងកុម្មុយនីស្តឥណ្ឌូចិន។ នេះជាសេចក្តីសន្និដ្ឋានដែលគាត់បានធ្វើឡើង។ តើសេចក្តីសន្និដ្ឋាននេះជាសេចក្តីសន្និដ្ឋានត្រឹមត្រូវ ឬសន្និដ្ឋានមិនត្រឹមត្រូវទេ។

**ឆ៖** ខ្ញុំ -- គឺខ្ញុំមិនគិតថាវាជាគំនិតយោបល់ត្រឹមត្រូវនោះទេ។ ដូចខ្ញុំបាននិយាយហើយ មិនមានអ្នកណាម្នាក់ជឿជាក់មុតមាំថាធ្វើសង្គ្រាមដើម្បីមកលេបត្របាក់កម្ពុជានោះទេ។ ខ្ញុំយល់ថាលោកមិនអាចនិយាយបែបនេះបានទេ។

**ស៖** លោកស្រីនិយាយថា ដូក្លាស ផាយ គឺជាអ្នកមួយសំខាន់ណាស់ក្នុងការបង្កើតនូវទ្រឹស្តីមួយនេះ។ គាត់ គឺជាម្នាក់មួយ -- មនុស្សម្នាក់មួយដែលអាចជាទស្សនៈរបស់ខាងផ្នែកក្រុមអភិរក្ស ដែលក្នុងឆ្នាំ៧៨ គឺគាត់ធ្វើសេចក្តីសន្និដ្ឋានផ្ទុះបញ្ច្រាំងអំពីបញ្ហាវៀតណាមក្នុងឆ្នាំ៧៨។ ហេតុអ្វីបានលោកស្រីថាគាត់ខុស ហើយលោកស្រីខ្លួនឯងថាលោកស្រីត្រូវ?

**ឆ៖** គាត់អត់មានយកស្អីមកអះអាងទេ។ ខ្ញុំគ្រាន់តែនិយាយគាត់គ្មានអីយកមកអះអាង ហើយគាត់មិនមាន -- មិនបានអះអាងទៅលើអ្វីមួយមែន។

**ស៖** អ្នកសិក្សាស្រាវជ្រាវតែងតែមានការអះអាងហើយ អាចដោយសារតែបញ្ហានេះ ប្រភពដែលយកមកអាចមាននៅក្នុងបណ្ណសារ ដូចជារបស់វៀតណាមខ្លួនឯងផ្ទាល់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

[១៤:២៥:០២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងខ្ញុំមិនឲ្យលោកផ្តល់សក្ខីកម្មទេ លោកមេធាវីការពារក្តី សូមឲ្យលោកសួរសំណួរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ខ្ញុំយល់ស្រប យើងកំពុងពិភាក្សាជាមួយអ្នកជំនាញ។ ចុះសេចក្តីសន្និដ្ឋានផ្សេងៗទៀតពីសំណាក់ ដូក្លាស ផាយ។ ឧទាហរណ៍ដូចជាសំណួរសួរថា តើកម្ពុជាប្រជាធិបតេយ្យ ឥរិយាបថរបស់កម្ពុជាប្រជាធិបតេយ្យមានបញ្ហារើសអើងប្រឆាំងទៅនឹងវៀតណាមទេ?

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** សង្គ្រាមបង្ហាញបញ្ជាក់ឲ្យច្បាស់ដែរថា ក្រសួងការបរទេសគឺថា ធ្វើអីចឹងមិនមានន័យទេ។ កិច្ចសម្ភាសន៍ ប៉ុល ពត ជាមួយ វីឆាត ឌុដម៉ាន ហើយនិងខ្ញុំគឺថាវាមានមូលហេតុ។ គាត់មានយោបល់ថា គាត់កសាងគោលនយោបាយបរទេសរបស់គាត់ ហើយគាត់ថា ណាគួនឹងចូលមកជាមួយនឹងកម្ពុជា។

**ស៖** តើវៀតណាមបានចូលចុះកិច្ចព្រមព្រៀងជាមួយនឹងកិច្ចព្រមព្រៀងលើសង្គ្រាម ទៅនឹងសហភាពសូវៀតដែរឬទេ? ដោយសារតែវត្តមានរបស់មេបញ្ជាការជាន់ខ្ពស់របស់សូវៀតនៅមុនសង្គ្រាមនៅមុនវៀតណាម តើលោកស្រីដឹងថាមានចុះកិច្ចព្រមព្រៀងជាមួយរុស្ស៊ីទេ?

**ឆ៖** ជាការពិតហើយ ដែលថាកិច្ចព្រមព្រៀងសូវៀត និងវៀតណាមគឺជាកិច្ចព្រមព្រៀងមួយដែលបង្ហាញនូវការងើបឡើង ហើយនេះដោយបង្ហាញនូវការបាក់បែករបស់សូវៀតនោះផងដែរ គឺថាមានទីប្រឹក្សាសូវៀតនៅក្នុងប្រទេសវៀតណាម ហើយមានទីប្រឹក្សាចិននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយអ្នកទាំងនេះបានយល់ឃើញអំពីបញ្ហាកងទ័ពណាតូ និងកិច្ចព្រមព្រៀងកងទ័ពសូវៀតនេះ។ តើលោកស្រីអាចបង្ហាញជូនអង្គជំនុំជម្រះនិយាយអំពីការបោះពុម្ពផ្សាយណាមួយរបស់ ជាពិសេសឯកសារខ្មៅរបស់កម្ពុជាប្រជាធិបតេយ្យ ឬក៏សារព័ត៌មានអន្តរជាតិដែលថា ប៉ុល ពត ឬក៏របបកម្ពុជាប្រជាធិបតេយ្យគិតថាកងទ័ពណាតូនឹងមកចូលរួមប្រយុទ្ធនោះ ហើយលើសពីនេះទៅទៀត ហេតុអ្វីក៏លោកស្រីមិនពន្យល់ឲ្យបានលម្អិតបន្តិចនៅក្នុងរបាយការណ៍នេះ?

**ឆ៖** ទី១ ដោយសារវាមានមូលហេតុច្រើនណាស់ អ្នកខ្លះគេយកចេញពីសៀវភៅរបស់ខ្ញុំ។ ប៉ុល ពត បាននិយាយ ហើយខ្ញុំបានផ្ដល់ជូន។ ខ្ញុំមិនអាចឆ្លើយជួសលោក ឌុងម៉ាន បានទេ ខ្ញុំឆ្លើយសម្រាប់តែខ្លួនខ្ញុំទេ។

**ស៖** ចុះចំពោះការបោះពុម្ពផ្សាយឯកសារខ្មៅនោះយ៉ាងដូចម្ដេចដែរ?

**ឆ៖** នេះគឺក្រសួងការបរទេសដែលគេបង្ហាញមកយើងមុននឹងទៅជួប ប៉ុល ពត។ លោកអាចសួរទៅរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** ចំពោះកងទ័ពណាតូវិញ ថាតើពាក់ព័ន្ធទៅនឹងបញ្ហាណាតូ លោកស្រីអត់ទាន់ឆ្លើយ។ នេះដោយសារបាត់បង់នូវការបកប្រែ ឬក៏យ៉ាងម៉េច?

[១៤:២៨:៣៨]

**ឆ៖** តើលោកមាន--

**ស៖** ខ្ញុំៗសួរថាអ៊ីចេះ! ប្រហែលជាដោយសារការបកប្រែទៅធ្វើឲ្យលោកស្រីយល់មិនបានច្បាស់។ នៅទីនេះគឺថាវាអាចមានការបាត់បង់យ៉ាងដូច្នេះ។ ប្រហែលជាមានការបាត់បង់ដោយសារការបកប្រែដូចខ្ញុំបញ្ជាក់ហើយ។

**ឆ៖** ការបកប្រែគឺផ្ដល់ឡើងដោយ ជួន ប្រសិទ្ធិ, អៀង សារី, គាត ឈន់។ ខ្ញុំយល់ថាមិនមែន

ដោយសារការ មិនមែនជាមួយនឹង ប៉ុល ពត ទេ គឺជាមួយនឹងអ្នកបកប្រែទាំងនេះ។

**ស៖** ខ្ញុំមិនត្រូវការស្មាន តើ ប៉ុល ពត និយាយថាដូចម្តេចទេ ប៉ុន្តែ លោកស្រីអាចឆ្លើយបាន ចំពោះជម្លោះរវាងវៀតណាម និងកម្ពុជា ហើយបញ្ហាសន្តិភាពនៅឯសហរដ្ឋអាមេរិកពីសំណាក់រដ្ឋអាមេរិក ហើយនិងកិច្ចព្រមព្រៀងជាមួយនឹងសូវៀតនោះ?

**ឆ៖** គឺទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងចិនគឺរឿងមួយសំខាន់ណាស់។? គឺអឺរ៉ុប ណាតូ គឺមិនពាក់ព័ន្ធអីទេ។ បញ្ហាសំខាន់គឺ ចិន និងសូវៀត ជាពិសេស នៅឯទីលានក្រហម ទីលានហាមែន។

**ស៖** នៅក្នុងឆ្នាំ១៩៨៩?

**ឆ៖** --

**ស៖** ខ្ញុំដូចជាបាត់ចម្លើយរបស់លោកស្រី មិនបានពេញលេញ។

**ឆ៖** លោកសួរអំពីបញ្ហាណាតូ ខ្ញុំថាសំខាន់បំផុតគឺ ចិនហ្នឹង ហើយវាបន្តរហូត បញ្ហាហ្នឹងបន្តរហូតទៅដល់ទីលានហាមែនឯនោះ។ បញ្ហា១ចំពោះកម្ពុជាហ្នឹង គឺជាបញ្ហារវាងអាមេរិកហើយនិងចិន មិនមែនណាតូនោះទេ។

**ស៖** ខ្ញុំនិយាយអំពីសង្គ្រាមនៅព្រំដែនរវាងវៀតណាមនិងកម្ពុជា គឺនៅក្នុងឆ្នាំ១៩៧០ ដែលមានមូលហេតុ -- ដោយសារបណ្តាលមកពីមូលហេតុជាច្រើន តើលោកស្រីយល់ស្របយ៉ាងម៉េចចំពោះបញ្ហានេះ?

**ឆ៖** នៅក្នុងឆ្នាំ១៩៧០ បញ្ហាកែប្រែច្រើននៅតាមព្រំដែន គឺនៅពេលដែលសហរដ្ឋអាមេរិកគាំទ្ររដ្ឋប្រហារ ប្រឆាំងនឹងសម្តេច សីហនុ ហើយកងទ័ពកុម្មុយនីស្តវៀតណាមមកពីខាងជើង ហើយទាហានមកពីខាងត្បូងដែលសំដៅ -- គេឆ្លងកាត់ប្រទេសនេះតែម្តង។ ហើយកងទ័ពកុម្មុយនីស្តវៀតណាមបានធ្វើការវាយប្រហារប្រឆាំងជាមួយនឹងទាហាន លន់ នល់។ ដូច្នេះកងទ័ពខ្មែរក្រហមអាចកសាង អាចបំពាក់អាវុធ។ អ៊ីចឹងក្រោយមក គេអាចនឹងធ្វើការប្រយុទ្ធដោយខ្លួនឯងបាន។ នេះគឺជាការកែប្រែយ៉ាងខ្លាំងរវាងទំនាក់ទំនាក់សហរដ្ឋអាមេរិក ហើយនិងជាមួយនឹងចិន -- សុំទោស សហរដ្ឋអាមេរិកជាមួយនឹងកម្ពុជា។ គឺជាការគួរឲ្យភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលថាកុម្មុយនីស្តវៀតណាមនោះ គឺគេចង់ការឃោសនា គេចង់ -- មួយការឃោសនា ហើយគេធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជាតែម្តង។

[១៤:៣២:១២]

**ស៖** ខ្ញុំចង់សួរសំណួរនេះបន្តដែរ ប៉ុន្តែខ្ញុំចង់តាំងសំណួរទៅមុខទៀតទៅចុះ។ យើងនិយាយអំពី

ទស្សនទានរបស់សហរដ្ឋអាមេរិក ហើយនិងមហិច្ឆតារបស់វៀតណាមពាក់ព័ន្ធទៅនឹងសហព័ន្ធឥណ្ឌូចិន។ ឥឡូវនេះ ខ្ញុំសូមអានជូនលោកស្រីមួយ ដកស្រង់ប្រភពចេញមកពីបណ្ណសារដែលយើងបានពិភាក្សាគ្នាពីខាងដើម គឺសៀវភៅសរសេរដោយ ស្ទីហ្វិន ម័រ មានចំណងជើងថា "ហេតុអ្វីបានជាវៀតណាមឈ្លានពានកម្ពុជា?" ជាពិសេស គឺដូច្នេះលោក បេកយ័រ គឺទំព័រ៦៦ នៃសៀវភៅនេះគឺ E307/5.2.4, ERN ជាភាសាអង់គ្លេស 01001733 គឺដកស្រង់សម្ដីរបស់ឯកអគ្គរដ្ឋទូតសូវៀតប្រចាំនៅ វៀតណាមខាងជើង។ ខ្ញុំសូមអានជូនលោកស្រីដូចតទៅនេះ។ ខ្ញុំសូមអានយឺតៗដើម្បីកុំឲ្យ -- មានការបកប្រែទៅបានងាយស្រួល។ "នេះមិនមែនមានន័យថា ហាណូយបានបោះបង់នូវមហិច្ឆតារបស់ខ្លួនទាំងស្រុងពាក់ព័ន្ធទៅនឹងបញ្ហាឥណ្ឌូចិនទេ។ ជាពិសេសនៅក្នុងឆ្នាំ១៩៧៣ ឯកអគ្គរដ្ឋទូតសូវៀតនៅខាងវៀតណាមខាងជើងបានបញ្ជាក់ថា នេះគឺជាគោលបំណងរបស់ទីក្រុងហាណូយហើយ"។ ហ្នឹងគឺជាការដកស្រង់ពីសម្ដីរបស់ឯកអគ្គរដ្ឋទូត។ បញ្ហាសម្រាប់ឥណ្ឌូចិនហ្នឹងគឺ បង្ហាញអំពីទស្សនៈរបស់សៃហ្គនមកលើរឿងចន្ទន៍កម្ពុជា។ ហើយក្រោយមកគឺ ឡាវ និងវៀតណាម ក៏បានធ្វើដំណើរនៅលើមាគ៌ាទៅកាន់របបសង្គមនិយមដូចគ្នា។ មូលហេតុនៃបញ្ហាសង្គមនិយមវៀតណាម គឺគេចង់គ្របដណ្ដប់ទៅលើកុម្មុយនីស្តឥណ្ឌូចិននេះតែម្ដង។ នៅក្នុងឆ្នាំ១៩៧៣ គឺថាសូវៀតនៅតែយល់ឃើញថា គោលនយោបាយវៀតណាមទាក់ទងទៅនឹងការបង្កើតសហព័ន្ធឥណ្ឌូចិនហ្នឹង គឺជានៅតែជាមហិច្ឆតារបស់វៀតណាម។ លោកស្រីមានប្រតិកម្មយ៉ាងដូចម្ដេចដែរ?

[១៤:៣៤:៤៦]

**ឆ៖** ខ្ញុំគ្មានអ្វីគួរភ្ញាក់ផ្អើលទេ គឺថា អាស្រ័យទៅលើអំឡុងពេលរបស់វានោះ។ តើមនុស្សផ្សេងគ្នា យល់ផ្សេងគ្នា ឬមួយយ៉ាងណា? សហភាពសូវៀត គឺថាមានទំនាក់ទំនងមិនល្អទាល់តែសោះជាមួយភាគីទាំងពីរនៅក្នុងសង្គ្រាមកម្ពុជា។ សូវៀត គេមានឯកអគ្គរដ្ឋទូតរបស់ខ្លួនរស់នៅទីក្រុងភ្នំពេញ ហើយសូវៀតគិតថា គេចាត់ទុកខ្លួនគឺជាសម្ព័ន្ធមិត្តមួយ វាជារឿងមួយប្រកបទៅដោយល្បិចកលណាស់ ប៉ុន្តែខ្ញុំគ្មានភ្ញាក់ផ្អើលអីទេ ដោយសារវាអាស្រ័យទៅលើអំឡុងពេលផ្សេងគ្នា។ ឯកសារនៅក្នុងបណ្ណសាររបស់សូវៀត នៅពេលដែលសូវៀតមានចំណាប់អារម្មណ៍តិចតួចបំផុតនៅក្នុងប្រទេសវៀតណាម នៅក្នុងកម្ពុជានិងឡាវ។ ហើយមិនចង់ឲ្យចំណាយលុយច្រើននៅទីនេះទេ គេមានចំណាប់អារម្មណ៍នៅខាងផ្នែកអឺរ៉ុបវិញ។ ហើយគឺ ហូជីមិញ ចង់ឲ្យវៀតណាមគឺថាមានបក្សមួយដាក់ដោយឡែកតែម្ដង។

**ស៖** ប្រហែលជាខ្ញុំស្ដាប់លោកស្រីមិនយល់ច្បាស់ ប៉ុន្តែឌុកទ័រ ស៊្វាយ គឺថាគាត់បានរៀបរាប់

យ៉ាងត្រឹមត្រូវអំពីគោលនយោបាយរបស់វៀតណាម និងឥណ្ឌូចិន ពាក់ព័ន្ធទៅនឹងស្ថានទូត ក៏ដូចជាឯកអគ្គរដ្ឋទូតរបស់សហភាពសូវៀតអ៊ីចឹងដែរ។ ដូច្នេះខ្ញុំមិនឃើញថា វាមានអ្វីទាក់ទងរវាង ឌុកទ័រ ស្ប៊ាយ ជាមួយនឹងឯកអគ្គរដ្ឋទូតសូវៀតនោះឡើយ។ តើយ៉ាងម៉េច តើយ៉ាងដូចម្ដេចដែរ?

[១៤:៣៦:២៩]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តិចលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញ កុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា មេធាវីការពារក្ដី ហាក់ដូចជាបញ្ចេញមតិជាជាងការចោទសំណួរលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមែនជាការនោះទេ -- គ្រាន់តែជាការសាកសួរអំពីសហភាពសូវៀតស្របជាមួយនឹងមតិ ក៏ដូចជាការយល់ឃើញរបស់លោកឌុកទ័រ ស្ប៊ាយ *(Pike)* តែប៉ុណ្ណោះ។ ខ្ញុំមិនមានអ្វីបន្ថែមទេ។

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** ទាក់ទៅនឹងមតិ ឬក៏ការយល់ឃើញរបស់ទូតសូវៀត គឺថាជារឿងគួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំង។ ប្រហែលជាទូតសូវៀតយល់ស្របទាំងស្រុង ប្រហែលជាលោកត្រឹមត្រូវ ប៉ុន្តែខ្ញុំមិនដឹងថាយ៉ាងម៉េចទេ វាអាចថាជាគោលនយោបាយរបស់អាមេរិក គោលនយោបាយសូវៀត ឬក៏គោលនយោបាយវៀតណាម។

[១៤:៣៧:៣៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយបន្ថែមទៀតទាក់ទងទៅនឹង ថាតើចិនយល់ឃើញយ៉ាងម៉េចដែរជាមួយទូតវៀតណាម? ហើយខ្ញុំចង់ឲ្យលោកស្រីពិនិត្យមើលទៅលើរបាយការណ៍របស់ ហ្កេង បៀវ *(Geng Biao)* គឺ E307/5.2.1 ជាពិសេសគឺមានលេខ ERN00100621 ដើម្បីជាព័ត៌មានសម្រាប់លោកស្រី គឺថាខ្ញុំមិនឃើញលោកស្រីសរសេរអ្វីទាក់ទងនៅក្នុងសៀវភៅរបស់លោកស្រីនោះឡើយ ប៉ុន្តែនេះជារបាយការណ៍ប្រជុំដ៏សំខាន់នៅខែមករា ឆ្នាំ៧៩ របស់គណៈអចិន្ត្រៃយ៍របស់ប្រទេសចិន។ ហ្កេង បៀវ

គឺជាមេទ័ពដ៏ធំនៅប្រទេសចិន ហើយគាត់បានធ្វើការវាយការណ៍ទៅ តេង ស៊ីវពីង។ នេះមិនមែនជាឯកសារសាធារណៈ ឬក៏ជាមតិជាសាធារណៈរបស់ចិននោះឡើយ ប៉ុន្តែជាការគិតរបស់ប្រទេសចិនចំពោះប្រទេសវៀត-ណាម។ ដូចដែលលោកស្រីបានជ្រាបរួចទៅហើយថា តេង ស៊ីវពីង គាត់ចាត់ទុកវៀតណាមគឺជាៗយូគោមរបស់ខាងអាស៊ីខាងកើត។ ហើយខ្ញុំសូមដកស្រង់អត្ថបទមួយ៖ "ហេតុអ្វីបានជាវៀតណាមមិនឈ្លានពានកម្ពុជា នៅពេលទំនាក់ទំនងរបស់ពួកគេបានខូចខាតតាំងពីឆ្នាំកន្លងមក? ហេតុអ្វីបានជាគេរង់ចាំមកដល់ឥឡូវហ្នឹងទើបឈ្លានពានកម្ពុជា? ជាការពិត តាំងពីមុនការរំដោះវៀត-ណាម ខាងត្បូង វៀតណាមគឺមានកម្លាំងគ្រប់គ្រាន់ទាំងយោធានិងកម្លាំង។ ប៉ុន្តែមានអ្នកសង្គមនិយមមួយចំនួននៅខាងក្រោយខ្នងរបស់ពួកគេ ហើយពួកគេមានគម្រោងនឹងឈ្លានពានកម្ពុជា ដើម្បីបង្កើតបានជាសម្ព័ន្ធមិត្តឥណ្ឌូចិន។ ហើយដោយផ្អែកទៅលើៗចក្រព័តសង្គមនិយម ដើម្បីពង្រីកទៅកាន់តំបន់នានាក្នុងអាស៊ីអាគ្នេយ៍"។ សំណួររបស់ខ្ញុំគឺថា តើការយល់ឃើញរបស់ប្រទេសចិនទាក់ទងទៅនឹងការឈ្លានពានរបស់វៀតណាមហ្នឹង តើវាត្រូវជាមួយនឹងមតិ ដូក្លាស ស្ប៉ាយ *(Douglas Pike)* នៅសភាអាមេរិកដែរឬទេ? តើលោកស្រីយល់ស្របតាមនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញចាំបន្តិច។ សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

[១៤:៤០:៣៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី លោកធ្វើសកម្មភាពដដែលនេះ គឺលោកលើកយកមតិដែលជាមតិរបស់បុគ្គលម្នាក់ ហើយលោកថាមតិរបស់ប្រទេស។ ហើយលោកធ្វើការវាយតម្លៃទៅលើភស្តុតាងតែមួយនៅចំពោះមុខ ដូច្នេះ ខ្ញុំស្នើឲ្យលោកបញ្ឈប់សកម្មភាពបែបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដថាតើខ្ញុំយល់អ្វីដែលលោកស្រីនិយាយឬក៏អត់? ខ្ញុំនិយាយអំពីគោលនយោបាយរបស់វៀតណាម ហើយខ្ញុំលើកយកមតិ ឬក៏លើកការយល់ឃើញអំពីគោលនយោបាយរបស់សូវៀត របស់អាមេរិក របស់វៀតណាម របស់ចិន ហើយខ្ញុំសាកសួរទៅមតិជំនាញទៅវិញ។ ដូច្នេះ នេះគឺជាអ្វីដែលខ្ញុំគួរធ្វើ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកបានលើកយកមតិរបស់បុគ្គល មិនមែនជាមតិរបស់ប្រទេសមួយនោះឡើយ។ ទោះបីថាមតិមួយនេះវាឆ្លុះបញ្ចាំងត្រឹមត្រូវទៅលើមតិរបស់ប្រទេសម៉េចក៏ដោយ ក៏យើងត្រូវការចាំបាច់ឲ្យការបញ្ជាក់។ ខ្ញុំគិតថានេះគឺជាបញ្ហានៅក្នុងការប្រើប្រាស់ពាក្យពេចន៍។

[១៤:៤១:៤០]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំគិតថា ដូក្លាស ស្ប៉ាយ គឺជាបញ្ហាដែលយើងអាចពិភាក្សាបាន ប៉ុន្តែចំពោះឯកសារនេះគឺជាគោលនយោបាយរបស់ប្រទេសចិន គឺជាឯកសារដែលបញ្ជាក់ច្បាស់លាស់។ ដូច្នេះ បើសិនបើខ្ញុំខុសពេលហ្នឹង លោកស្រីអ្នកជំនាញប្រហែលជាអាចកែខ្ញុំបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោក តើនេះជាឯកសារផ្លូវការរបស់ចិន មានការបញ្ជាក់អះអាងដោយអាជ្ញាធរចិនទេ លោកកូប៉េ? យើងឃើញថា ឯកសារនេះគឺជាឯកសារដែលយើងមិនដឹងថាយើងទទួលបានក្នុងកាលៈទេសៈបែបណាទេ។ លោកបញ្ជាក់បន្តិចទៅមើល?

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំហាក់ដូចជាអាក់អន់ៗចិត្តបន្តិច ដែលយើងត្រូវពិនិត្យទៅលើភាពពាក់ព័ន្ធរបស់ ហ្គេង បៀវ ក៏ដូចជារបាយការណ៍មួយនេះ។ ដោយគ្មានការមន្ទិលសង្ស័យទាល់តែសោះ នេះគឺជាទស្សនៈរបស់ចិនឆ្លុះបញ្ចាំងអំពីគោលនយោបាយចិន ប្រសិនបើខ្ញុំនិយាយខុស ខ្ញុំគិតថាអ្នកជំនាញគាត់អាចកែខ្ញុំបាន។ គាត់នឹងកែប្រែ។

[១៤:៤២:៥១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នេះគឺជាការសម្រេចរបស់តុលាការ។ ដូច្នេះ លោកត្រូវគោរពតាមនៅពេលនេះ។

**លោក វ៉ិចទ័រ កូប៉េះ៖**

អត់បញ្ហា។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកស្រី បេកយ័រ តើលោកស្រីអាចប្រាប់បានដែរឬទេ ថាតើគោលនយោបាយរបស់ចិន

ពាក់ព័ន្ធទៅនឹងមតិរបស់ចិន ក៏ដូចជាគោលនយោបាយរបស់វៀតណាមថា តើមានការយល់ឃើញយ៉ាងម៉េចដែរចំពោះកម្ពុជាប្រជាធិបតេយ្យចំពោះកម្ពុជា?

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** ខ្ញុំគិតថានេះគឺជាមតិជាសាធារណៈ ហើយមាននៅក្នុងសៀវភៅរបស់ខ្ញុំ។ គឺថាចិនចោទប្រកាន់ថាវៀតណាមចង់បង្កើតជាសហព័ន្ធឥណ្ឌូចិន។ ហើយៗចិនបានឈ្លានពានវៀតណាមតាមព្រំដែន ហើយបានបង្រៀនបទមេរៀនមួយដ៏ល្អដល់វៀតណាម។ ខ្ញុំគិតថា វាជាការប្រើប្រាស់ការចង់បានរបស់វៀតណាម ដើម្បីបង្កើតជាសហភាពឥណ្ឌូចិនមួយ។ គឺជាទស្សនៈជាសាធារណៈ ប៉ុន្តែគេចាត់ទុកថាវៀតណាមចង់បង្កើតជាសហភាពឥណ្ឌូចិន វាអត់មានអ្វីជាចម្លែក អត់មានអ្វីជាអាថ៌កំបាំងនោះទេ។

**ស៖** សូមអរគុណចំពោះការឆ្លើយតបរបស់លោកស្រី។

[១៤:៤៤:១២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីក៏សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រងចាំសម្រាប់សាក្សីនិងអ្នកជំនាញ ដល់អ្នកជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៤ នាទី)*

[១៥:០៤:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនិតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវី

ការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកស្រី បេកឃ័រ មុនពេលដែលយើងឈប់សម្រាក យើងបានជជែកគ្នាអំពីសភាអាមេរិក គឺរបាយការណ៍អំពីមហិច្ឆតារបស់វៀតណាមចំពោះកម្ពុជា។ យើងបាននិយាយអំពីគោលនយោបាយ ឬក៏មតិរបស់សូវៀតចំពោះវៀតណាម ក៏ដូចជារបស់ប្រទេសចិនផងដែរ។ ហើយយើងមិនទាន់បាននិយាយទៅដល់សម្តេចព្រះវរាជបិតា នរោត្តម សីហនុ ទាក់ទងទៅនឹងការឈ្លានពានរបស់វៀតណាមនៅក្នុងឆ្នាំ១៩៧៩។ យើងបាននិយាយដោយសង្ខេបរួចហើយអំពីសម្តេច សីហនុ លោកបាន -- យើងបាននិយាយអំពីការថ្លែងនៅទីក្រុងប៉េកាំង។ តើលោកស្រីអាចប្រាប់បន្ថែមបានទេ ទាក់ទងទៅនឹងសន្និសីទកាសែតដែលស្តេច សីហនុ បានធ្វើនៅក្នុងទីក្រុងប៉េកាំង ខែមករា ៧៩?

[១៥:០៦:៣៨]

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** ដូចដែលខ្ញុំបានប្រាប់ទៅខាងព្រះរាជអាជ្ញារួចទៅហើយ គឺថាវាជាការសម្ភាសយ៉ាងវែងដែលផ្ទុះបញ្ចាំងអំពី -- ដែលបង្ហាញពីការឃុំខ្លួនក្នុងវាំង ថាតើៗគាត់រស់នៅដោយរបៀបណាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនិយាយអំពីការដែលគាត់ទៅទីក្រុងញូវយ៉ក ទៅអង្គការសហប្រជាជាតិ ហើយដែលនិយាយអំពីកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការព្រួយបារម្ភរបស់គាត់។

**ស៖** សំណួររបស់ខ្ញុំ គឺថា តើនៅក្នុងសន្និសីទកាសែតនៅទីក្រុងប៉េកាំងនោះ ថាតើជាការធ្វើសន្និសីទកាសែតផ្តោតទៅលើទស្សនៈរបស់គាត់ ឬក៏អំពីអ្វី? ថាតើគាត់យល់ឃើញយ៉ាងម៉េចដែរទាក់ទងទៅនឹងការឈ្លានពាន ក៏ដូចជា -- ថាតើលោកស្រីយល់ឃើញយ៉ាងម៉េចដែរអំពីសន្និសីទកាសែតនោះជាទូទៅ?

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ ប៉ុន្តែអ្វីដែលខ្ញុំច្បាស់ គឺថាគាត់ខ្លាចវៀតណាម។ ខ្លាចថាវៀតណាមលេបទឹកដីកម្ពុជា ដូច្នេះ នេះគឺជាអ្វីដែលគាត់--។

**ស៖** ថាតើនេះ គឺជាអ្វីដែលលោកស្រីចាំទាក់ទងទៅនឹងការឈ្លានពាន ក៏ដូចជាការលុកលុយនិងមហិច្ឆតារបស់វៀតណាមហ្នឹងឬទេ? ថាតើនេះ គឺជាអ្វីដែលគាត់និយាយនៅមុខក្រុមប្រឹក្សាសន្តិសុខ

អង្គការសហប្រជាជាតិនៅខែមករា ឆ្នាំ៧៩ តើមែនទេ?

**ធ៖** ខ្ញុំមិនចាំអំពីចំណុចទាំងអស់នេះទេ។

**ស៖** តើលោកស្រីចាំដែរឬទេ ថាចាំពាក្យពេចន៍ជាក់ស្តែងដែលគាត់និយាយនៅពេលនោះដែរឬទេ? គឺថាគាត់ប្រៀបធៀបការលុកលុយរបស់វៀតណាម គឺដូចជាការឈ្លានពានរបស់អាល្លឺម៉ង់នៅក្នុងប្រទេសប៉ូឡូញ។ តើលោកស្រីចាំអំពីចំណុចទាំងអស់នេះទេ?

**ធ៖** អត់ទេ។ ខ្ញុំអត់ចាំអំពីចំណុចទាំងអស់នេះទេ។

**ស៖** ហើយគាត់បានប្រើប្រាស់ឧទាហរណ៍នៃ ដូចថា គឺថាវៀតណាមកំពុងតែលេប គឺដូចជាពស់ថ្លាន់កំពុងតែរុំខ្លួនកម្ពុជា ហើយលេបកម្ពុជាជាបន្តិចម្តងៗ។ តើលោកស្រីចាំពីពាក្យទាំងអស់នេះទេ?

[១៥:០៩:១៩]

**ធ៖** ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថា គាត់ថាគេកំពុងតែលេបត្របាក់កម្ពុជាបន្តិចម្តងៗអាហ្នឹងគឺជាអ្វីដែលខ្ញុំចាំ។

**ស៖** តើលោកស្រីចាំដែរឬទេ ដែលគាត់ចាត់ទុកថាការឈ្លានពានរបស់វៀតណាម គឺជាការលុកលុយ ក៏ដូចជាការបំពេញមហិច្ឆតារយៈពេលវែងក្នុងការលេបត្របាក់ទឹកដីកម្ពុជាដែរឬទេ?

**ធ៖** ពិតហើយ គឺជាការនិយាយជាបទដ្ឋានរួមគ្នា ក្នុងរយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំនេះ។

**ស៖** តើខ្ញុំអាចសន្និដ្ឋានបានទេថា អ្វីដែលសហភាពសូវៀតយល់ឃើញ ក៏ដូចជាការយល់ឃើញរបស់ចិនទាក់ទងទៅនឹងការឈ្លានពានរបស់វៀតណាមហ្នឹង គឺថាក៏ដូចជាការគិតឃើញរបស់សម្តេចសីហនុ គឺដូចគ្នា?

**ធ៖** សូវៀត និង ចិន មិនយល់ស្របដូចគ្នាទាក់ទងទៅនឹងមហិច្ឆតារបស់វៀតណាមនោះទេ។ លោកអាចឃើញថាចំពោះសូវៀតដូចជាមិនមានបញ្ហាពាក់ព័ន្ធនោះទេ ប៉ុន្តែខ្ញុំមិនយល់ស្រប។ អ្វីដែលខ្ញុំមិនយល់ស្របគឺថា សូវៀត និង ចិន គាត់មិនយល់ស្របជាមួយគ្នាទាក់ទងទៅនឹងអ្វីដែលវៀតណាមធ្វើនោះទេ។

**ស៖** ឥឡូវនេះ យើងនិយាយបន្ថែមបន្តិចអំពីវៀតណាមផ្ទាល់តែម្តង គឺអំពីមហិច្ឆតាក៏ដូចជាគោលនយោបាយរបស់វៀតណាមចំពោះកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាចំពោះកម្ពុជាទាំងមូល។ តើលោកស្រីអាចប្រាប់បានដែរឬទេថាតើរបបក្រោយឆ្នាំ៧៥ ក៏ដូចជាការរួបរួមរបស់វៀតណាមដឹកនាំដោយ ឡេ យន់ ហ្នឹង –ខ្ញុំមិនច្បាស់ពីការអាននៅក្នុងភាសាខ្មែរនោះទេ– ប៉ុន្តែតើលោកស្រីយល់ថារបប

ដែលដឹកនាំដោយវៀតណាមមានលក្ខណៈយ៉ាងដូចម្តេចដែរ?

**ឆ៖** នេះគឺជាប្រធានបទដ៏ធំថា តើគេបង្រួបបង្រួមដោយរបៀបណា ខ្ញុំមិនដឹងនោះទេ។

**ស៖** ខ្ញុំយល់ស្របជាមួយលោកស្រីថា នេះជាប្រធានបទដ៏ធំមួយ ប៉ុន្តែឥឡូវនេះ យើងនិយាយអំពីគោលនយោបាយចំពោះសហភាពសូវៀត។ តើខ្ញុំអាចនិយាយបានទេថា ឡេ យន់ គឺជាអ្នកស្តាលីននិយម។ តើលោកស្រីយល់ឃើញយ៉ាងម៉េចដែរ?

**ឆ៖** មិនមានបញ្ហាអ្វីនោះឡើយ ដោយថាវៀតណាមគឺគាត់នៅជិតជាមួយសូវៀតជាងចិន គឺថាតាំងពីសម័យហូជីមិញមកម្ល៉េះ។ គាត់បាននិយាយអំពីបញ្ហាប្រេបេរមាត់ ហើយនិងកែវជាដើម។ ទាំងអស់នេះគឺបានន័យថាសូវៀតគាត់ចាប់មានបញ្ហាជាមួយអាកប្បកិរិយារបស់ចិន។

**ស៖** តើលោកស្រីអាចចែករំលែកបានទេអំពីអ្វីដែលលោកស្រីបានមានប្រសាសន៍កន្លងមកនេះ?

**ឆ៖** ក្នុងបញ្ហាអ្វីដែរ?

**ស៖** ជាពិសេសទាក់ទងទៅនឹងបញ្ហាសង្គមនិយម ក៏ដូចជាមាគ៌ាមនោគមន៍វិជ្ជាជាដើមហ្នឹង គឺនៅក្រោយឆ្នាំ៧៩។

[១៥:១៣:២០]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនច្បាស់ថាតើអ្វីដែលកំពុងតែនិយាយនោះឡើយ ចំពោះការ -- អំពីព្រៃផ្សៃជាមួយប្រទេសសង្គមនិយម ហើយធ្វើឲ្យប្រទេសសង្គមនិយមទៅជាប្រទេសមូលធននិយម គឺមិនមែនជាបញ្ហាដែលពាក់ព័ន្ធនោះឡើយ ប៉ុន្តែជាបញ្ហាដែលអាចទាក់ទងទៅនឹងប្រទេសសង្គមនិយម។ ដូច្នេះខ្ញុំចង់ឲ្យបញ្ជាក់ឲ្យបានច្បាស់ថា មេធាវីការពារក្តីយល់អំពីអ្វីដែលយើងនិយាយគឺការផ្លាស់ប្តូរពីសង្គមនិយមទៅជាមូល-ធននិយម។

**លោក វិុចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដអំពី ឆេក និងស្លូវ៉ា នោះទេប៉ុន្តែខ្ញុំគិតថានេះវាជាបញ្ហាមួយ។ អ្វីដែលខ្ញុំចង់សួរគឺថាតើយើងអាច --

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើសុំឲ្យមេធាវីការពារក្ដីនិយាយឲ្យបានឮបន្តិចលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ និយាយឲ្យបានខ្លាំងជាងហ្នឹងបន្តិច ពីព្រោះអ្នកបកប្រែស្ដាប់អត់បានទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

គឺថាយើងបាន ខ្ញុំស្នើសុំឲ្យគេលើកមីក្រូឲ្យជិតខ្ញុំបន្តិចមក។

**ស៖** ដូច្នេះ ខ្ញុំគិតថា តើយើងអាចចាប់យកលិទ្ធិទាំងពីរយកមកពិភាក្សាគឺទាក់ទងទៅនឹង ឆេក និងស្តូវ៉ា នៅក្នុងឆ្នាំ១៩៦០ ជាងនោះដែរឬទេ? ថាតើយើងអាចពិភាក្សាអំពីលទ្ធិទាំងពីរនេះដែរឬទេ? ហើយជាពិសេសថា តើវៀតណាមគាត់យល់ឃើញយ៉ាងម៉េចដែរទាក់ទងទៅនឹងលទ្ធិទាំងអស់នេះ?

[១៥:១៥:១៤]

**លោកស្រី អេលីហ្សាបេត បេកឃ័រ៖**

**ឆ៖** ខ្ញុំនិយាយតាមត្រង់ទៅ ខ្ញុំមិនបានឃើញអំពីឯកសារទាំងអស់នេះទេ។

**ស៖** តើលោកស្រីចង់និយាយអំពីឯកសារនៃការឈ្លានពានឆេកូស្លូវ៉ាគីនោះមែនទេ? ប្រហែលជាខ្ញុំយល់ច្រឡំចំពោះសំណួររបស់លោក ប៉ុន្តែខ្ញុំចង់ដឹងថា តើជាឆេកូស្លូវ៉ាគី ឬក៏អាហ្កានីស្ថាន ធៀបជាមួយនឹងវៀតណាមនៅកម្ពុជាអ៊ីចឹងមែនទេ?

**ស៖** ខ្ញុំគិតថាអ្វីៗវាកើតឡើង វា -- ខ្ញុំនិយាយដូចជាឆាប់រហ័សពេក ដោយសារខ្ញុំមានពេលវេលាកំណត់។ ដូច្នេះអ្វីដែលខ្ញុំចង់សួរលោកស្រីគឺ ថាតើលោកស្រីអាចប្រាប់ខ្ញុំបានដែរឬទេថាតើវៀត-ណាមចាប់យកលទ្ធិមួយដែលមិនត្រូវជាមួយនឹងលទ្ធិបច្ចុប្បន្នដែរឬទេ? ថាតើលទ្ធិហ្នឹងវាត្រូវដូចគ្នានឹងអ្វីដែលសូវៀតបានឈ្លានពាន សេកូស្លូវ៉ាគីក៏ដូចជាឈ្លានពាន អាហ្កានីស្ថាន ក្នុងឆ្នាំមួយពាន់ប្រាំបួនរយចិតសិបជាង ក៏ដូចជា -- ឬក៏យើងអាចនិយាយថាជាប្រទេសគុយបានៅក្នុងទ្វីបអាស៊ីជាដើម។ ថាតើនេះគឺជាគោនយោបាយដែលគេធ្វើតាមប្រទេសសហភាពសូវៀតដែរឬទេ?

[១៥:១៦:៣៨]

**ឆ៖** ដោយសារតែខ្ញុំមិនដែលឃើញការប្រៀបធៀបនេះកន្លងមក ប៉ុន្តែនៅក្នុងឆ្នាំ១៩៧០ វៀត-ណាមគឺចូលរួមយ៉ាងខ្លាំងនៅក្នុងសង្គ្រាម ដូច្នេះខ្ញុំខ្លួនឯងផ្ទាល់ ខ្ញុំមិនអាចឃើញថាវាមានការប្រៀបធៀបណាមួយដែលសមស្រប ដែលថាលទ្ធិបច្ចុប្បន្នគឺវាដូចគ្នាទៅនឹងការឈ្លានពាននៅពេលនោះរបស់

វៀតណាមនៅកម្ពុជានោះឡើយ។

**ស៖** តើលោកស្រីមានដឹងអំពីការផ្តល់យោបល់របស់សូវៀតចំពោះប្រទេសវៀតណាមឲ្យធ្វើជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ ដូចដែលសូវៀតធ្វើជាមួយប្រទេសឆេកូស្លូវ៉ាគីដែរឬទេ? គឺនៅក្នុងឆ្នាំ ១៩៦៨ ដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** ប្រហែលជាខ្ញុំចង់សួរលោកស្រីម៉្យាងទៀតថា តើវៀតណាមក្នុងឆ្នាំ៧៥, ៧៦, ៧៧, ៧៨, ៧៩ គឺជាៗដៃជើងរបស់សូវៀត របស់ស្តាលីនដែរឬទេ?

[១៥:១៧:៥៦]

**ឆ៖** ខ្ញុំមិនគិតថាវៀតណាមជាដៃជើង ឬក៏ជាបក្ខពួករបស់សូវៀតនោះទេ។

**ស៖** ប៉ុន្តែលោកស្រីបានអានសៀវភៅរបស់ ស្ទីវិន ម័រ។ ខ្ញុំមិនអាចរកឃើញការដកស្រង់ជាក់ស្តែងនោះទេ ប៉ុន្តែនេះគឺជាការយល់ឃើញរបស់គាត់ គឺថាវៀតណាមគឺជាដៃជើងរបស់សូវៀត។ តើលោកស្រីយល់ស្របដែរឬទេ?

**ឆ៖** ខ្ញុំយល់ស្របជាមួយ ណាយ៉ាន់ ចាន់ដា មិនមែនជា -- ដែលថាវៀតណាមមិនមែនជាដៃជើងរបស់សូវៀតនោះឡើយ។ អ្វីដែលខ្ញុំចង់និយាយគឺថា វៀតណាមគឺជាប្រទេសក្រីក្រមែនទែន ក្រោយឆ្នាំ៧៥ សហរដ្ឋអាមេរិកចាប់ផ្តើមដំណើរការយ៉ាងខ្លាំង ហើយភាពក្រីក្ររបស់ប្រជាជនវៀតណាមបានបណ្តាលឲ្យប្រជាជនគិតអំពីបញ្ហារោងចក្រ អំពីការជួយទៅដល់វៀតណាម។ ដូច្នេះ ប្រសិនបើលោកចាំច្បាស់ គឺ *វ៉ាឡិន-វ៉ំ-ហ្វៃ* គឺថាៗពួកគេត្រូវបញ្ជូនពលករចេញទៅខាងក្រៅប្រទេស ដូច្នេះហើយយើងដឹងច្បាស់ថា ពួកគាត់ -- ប៉ុន្តែគេមិនមែនជាដៃជើងនោះឡើយ គ្រាន់តែថាគេជាប្រជាជនក្រីក្រតែប៉ុណ្ណោះ។

**ស៖** តើលោកស្រីយល់ស្របជាមួយខ្ញុំដែរឬទេថា ណាយ៉ាន់ ចាន់ដា មិនអាចប្រើប្រាស់បណ្ណសាររបស់សូវៀតដែលខុសពី ម័ររ៉េស ដែលគាត់អាចចូលពិនិត្យឯកសារនៅក្នុងបណ្ណសាររដ្ឋានសូវៀត។ តើលោកស្រីយល់ស្របតាមខ្ញុំដែរឬទេ?

[១៥:១៩:៤៣]

**ឆ៖** ខ្ញុំសូមបញ្ជាក់មួយសាទៀតថា ការទទួលបានលទ្ធភាពចូលពិនិត្យរបស់ ស្ទីវិន ម័រ ទៅលើ *អាខាយវ*របស់សូវៀតហ្នឹងមិនមែនជាបញ្ហាសំខាន់នោះទេ។ ហើយខ្ញុំក៏មិនចងចាំថា វៀតណាមគឺជាដៃជើងរបស់សូវៀតនោះឡើយ។

**ស៖** សំណួរខ្ញុំសូមបន្តទៅមុខទៀត។ ទាក់ទងទៅនឹងរបាយការណ៍សិទ្ធិមនុស្សរបស់វៀតណាម លោកស្រីបានសរសេរនៅក្នុងសៀវភៅរបស់លោកស្រីផងដែរ តើលោកស្រីអាចបញ្ជាក់បានដែរឬទេ អំពីការសម្លាប់រង្គាលនៅវៀតណាមខាងត្បូងដោយទាហានវៀតណាមខាងជើងក្រោយថ្ងៃ ក្រោយខែមេសា ឆ្នាំ៧៥ ជាពិសេសគឺទាក់ទងទៅនឹងទាហានរបស់វៀតណាមខាងត្បូងនោះ តើលោកស្រីយល់ឃើញយ៉ាងដូចម្តេចដែរ?

**ឆ៖** បញ្ហាសិទ្ធិមនុស្សគឺជាបញ្ហាមួយ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយគឺថា របាយការណ៍ពិតប្រាកដអំពីចំនួននៃការសម្លាប់កន្លងមកនោះ។ ប៉ុន្តែខ្ញុំគិតថានេះគឺជាបញ្ហាមួយ ព្រោះថាឥឡូវរដ្ឋាភិបាលនៅកាន់អំណាចនៅឡើយ។ ដូច្នេះយើងមិនអាចទទួលទិន្នន័យទាំងអស់នេះទេ។ ដូច្នេះខ្ញុំមិនត្រូវនិយាយអំពីរបាយការណ៍សិទ្ធិមនុស្សរបស់វៀតណាមទេ។

**ស៖** ខ្ញុំ--យើងជិតបញ្ចប់ប្រធានបទមួយនេះហើយ ប៉ុន្តែខ្ញុំគិតថា ឥឡូវនេះមានជនភៀសខ្លួន--នៅពេលនោះមានជនភៀសខ្លួនប្រហែលជា ១លាននាក់ដែលត្រូវបានគេបណ្តេញចេញពីជនភៀសខ្លួនចិនគេបណ្តេញចេញពីវៀតណាមប្រហែលជា១លាននាក់។ តើលោកស្រីយល់ឃើញយ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំបានរាយការណ៍អំពីចំណុចនេះទៅក្នុងផ្នែកសៀវភៅរបស់ខ្ញុំ គឺថាមានប្រជាជននៅលើទូកគឺប្រជាជននៅខាងត្បូង ហើយនិងពួកជនជាតិចិននៅខាងជើង។ ដូច្នេះគឺថា ពួកគាត់ទាំងអស់នោះពាក់ព័ន្ធយ៉ាងខ្លាំងជាមួយកម្ពុជា។ គឺថាអ្នកដែលនៅខាងជើង គឺថាជនជាតិចិន សង្ស័យ ត្រូវបានគេសង្ស័យដោយសារវៀតណាមគិតថាជនជាតិចិន គឺនៅពីក្រោយខ្នងសង្គ្រាមរវាងវៀតណាមនិងកម្ពុជា។ ទោះបីថា ពួកគាត់ជាជនជាតិចិន គាំទ្រកុម្មុយនីស្តវៀតណាមក្តី ប៉ុន្តែគេបណ្តេញពួកគាត់ទៅហុងកុង ឬមួយក៏តំបន់ផ្សេងៗ ហើយវាមានចំណុចមួយទៀតគឺសង្គ្រាមដ៏គួរឲ្យភ័យរន្ធត់។

[១៥:២២:១៥]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងប្រធានបទនេះ គឺចង់សួរអំពីអ្វីដែលយើងបានពិភាក្សាកន្លងមក គឺទាក់ទងទៅនឹងមហិច្ឆតារបស់វៀតណាមចំពោះកម្ពុជាប្រជាធិបតេយ្យ។ គឺអំពីគោលជំហររបស់វៀតណាមចំពោះប្លុកសូវៀតគឺ ក៏ដូចជារបាយការណ៍សិទ្ធិមនុស្ស។ ឥឡូវនេះ តើលោកស្រីអាចបញ្ជាក់ប្រាប់ខ្ញុំបានទេក្នុងមតិយោបល់លោកស្រីជាអ្នកជំនាញ ថាតើការឈ្លានពានរបស់វៀតណាមទៅលើកម្ពុជាប្រជាធិបតេយ្យគឺជាអំពើឈ្លានពាន លុកលុយធ្ងន់ធ្ងរ ដែលប្រឆាំងទៅនឹងអនុសញ្ញាដែរឬទេ?

**ឆ៖** តើលោកចង់និយាយអំពីមនុស្សឬ?

**ស៖** បាទ ខ្ញុំនិយាយអ៊ីចឹងមែន។

**ឆ៖** ខ្ញុំមិនដែលគិតថា វៀតណាមជាការឈ្លានពានដើម្បីមនុស្សធម៌នោះទេ វាជាការឈ្លានពានដើម្បីអំណាច ហើយខ្ញុំគិតថា កម្ពុជាហាក់ដូចជាមិនដឹងថាតើ វៀតណាមត្រឡប់មកវិញបានឆាប់រហ័សបែបនេះឡើយ។ ដូច្នេះចំពោះមនុស្សធម៌គឺបញ្ចប់នៅពេលចុងក្រោយ នៅពេលដែលអង្គការសហប្រជាជាតិគាំទ្រពួកគេ។ ហើយអ្វីដែលខ្ញុំចង់និយាយគឺថា ដោយសារតែខ្ញុំតែងតែមានអារម្មណ៍មិនល្អជាមួយគ្រប់រដ្ឋាភិបាលទាំងអស់។ ខ្ញុំគិតថា សូម្បីតែប្រទេស ប្រសិនបើប្រទេសថៃមកឈ្លានពានកម្ពុជា ហើយផ្តួលរំលំរបបភ្នំពេញ ក៏ប្រហែលជាវាមានលទ្ធផលផ្សេងពីនេះ។

[១៥:២៤:១២]

**ស៖** ខ្ញុំមិនប្រាកដអំពីបញ្ហានេះទេ។ ប៉ុន្តែយ៉ាងហោចណាស់ ខ្ញុំចង់ឲ្យមានការកំណត់ជាកំណត់ត្រាថាលោកស្រីសើចចំអកទៅនឹងពាក្យរបស់ខ្ញុំដែលនិយាយថា មនុស្សធម៌។ ដូច្នេះតើវាជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសើចព្រោះថាខ្ញុំមិនដែលឮពាក្យនេះពីមុនកន្លងមក។ គឺថាមិនមានផ្នែកណាមួយទាក់ទងនឹងមនុស្សធម៌នៅពេលដែលពួកគេផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ វាមិនមែនជាបញ្ហាដែលថា ព្រោះថាប្រសិនបើយើងនិយាយ បញ្ហាបន្ទាប់បន្សំទើបជាបញ្ហាមនុស្សធម៌។ ប៉ុន្តែខ្ញុំគិតថា នេះវាគ្រាន់តែជាការឆ្លើយតបទៅនឹងបញ្ហាសង្គ្រាមនៅតាមព្រំដែន។

**ស៖** លោកស្រីទើបនឹងផ្តល់ចម្លើយដ៏ល្អចំពោះសំណួររបស់ខ្ញុំ ហើយវាជាផ្នែកដែលខ្ញុំចាប់អារម្មណ៍ផងដែរ។ ហើយបន្តទៅទៀតលោកស្រីបាននិយាយថា វៀតណាមហ្នឹងបណ្តេញខ្មែរក្រហម ប៉ុន្តែវាត្រឹមត្រូវដែរឬទេ ដែលថារដ្ឋាភិបាលដែលត្រូវបានលើកបន្តុបនោះ គឺជាសុទ្ធតែជាអតីតខ្មែរក្រហម? ហើយបានពង្រីកបន្ថែមទៅលើចំណុចនេះ សម្តេច សីហនុ បានហៅមេដឹកនាំដែលលើកបន្តុបហ្នឹង ថាជាអាយ៉ងរបស់វៀតណាម។ តើលោកស្រីអាចនិយាយបានទេថា គឺមិនមែនជាការបណ្តេញខ្មែរក្រហមទាំងស្រុង គឺថាគ្រាន់តែគេទុកខ្មែរក្រហមមួយពួកហ្នឹងនៅក្នុងអំណាចបន្តទៅទៀតនោះ?

**ឆ៖** អត់ទេ មិនមែននិយាយបែបនេះទេ។ គឺថារដ្ឋាភិបាលណាក៏ដូចរដ្ឋាភិបាលណា សម្តេច ហ៊ុន សែន , ហេង សំរិន សុទ្ធតែជា -- អ្នកទាំងអស់នេះគឺយើងដឹងច្បាស់អំពីចំណុចទាំងអស់នេះ គឺថាគាត់មិនមែនជាផ្នែកនៃកម្ពុជាប្រជាធិបតេយ្យបន្តទៅទៀតទេ។ ពួកគេបានរត់គេចចេញក្នុងពេលដែលគេ

បោសសម្អាតខាងបូព៌ា ហើយបានចូលជាមួយវៀតណាម។ ហើយនៅពេលដែលសម្តេច សីហនុ ប្រកាសគឺថាគេមិននេះនោះទេ។ ដូច្នេះប្រសិនបើគិតថាជាការពង្រីកកម្ពុជាប្រជាធិបតេយ្យមិនមែននោះទេ ការពិតទៅព្រោះពួកគាត់បានផ្តាច់ខ្លួនចេញពីកម្ពុជាប្រជាធិបតេយ្យយូរណាស់មកហើយ។

[១៥:២៦:៥៨]

**ស៖** ឥឡូវនេះ ខ្ញុំឈានទៅដល់ប្រធានបទបន្តរបស់ខ្ញុំ។ នៅពេលដែលលោកស្រីនិយាយអំពីការងារបះបោរ ឬក៏ការបែកបាក់នៅក្នុងខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យនោះ គឺការបែកបាក់ទៅជាពីរបីក្រុម។ មួយក្រុមដឹកនាំដោយ ប៉ុល ពត, នួន ជា, អៀង សារី មួយក្រុមទៀតដឹកនាំដោយ សោ ភឹម, រស់ ញឹម និងអ្នកដទៃទៀត។ ថាតើនៅក្នុងឆ្នាំណាដែលមានការបែងបាក់គ្នានោះ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន សំណួរគឺហាក់ដូចជាការសន្មតទៅលើអង្គហេតុទាំងអស់ដែលសាក្សីមិនទាន់ផ្តល់ចម្លើយនៅឡើយ។ នេះគឺគ្រាន់តែជាការសន្មតដែលមេធាវីបានលើកឡើង ដែលទាំងអស់នេះគឺជាការខ្វែងគំនិតគ្នារវាង រស់ ញឹម, សោ ភឹម ជាដើម។ ដូច្នេះមេធាវីគួរតែសួរទៅលើសាក្សី ថាតើវាជាការពិតដែរឬទេ? គាត់មិនគួរចោទសំណួរដែលជាការសន្មតទៅលើអង្គហេតុដោយសារតែមិនទាន់មានផ្តល់សក្ខីកម្មពីសាក្សីនេះនៅឡើយ។

[១៥:២៨:១៧]

**ស៖** ខ្ញុំនឹងរីករាយ ប្រសិនបើចង់ឲ្យខ្ញុំសួរបែបនេះ។ លោកសាក្សី តើលោកស្រីអាចប្រាប់យើងខ្ញុំបានដែរឬទេ អំពីការបះបោរ ក៏ដូចជាការបែកបាក់របស់កម្ពុជាប្រជាធិបតេយ្យ? តើ សោភឹម, រស់ ញឹម ដូចដែលលោកស្រីបានបញ្ជាក់កន្លងមក គឺម្នាក់បានសម្លាប់ខ្លួន ហើយម្នាក់ត្រូវបានគេសម្លាប់។ តើលោកស្រីអាចបញ្ជាក់បន្ថែមអ្វីខ្លះបន្ថែមទៀត ដែលទាក់ទងទៅនឹងពួកគាត់ទាំងពីររូបនេះ?

**ឆ៖** ដូចដែលខ្ញុំបានរៀបរាប់នៅក្នុងសៀវភៅរបស់ខ្ញុំហើយ គឺមិនមែនជាការបែកបាក់នោះឡើយ គឺមកពីខាងលើ។ ហើយដូចដែលភស្តុតាងបានបង្ហាញនៅទួលស្លែងដូច្នេះដែរ។ គឺជាការវាយប្រហារទៅលើភូមិភាគដទៃទៀត គឺថាជាការវាយប្រហាររបស់មជ្ឈិមទៅលើភូមិភាគ។ ដូច្នេះខ្ញុំមិនចាត់ទុកថាជាការបែកបាក់គ្នានោះឡើយ។

**សៈ** ជាការពិតទៅ នេះគឺជាប្រធានបទដែលយើងត្រូវយកមកជជែកនៅក្នុងសវនាការនេះ។ ប្រសិនបើខ្ញុំប្រើប្រាស់ពាក្យលោកស្រី ហើយខ្ញុំប្រើពាក្យថា"បោសសម្អាត"នោះ ថាតើពាក្យ"បោសសម្អាត" ហ្នឹង បានន័យថាម្ខាងទៀតក្បត់ ឬមួយក៏យ៉ាងម៉េចដែរ? ហើយនៅពេលដែលលោកស្រីគិតអំពីការក្បត់ ដែលនាំទៅដល់ការបោសសម្អាត ថាតើវា -- ថាតើ សោ ភឹម និង រស់ ញឹម ហ្នឹងចាប់ផ្ដើមប្រឆាំងនៅពេលណា? គឺថាចាប់ផ្ដើមប្រឆាំងជាមួយគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅពេលណា?

[១៥:៣០:០៣]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន គឺថាមិនមានភស្តុតាងណាមួយដែលសាក្សីនេះបានបង្ហាញថា រស់ ញឹម ឬក៏ សោ ភឹម ប្រឆាំងជាមួយនឹងគោលនយោបាយនោះឡើយ។ ដូច្នេះយ៉ាងណាក៏ដោយ ខ្ញុំនៅតែទុកឱកាសឱ្យសាក្សីគាត់ឆ្លើយ។ អញ្ជើញចុះ!

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆៈ** ភស្តុតាងបានបង្ហាញថា មជ្ឈិមចាប់ផ្ដើមបោសសម្អាតភូមិភាគនៅឆ្នាំ៧៧។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** អ៊ីចឹងមានន័យថា ពេលណាដែលលោកស្រីគិតថា ពួកគេគិតថាការបោសសម្អាតនេះជាការចាំបាច់?

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆៈ** កំណត់ត្រាបានបង្ហាញថា គឺវាហាក់ដូចជាការគប់គ្នាទៅវិញទៅមក គឺថាយើងឃើញថា វាមានការផ្លាស់ប្ដូរ ក៏ដូចជាមានការប្រែប្រួលនៅក្នុងការឆ្លើយសារភាព ដែលថាខ្មាំងមិនចាំបាច់ថាត្រូវជា សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ ទេ។ ឥឡូវគេចាត់ទុកខ្មាំងគឺជាវៀតណាម។ នេះគឺជាអ្វីដែលកើតឡើងនៅក្នុងឆ្នាំ៧៧។ ខ្ញុំមិនចាំអំពីគោលនយោបាយសំខាន់ដែលបានកើតឡើងនោះឡើយ។ ប៉ុន្តែវាជាទំនោរទូទៅទាក់ទងទៅនឹងជនក្បត់។ នៅពេលដែលម្ខាងមានអំណាច ហើយធ្វើការកាប់សម្លាប់។ ដូច្នេះ ម្ខាងទៀតគឺត្រូវតែទទួលរងផលប៉ះពាល់។

[១៥:៣១:៥៩]

**សៈ** ខ្ញុំសូមបង្ហាញជូនលោកស្រី ឬក៏អានសម្រង់ចេញពីសៀវភៅមួយដែលជាភាពយន្តឯកសារដែលប្រើជាភស្តុតាងជាញឹកញាប់នៅក្នុងសវនាការដំបូង។ "នៅពីខាងក្រោយការកាប់សម្លាប់" ដែល

សរសេរដោយ ថេត សម្បត្តិ។ តើត្រឹមត្រូវទេ ដែលលោកស្រីលើកឡើងពីខាងដើម? លោកស្រីដឹងអំពីសៀវភៅនេះទេ ឬក៏ដឹងតែពីខ្សែភាពយន្តនោះទេ?

**ឆ៖** ខ្ញុំដឹងតែពីខ្សែភាពយន្តឯកសារទេ។

**ស៖** លោកប្រធាន ខ្ញុំសូមការអនុញ្ញាតដកស្រង់ចេញពីសៀវភៅមួយក្បាលនេះ។ ខ្ញុំអត់មើលលេខ E ហ្នឹងអត់ទាន់ឃើញនៅឡើយទេ គឺ E3152.2, អង់គ្លេស ERN គឺទំព័រ១០៦ ERN 002--, ខ្មែរ 00858341 ដល់ 42។ ខ្ញុំសូមផ្តល់ប្រវត្តិសាវតារខ្លះៗដែលថា ថេប សម្បត្តិ បានដកស្រង់នូវអ្វីដែលគាត់គិត។ បាទ គឺគាត់ៗបានជួបជាមួយនឹងកម្មាភិបាលជាន់ខ្ពស់នៅភូមិភាគពាយ័ព្យ ហើយមនុស្សនោះឈ្មោះ ចាន់ សារុធ ធ្លាប់ជាប្រធានមន្ទីរពេទ្យនៅបាត់ដំបង។ គាត់ៗដកស្រង់សម្តីរបស់ ថេប សម្បត្តិនោះដូចតទៅនេះ៖ “ចាន់ សារុធ ប្រធានមន្ទីរពេទ្យនៅតំបន់មួយនៅបាត់ដំបង បានឆ្លើយនៅក្នុងពេលសម្ភាសន៍ថា នៅក្នុងកិច្ចប្រជុំមួយដែលគាត់បានចូលរួមនៅស្តៅ មាន ប៉ុល ពត, រស់ ញឹម អ្នកណាៗម្នាក់ដែលរកឃើញថាជំទាស់នោះគឺត្រូវតែៗសម្លាប់។ ផែនការនេះគឺផែនការមួយដ៏ធំ និងសំខាន់ណាស់។ សារុធ គាត់និយាយថាអ៊ីចឹង។ យើងត្រូវជំរុញទឹកចិត្តដោយសារសមាជិកខ្លះដូចជា វន វ៉េត គឺថាបានគាំទ្រដល់ផែនការធ្វើប្រហារនេះ។ ហើយដោយមានការចូលរួមពី សោ ភឹម ពីភូមិភាគបូព៌ាផង”។

[១៥:៣៤:៤៤]

សេចក្តីថ្លែងនេះគឺជាសេចក្តីថ្លែងមួយរបស់កម្មាភិបាលថ្នាក់កណ្តាលមកពីបាត់ដំបងដែលត្រូវបានគាំទ្រដោយកម្មាភិបាលមួយទៀត ហើយដែល ថេត សម្បត្តិ យកមកសរសេរនៅក្នុងសៀវភៅរបស់គាត់។ ខ្ញុំសូមអាននៅក្នុងសៀវភៅហ្នឹងគឺ ERN អង់គ្លេស 00757531, ខ្មែរ00858339 ត្រង់ទំព័រ១០៤ “កម្មាភិបាលខ្មែរក្រហមមួយរូបនោះ គឺថាមានការធ្វើរដ្ឋប្រហារ ដើម្បីសម្លាប់ ប៉ុល ពត, នួន ជា។ នៅខេត្តពោធិ៍សាត់ក៏មានផែនការក្នុងឆ្នាំ១៩៧៦ ដើម្បីធ្វើរដ្ឋប្រហារដែលដឹកនាំដោយភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា។ អ្នកណាក៏ដឹងដែរថា មានផែនការធ្វើរដ្ឋប្រហារទម្លាក់ ប៉ុល ពត”។ នេះគឺឆ្នាំ១៩៧៦ តើលោកចំណុចនេះវាអាចនឹងកែប្រែដល់ចម្លើយលោកស្រីទើបនឹងឆ្លើយដែរ លោកស្រីយល់ថាម៉េចដែរ?

**ឆ៖** ខ្ញុំដឹង ថេត សម្បត្តិ ខ្ញុំដឹងពេលគាត់ធ្វើកិច្ចសម្ភាសន៍ហ្នឹង។ ខ្ញុំមិនគិតថា វាមានផែនការធ្វើរដ្ឋប្រហារចំណុចនេះបញ្ជាក់អះអាងនោះទេ។

[១៥:៣៦:១៥]

**ស៖** លោកស្រីអាចពន្យល់ឲ្យបានទូលំទូលាយបន្តិចបានទេ ហេតុអ្វីក៏លោកស្រីមិនចង់វាយ

ប្រហារទៅលើអ្នកនុ៎ង?

**ឆ៖** ដោយសារវាជាកិច្ចសម្ភាសន៍មួយដាច់តែឯងនេះ វាមិនមានឯកសារគាំទ្រដទៃទៀតណានេះទេ។

**ស៖** ខ្ញុំទើបតែដកស្រង់ និងសម្រង់សៀវភៅប្រភពពីរបីមួយទៀត ខ្ញុំមិនដឹងថា ដោយសារថាការពិតនោះភស្តុតាងនៅក្នុងសំណុំរឿង គឺដូច -- គឺដើម្បីឲ្យវាមានស៊ីសង្វាក់ទៅនឹងភស្តុតាងនេះ ដើម្បីបញ្ជាក់ថាមេដឹកនាំភូមិភាគនិរតី ភូមិភាគបូព៌ា, សោ ភឹម, ហើយនិងភូមិភាគពាយ័ព្យ គឺថាគេត្រូវគេតាមដានហើយនៅក្នុងឆ្នាំ១៩៧៥-៧៦ មានការទទួលអាវុធ ផ្តល់អាវុធអីជាដើម។ល។ ដូចកម្មាភិបាលរូបនេះបាននិយាយគឺថា ដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រតិកម្មរបស់ខ្ញុំហ្នឹង គឺខ្ញុំចង់សួរទៅលោកស្រី តើលោកស្រីមានប្រតិកម្មយ៉ាងដូចម្តេច ឬក៏មានចម្លើយយ៉ាងដូចម្តេចដែរ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:៣៧:៤៤]

**លោក នីកូឡាស គូមជែន៖**

នេះគឺជានាំឲ្យយល់ខុសទេ។ ភស្តុតាងចេញពីសំណុំរឿងហ្នឹង ខ្ញុំមិនដឹងថាមេធាវីការពារក្តីយោងទៅលើអ្វីជាក់លាក់ដែរ។ ខ្ញុំសូមស្នើថាការដកស្រង់សម្តី -- មិនគួរណាមេធាវីការពារក្តីសួរទៅអ្នកជំនាញ ឬក៏សាក្សី ដើម្បីឲ្យវាយតម្លៃទៅលើភស្តុតាងណាមួយនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ -- ដោយសារតែមានការជំទាស់រាប់លានដងឯណោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រី បេកឃ័រ ជាថ្មីម្តងទៀត គឺហេតុអ្វីបានជាលោកស្រីនិយាថាការយល់ឃើញរបស់ ថេត សម្បត្តិ ដែលសរសេរនៅក្នុងសៀវភៅរបស់គាត់ហ្នឹង យល់ខុសពីរូបគាត់អ៊ីចឹង ឬក៏ខុសពីអ្វីដែលបានបង្ហាញក្នុងខ្សែភាពយន្តនោះ?

[១៥:៣៩:៤២]

**លោកស្រី អេលីហ្សាបេត បេកយ័រ៖**

**ឆ៖** នេះ គឺជាមាគ៌ារបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មិនមែនជារឿងមនុស្សដែលគេបង្ខំឲ្យឆ្លើយសារភាពទេ។ អ្វីដែលបានមកពីទួលស្លែងមិនមែនជារឿងអ្វីដែលថ្មីនោះទេ។ បើលោកចំណាយពេលនៅទួលស្លែង គឺថាម្នាក់ៗគេចោទថាក្បត់យ៉ាងហ្នឹងអីចឹងឯង។

**ស៖** ខ្ញុំមិននិយាយថាជារឿងមួយដែលថ្មីទេ ក៏ប៉ុន្តែតាមដែលខ្ញុំយល់ គឺថាសៀវភៅនេះមិនមែនសៀវភៅមួយបានពីទួលស្លែងនោះទេ។ ខ្ញុំយល់អ្វីដែលលោកស្រីចង់និយាយ។ នៅពេលណាធ្វើការបកស្រាយចម្លើយសារភាពយើងត្រូវពិនិត្យពិច័យឲ្យបានហ្មត់ចត់នោះ។ ក៏ប៉ុន្តែនេះ គឺជាកម្មាភិបាលមួយដែលរស់រានមានជីវិត ហើយដែលនិយាយៗចំហតែម្តងជាមួយនឹង ថេត សម្បត្តិ។

**ឆ៖** ខ្ញុំសូមនិយាយឡើងវិញ--

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន គឺថាអត់មានសំណួរទេ។ មានតែការនិយាយ មេធាវីការពារក្តីអត់សំណួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ឃើញថា អ្នកជំនាញយល់ពីសំណួររបស់ខ្ញុំហើយ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយថាមាននីតិវិធីនៅក្នុងតុលាការនេះ។ ខ្ញុំធ្វើការជាង៣០ឆ្នាំ កាលណាសួរ ឆ្លើយ, បើមិនមានសំណួរ មិនមានចម្លើយ, មិនមានសំណួរច្បាស់លាស់ គឺមិនមានចម្លើយណាប្រកបទៅដោយផ្លែផ្កាបាននោះទេ។ ដូច្នេះ មេធាវីការពារក្តីត្រូវតែសួរជាសំណួរតែម្តងមកដល់អ្នកជំនាញ ឬក៏សាក្សី មិនត្រូវលើកយកជាសេចក្តីថ្លែងណាមួយសួរពីប្រតិកម្មនោះទេ។

[១៥:៤០:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន លោកជ្រាបហើយ នេះជាប្រធានបទសំខាន់ណាស់សម្រាប់ក្រុមមេធាវីការពារក្តីរបស់ នួន ជា ដើម្បីបង្ហាញឲ្យឃើញថា តើភាគីដែលមានវិវាទនឹងគ្នាហ្នឹង មានទំនាស់នឹងគ្នាយ៉ាងម៉េចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកជំនាញគឺថា គាត់មានលទ្ធភាពពេញលេញក្នុងការឆ្លើយតបទៅនឹងអ្វីដែលកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ បើសិនជាអ្នកជំនាញអាចឆ្លើយបានឆ្លើយ បើឆ្លើយមិនបានក៏ហើយទៅ។

**ប្រធានអង្គជំនុំ៖**

ទោះបីអ្នកជំនាញមានលទ្ធភាព និងសមត្ថភាពពេញលេញក៏ដោយ ក៏សំណួរនិងចម្លើយគប្បីប្រព្រឹត្តទៅតាមនីតិវិធីដែរ។ សុំលោករៀបចំនូវការរៀបចំនូវសំណួរឲ្យបានជាក់ច្បាស់ ដើម្បីឲ្យអ្នកជំនាញអាចឆ្លើយតបបានត្រឹមត្រូវ ដើម្បីជាប្រយោជន៍ក្នុងការជាវិភាគទានក្នុងការស្វែងរកការពិត។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

លោកស្រី បេកយ័រ ខ្ញុំសួរចំណុចផ្សេង។ សុំសួរទៅលោកស្រីទាក់ទងទៅនឹងការបះបោរដែលដឹកនាំដោយ រស់ ញឹម និង សោ ភឹម ដែលបានចាប់ផ្ដើមតាំងពីឆ្នាំ៧៥-៧៦ មកម៉្លេះ ដែលមានផែនការធ្វើរដ្ឋប្រហារ។ តើនេះត្រឹមត្រូវដែរទេ?

**ឆ៖** ខ្ញុំមិនមានឃើញភស្តុតាងបង្ហាញចំណុចនេះទេ។ ខ្ញុំយល់ថានេះជាការយល់ខុសហើយ។ ខ្ញុំថានេះគឺជាការបោសសម្អាតពីលើចុះក្រោមទេ។

**ស៖** ខ្ញុំសុំបន្តចូលប្រធានបទមួយផ្សេងទៀតគឺ ការសម្លាប់ ម៉ាល់ខូម ខាដវែល ជាបញ្ហាមួយដែលលោកស្រីអាចនឹងឆ្លើយបានច្រើន។ ដូចលោកស្រីបានឃើញ និងមានបទពិសោធន៍ជាច្រើនរួចមកហើយ។ ខ្ញុំសុំបង្ហាញលោកស្រីនូវឯកសារដូចគ្នាដែលខ្ញុំបានយកមកយោងពី រីឆាត ឌុដម៉ាន គឺជារបាយការណ៍តែមួយដោយយោងទៅលើទស្សនៈរបស់គាត់ នៅក្នុងយប់នុ៎ងនោះ នៅក្នុងយប់ដែលកើតព្រឹត្តការណ៍នេះឡើងនេះ។ ខ្ញុំសុំបង្ហាញលោកស្រីគឺ E3/3290, ERN 00419211។ ខ្ញុំសុំដកស្រង់ដូចតទៅនេះ "ម៉ាល់ខូម ខាដវែល គឺជាអ្នកជំនាញខាងផ្នែកសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ គាត់ត្រូវបានគេបាញ់សម្លាប់។ យើងទាំងបីនាក់គឺជាគោលដៅនៃពួកភេរវករ ដោយសារតែយើងធ្វើការបន្ទុះបង្អាប់មុខរដ្ឋាភិបាល"។ សំណួររបស់ខ្ញុំគឺសួរលោកស្រីថា តើលោកមានប្រតិកម្មយ៉ាងម៉េចចំពោះការកត់សម្គាល់ខ្លីរបស់ ឌុដម៉ាន នេះ?

[១៥:៤៤:១០]

**ឆ៖** ខ្ញុំអត់យល់ លោកចង់សួរថាម៉េចហ្នឹង?

**ស៖** នៅក្នុងសៀវភៅរបស់លោកស្រី លោកស្រីបានផ្ដល់ទ្រឹស្ដីមួយថាហេតុអ្វីបានជាការបាញ់សម្លាប់ ម៉ាល់ខូម ខាដវែល ហ្នឹងកើតមានឡើង? ដោយសារតែពេលវេលាហ្នឹង ខ្ញុំសុំដកស្រង់របាយការណ៍របស់ រីឆាត ឌុដម៉ាន ដែលគាត់ហាក់បីដូចជាចង់និយាយថាការសម្លាប់ហ្នឹងគឺធ្វើឡើងដោយសារតែពួកយើងគឺធ្វើការបង្អាប់បន្ទុះបំបាក់មុខរដ្ឋាភិបាល។ ហើយលោកស្រីសូមកែតម្រូវរបស់ខ្ញុំខុសដែល

ថាការបាញ់សម្លាប់នេះអាចធ្វើឡើងដោយកម្ពុជាប្រជាធិបតេយ្យតែម្តង ឬក៏ដោយអ្នកដែលប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ? តើលោកស្រីអាចបំភ្លឺជូនអង្គជំនុំជម្រះបានទេថាហេតុម៉េចក៏មានការកាប់សម្លាប់ហ្នឹងកើតឡើង បាញ់សម្លាប់ហ្នឹង?

**ឆ៖** តើចង់និយាយថា -- លោកចង់និយាយថាម៉េច?

**ស៖** គាត់មិននិយាយថាវៀតណាមឬក៏អីនោះទេ អត់មាននិយាយអ៊ីចឹង គ្រាន់តែថាវាអាចដោយរដ្ឋាភិបាលដោយសារតែពួកយើង គឺថាធ្វើឲ្យបាក់មុខមាត់រដ្ឋាភិបាល ឬវាអាចដោយសារការញុះញង់ហ្នឹងគឺកើតចេញពី ប៉ុល ពត ឬដោយយ៉ាងណានោះ?

**ឆ៖** ខ្ញុំអត់បានបញ្ជាក់ថាដូច្នេះទេ អ្វីដែលខ្ញុំលើកឡើងនោះគឺ ទី១ នៅទួលស្លែងហ្នឹងបង្ហាញយ៉ាងជាក់ច្បាស់ហើយ គឺថាមានមូលហេតុច្រើនណាស់ ដើម្បីកំណត់អំពីមូលហេតុផ្សេងៗ ដែលមានមូលហេតុដោយសារប្រជាជនកម្ពុជារាប់លាននាក់ស្លាប់ហ្នឹងគឺថា មានមូលហេតុផ្សេងៗគ្នា។ បញ្ហានុ៎ងគឺថាតើមូលហេតុអីបានជាដូច្នេះនៅក្នុងចិត្តរបស់ខ្ញុំគឺថា មានអ្នកនៅក្នុងកម្ពុជាប្រជាធិបតេយ្យមិនសប្បាយចិត្តទេ។ អៀង សារី ក៏គាត់បានថាព្យាយាម គឺលើកមុខលើកមាត់រដ្ឋាភិបាលនៅក្នុងឆាកអន្តរជាតិ។ ខ្ញុំមិនចង់ធ្វើខ្លួន -- ធ្វើពុតមិនដឹងទៅជាដឹងទេ។

[១៥:៤៦:៤៨]

**ស៖** តើវាអាចដែលគេថាអ្នកនៅពីខាងក្រោយខ្នងការបាញ់សម្លាប់នេះគឺកម្មាភិបាលខ្មែរក្រហមជាអ្នកធ្វើអំពើហ្នឹងឡើង វាអាចអ៊ីចឹងទេ?

**ឆ៖** ខ្ញុំសរសេរថា ថាភ្នាក់ងារវៀតណាមហ្នឹងគឺថាជ្រៀតចូលមកភ្នំពេញ។ វាមាន -- នឹងវាអាចមានន័យច្រើនគឺថាខ្ញុំសរសេរយ៉ាងនេះឯង ។

**ស៖** វាជាការស្មានៗទេ។ ក្នុងយោបល់ជាអ្នកជំនាញ តើលោកស្រីអាចនិយាយថា អាចមានលទ្ធភាពណាមួយថាការសម្លាប់ហ្នឹងគឺជាអំពើមួយដែលធ្វើឡើងដោយអ្នកដែលប្រឆាំងទៅនឹងបក្ស ឬក៏អ្នកដែលបាញ់សម្លាប់ហ្នឹង គឺថាធ្វើឡើងទៅតាមការបញ្ជារបស់វៀតណាម?

**ឆ៖** ខ្ញុំឆ្លើយសំណួរនេះហើយ ខ្ញុំគិតថាខ្ញុំបានឆ្លើយហើយៗ។

**ស៖** បាទ មិនអីទេ។ ខ្ញុំសូមបន្តចូលប្រធានបទមួយផ្សេងទៀត។ ការប្រើការឃោសនាដោយវៀតណាម ដែលកម្ពុជាប្រជាធិបតេយ្យបានប្រើប្រាស់យ៉ាងទូលំទូលាយ។ ខ្ញុំសូមចូលទៅសាមួយដែលដូក្លាស ស្ប៉ាយ *(Douglas Pike)*គាត់បានយកមកប្រើប្រាស់។

[១៥:៤៨:២៤]

លោកប្រធានគឺឯកសារ E323/2370, ERN អង់គ្លេស 00187389, ERN បារាំង 00344 740 មិនមាន ERN ជាភាសាខ្មែរទេ។ ដូក្លាស ស្ប៉ាយ គាត់សរសេរក្នុងរបាយការណ៍របស់គាត់អំពីការប្រើប្រាស់ការឃោសនាដោយវៀតណាម បន្ទាប់ពីការកាត់ផ្ដាច់ការទូតរវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៧។ ខ្ញុំសូមដកស្រង់សម្ដីគាត់ដូចតទៅ៖ "ភាគីទាំងពីរបានចោទប្រកាន់ថា មានការប្រព្រឹត្តអំពើសាហាវយង់ឃ្នង គេដុតផ្ទះសម្បែង ហើយគេបានយកថ្លើមប្រមាត់ វះយកថ្លើមប្រមាត់យកមកស៊ី ហើយគេសម្លាប់គ្រួសារទាំងមូល បំផ្លិចបំផ្លាញវត្ត ហើយគេបានឆក់លួចរបស់របរនៅក្នុងមន្ទីរពេទ្យ សាលារៀន"។ នេះគឺ ដូក្លាស ផាយ*(Douglas Pike)* គាត់បានសរសេរនៅក្នុងរបាយការណ៍របស់គាត់ ខ្ញុំដកស្រង់តទៅទៀត "ភាគីទាំងពីរ គឺធ្វើឲ្យមានភាពជូរចត់ទៅនឹងទស្សនៈរបស់អាមេរិក -- វៀតណាម គឺថាកាន់តែមានភាពពិសពុលជាងកម្ពុជា"។ ដូច្នេះ ចំណុចនេះហាក់បីជាគាត់លើកឡើងថា -- ចង់បង្ហាញថា វៀតណាមដើម្បីឲ្យបាក់មុខបាក់មាត់កម្ពុជាប្រជាធិបតេយ្យបានរៀបចំនូវការឃោសនាយ៉ាងធំធេងបំផ្លើសអំពីបញ្ហាការរំលោភសិទ្ធិមនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ពួកគេបំផ្លើសដោយផ្ដល់នូវឧទាហរណ៍មួយចំនួនដែលយើងខ្ញុំលើកឡើងនេះ"។ តើលោកស្រីមានប្រតិកម្មយ៉ាងម៉េចដែរចំពោះសម្ដីរបស់លោក ដូក្លាស ផាយ នេះ?

**ឆះ** ក្នុងនាមជាអ្នកកាសែត ខ្ញុំមិនៗមែនមិនយល់ស្របទេ។ វៀតណាមជំនាញ មានជំនាញយ៉ាងខ្លាំងក្នុងការឃោសនាក្នុងពេលសង្គ្រាមនោះ។ កុម្មុយនីស្តកម្ពុជាបានស្វាគមន៍អ្នកកាសែតកម្ពុជាប្រជាធិបតេយ្យសម្លាប់ចោលទាំងអស់ទៅវិញ។ កម្ពុជាប្រជាធិបតេយ្យគឺថា មានភាពអមិត្តយ៉ាងខ្លាំងជាមួយនឹងបរទេស។ កម្ពុជាប្រជាធិបតេយ្យគ្មានគ្នាញខ្លងណាស់កាលណាជួបជាមួយនឹងជនបរទេស។ គឺវៀតណាមយល់របៀបថាតើ គេត្រូវទាក់ទងជាមួយបរទេសម៉េច? អញ្ជើញបរទេសចូលមកយ៉ាងម៉េច? ឲ្យគេរាយការណ៍យ៉ាងម៉េច? អីយ៉ាងម៉េច? ជំនាញនេះឯងដែលគាត់និយាយ ហើយគាត់ថាវៀតណាមមានជំនាញច្រើន។

**សះ** ចុះយើងមានស្អីអានពីខាងកម្ពុជាប្រជាធិបតេយ្យ បើមិនមានអីឲ្យអានផងហ្នឹង? គាត់និយាយថាភាគីៗហ្នឹងគឺថា ធ្វើឲ្យមានភាពជូរចត់នៅផ្លូវឆាកអន្តរជាតិ។ ហើយវៀតណាមគឺមានភាពស្ទាត់ជំនាញជាង។ ដូច្នេះ ហាក់គាត់លើកឡើងថា ភាគីទាំងពីរចាប់ផ្ដល់ការឃោសនាដូចគ្នា។ ក៏ប៉ុន្តែវៀតណាមមានជំនាញប្រសប់ជាង តើលោកស្រីយល់យ៉ាងម៉េច?

[១៥:៥១:៥២]

**ឆ៖** យើងនិយាយអំពីការឃោសនា យើងអត់និយាយអំពីការទំនាក់ទំនងគ្នា។ យើងនិយាយអំពីជំនាញក្នុងការឃោសនា។ ដូចខ្ញុំនិយាយអ៊ីចឹង វៀតណាមមានជំនាញជាង។ ខ្ញុំអត់និយាយពីរឿងខ្លឹមសាររបស់ភាគីណាមួយទេ ខ្ញុំនិយាយអំពីភាពស្ទាត់ជំនាញក្នុងការឃោសនា។

**ស៖** ការឃោសនា បើយើងនិយាយទៅតាមនិយមន័យរបស់វា គឺយើងនិយាយពីខ្លឹមសារវាតើដូច្នេះចំណុចនេះវាហាក់ដូចជាវៀតណាមមានការងារហ្នឹង គឺថាជំនាញជាងក្នុងការបំផ្លើសបន្ថែមបន្ថយដើម្បីបង្អាប់បន្ទុះកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីយល់ស្របថាអ៊ីចឹងទេ?

**ឆ៖** ខ្ញុំគិតថាគាត់មិននិយាយថាអ៊ីចឹងទេ។ គឺថាកម្ពុជាប្រជាធិបតេយ្យ រឿងរ៉ាវទាំងអស់ហ្នឹងវាកើតមកពីជនភៀសខ្លួន នៅឯជំរំជនភៀសខ្លួននោះ ជនភៀសខ្លួនបានរៀបរាប់ចំណុចទាំងអស់នេះ។ ខ្ញុំឮដឹងគាត់និយាយអំពីចំណុចនេះ គាត់អត់បាននិយាយប្រៀបធៀបអំពីតុល្យភាពចំណុចនេះទេ។

**ស៖** លោកស្រីនិយាយថា នេះជារឿងរ៉ាវបានពីជនភៀសខ្លួន?

[១៥:៥៣:១៤]

**ឆ៖** ចាស ត្រឹមត្រូវហើយ។

**ស៖** ដូច្នេះខ្ញុំសូមត្រឡប់ចូលទៅសៀវភៅមួយដែលសរសេរថា “ភ្នែកម្ចាស់” ទំព័រទី១ គឺគាត់ធ្វើការវិភាគថាតើរឿងរ៉ាវរបស់ជនភៀសខ្លួននោះ គួរយកមកបកស្រាយដោយរបៀបណា? ហើយក៏ដូចជាសៀវភៅរបស់ វីកឃើរី ដែលគាត់បានសរសេរដែរ។ ខ្ញុំសូមដកស្រង់ចេញពីសៀវភៅរបស់គាត់ គឺទំព័រទី២ (ខ្ញុំនឹងផ្តល់ ERN នៅពេលក្រោយលោកប្រធាន)។ គាត់សរសេរដូចតទៅនេះ “គាត់និយាយដំបូងបំផុតគឺនិយាយអំពីការបំផ្លើស ការបំភ្លៃគឺនិយាយអំពីព្រឹត្តិប័ត្ររបស់អ្នកមិនចូល -- គឺថាព្រឹត្តិប័ត្រអព្យាក្រិតរបស់លោកខាងលិច។ ហើយជាពិសេសទាក់ទងទៅនឹងការលម្អៀងនៃសក្ខីកម្មរបស់ជនភៀសខ្លួន របាយការណ៍ទាំងពីរនេះ គឺដែលនិយាយអំពីប្រជាជនថ្នាក់កណ្តាលដែលបានបាត់បង់អាយុជីវិត បងប្អូនរបស់គេ។ ហេតុដូច្នេះបានគេមាននិន្នាការមួយស្អប់របបនេះណាស់។ ជនភៀសខ្លួនគឺថាមិនពេញចិត្តនឹងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ទោះបីជាវាមិនមានមូលហេតុសំអាងចំពោះការរត់គេចខ្លួនរបស់ខ្លួននេះក៏ដោយ។ ដោយការគាបសង្កត់ មន្ត្រីថៃនុះ ហើយភ្នាក់ងារបរទេស ដែលជនភៀសខ្លួនទាំងអស់ហ្នឹងគឺថាពឹងពាក់ទៅលើថៃ ហើយនិងភ្នាក់ងារបរទេស។ ដោយសារការនឹកដល់ផ្ទះសម្បែង គឺថាជនភៀសខ្លួនគេបានប្រាប់រឿងរ៉ាវ ដែលគេគិតថាការសម្ភាសនេះ គឺចង់ឲ្យគេឯងឮ ហើយ

ចំណុចនេះចង់ឲ្យគេធ្វើម៉េចឲ្យបញ្ជូនអ្នកទាំងអស់ហ្នឹងចេញពីចេញពីជំរំ។ ហើយជាពិសេសគឺគេនិយាយពីរឿងរ៉ាវគួរឲ្យរន្ធត់ចេញពីបទពិសោធន៍ផ្ទាល់ខ្លួន ហើយក៏ជារឿងមួយដែលប្រឆាំងទៅនឹងកុម្មុយនីស្តផងដែរ។ ជារឿងរ៉ាវ ដែលគេរាប់ឡើងវិញអំពីការសម្លាប់។ ជួនកាលការសម្ភាសហ្នឹងធ្វើឡើងដោយអ្នកដែលធ្វើឡើងមក ធ្វើដោយអ្នកមិនចេះសរសេរ មិនចេះអាន – ជនភៀសខ្លួនមិនចេះសរសេរ មិនចេះអាន"។ បញ្ចប់ការដកស្រង់។ លោកស្រី បេកឃ័រ លោកស្រីផ្តល់សក្ខីកម្មពីខាងដើមថា លោកស្រីបាននិយាយជាមួយជនភៀសខ្លួនដោយផ្ទាល់ដែរ។ តើលោកស្រីបានដឹងថាមានការពិភាក្សានៅក្នុងព្រឹត្តិប័ត្រ *អ៊ីកូណូមិក* ដែល រីកឃីរី ប៊ីហ្គ័រ បញ្ជាក់អះអាងដោយ ហ្វ្រង់ស័រ ប៉ុងសូដ៍ – សាក្សី ហ្វ្រង់ស័រ ប៉ុងសូដ៍ដែរ។ ហើយមានការបំផ្លើសច្រើនណាស់នៅក្នុងរឿងរ៉ាវដែលរៀបរាប់ដោយជនភៀសខ្លួននៅតាម នៅជំរំនៅតាមព្រំដែនកម្ពុជា-ថៃ។ លោកស្រីយល់ថាម៉េចដែរ?

[១៥:៥៦:៣៧]

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប។ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ដើម្បីតាមសំណួររបស់គាត់ដែលបាន តើសហភាគីនោះ អាចផ្តល់បរិបទបានទេ ហើយឲ្យនិយាយអំពីការងាររបស់ រីកឃីរី យើងអត់មានលេខកូដ លេខផង ហើយសក្ខីកម្មរបស់ ប៉ុងសូដ៍ នោះ យើងក៏អត់មានលេខឯកសារដែរ អ៊ីចឹងតើតាមគាត់យ៉ាងម៉េចទៅ? អ៊ីចឹងសូមឲ្យសហភាគីហ្នឹងពន្យល់ឲ្យបានច្បាស់លាស់ជាងហ្នឹង អំពីមូលដ្ឋានដែលគាត់ផ្អែកលើ ដើម្បីចោទសំណួរទៅលោកស្រីអ្នកជំនាញនេះ លោកប្រធាន។

**ស៖** ក្នុងករុណាក៏ដោយ ខ្ញុំមាន ERN ហើយលោកប្រធាន គឺ01002125។ ឯកសារ E307/5.2.17 គឺសៀវភៅរបស់លោក ហ្វ្រង់ស័រ ប៉ុងសូដ៍។ លោកស្រី បេកឃ័រ តើលោកស្រីមានប្រតិកម្មយ៉ាងម៉េចដែរចំពោះរឿងរ៉ាវដែលរៀបរាប់ដោយជនភៀសខ្លួននេះ?

[១៥:៥៧:៥៤]

**ឆ៖** ទី១ គឺថាលោកដកស្រង់ ខ្ញុំខុសហើយ។ ខ្ញុំនិយាយថាក្នុងកាលៈទេសៈពិសេសតែប៉ុណ្ណោះ ខ្ញុំអត់ដែលបាននិយាយទៅប្រទេសថៃ ទៅសម្ភាសហ្នឹងទេ។ ខ្ញុំសម្ភាសតែជនភៀសខ្លួនដែលគាត់បានទៅដល់សហរដ្ឋអាមេរិកហើយនោះ ខ្ញុំមិនដែលនិយាយថាខ្ញុំដែលបានទៅសម្ភាសនៅឯថៃនោះទេ។ គឺថា

យើងតែងតែសម្ភាសជនភៀសខ្លួនដោយចិត្តទុកដាក់បំផុត ប្រុងប្រយ័ត្នបំផុត ដូចខ្ញុំបានសរសេរនៅក្នុងសៀវភៅរបស់ខ្ញុំហើយ។ គឺមានករណីជាច្រើនដែលយើងត្រូវតែមានការប្រុងប្រយ័ត្ន។ យើងមិនមែននិយាយថាម្នាក់ៗត្រូវបានគេសម្លាប់នោះទេ។ លោកទី១ -- សូម -- ទី១ យើងសួរគេសិន។ មិនមែនថាំដល់ពាក់វ៉ែនតាបានគិតថាអ្នកហ្នឹងគឺជាបញ្ញវន្តនោះទេ មិនមែនអ៊ីចឹងទេ។ មិនមែនជាបញ្ហាដូចលោកថាអ៊ីចឹងទេ។ ការប្រុងប្រយ័ត្នគឺថាយើងគិតទៅដល់រឿងរ៉ាវរបស់គេ អាយុជីវិតរបស់គេ។ យើងម្នាក់ៗគឺថាធ្វើការសម្ភាសដោយប្រុងប្រយ័ត្នណាស់ ហើយសាស្ត្រាចារ្យរបស់ខ្ញុំ ក៏គាត់ប្រាប់មកអ៊ីចឹងដែរ។

[១៥:៥៩:១០]

**ស៖** សម្រង់ដែលដាក់បង្ហាញជូនហ្នឹង គឺខ្ញុំមិនចង់សួរថា លោកជនភៀសខ្លួនកុហកទេ ប៉ុន្តែលោកស្រីធ្វើការវាយតម្លៃបានត្រឹមត្រូវដែរទេទាក់ទងទៅនឹងសក្ខីកម្ម ឬក៏រឿងរ៉ាវរបស់ជនភៀសខ្លួននេះ? ដោយសារលោកស្រីមានរឿងរ៉ាវរបស់ជនភៀសខ្លួនយកមកសរសេរ ហើយមានសរសេរថា វៀតណាមបានប្រើប្រាស់ការឃោសនា ហើយមានការប្រព្រឹត្តនូវអំពើសម្លាប់រង្គាលអីជាដើម។ល។ ទាក់ទងទៅនឹងបញ្ហាទាំងពីរនេះ ទី១ ការបំផ្លើសអំពីការសម្លាប់រង្គាល, ទី២ ការគិតគូរអំពីការបកស្រាយរឿងរ៉ាវរបស់ជនភៀសខ្លួន។ សំណួររបស់ខ្ញុំ តើលោកស្រីយល់ស្របថា ដើម្បីឲ្យវាយតម្លៃឲ្យបានត្រឹមត្រូវថាតើមានការខិតខំប្រឹងប្រែង មានការបំផ្លើសចំពោះការកាប់សម្លាប់រង្គាលដែរឬក៏អត់នោះ? រឿងរ៉ាវរបស់ជនភៀសខ្លួនគឺមិនមានការពាក់ព័ន្ធដែលត្រូវយកមកពិចារណានៅក្នុងរឿងនេះទេ។ តើលោកស្រីយល់យ៉ាងម៉េច?

**ឆ៖** ខ្ញុំដូចជាវង្វេងហើយអ្វីដែលលោកសួរហ្នឹង។ ខ្ញុំៗមិនយល់លោកនិយាយពីរឿងរ៉ាវមួយណា?

**ស៖** ខ្ញុំសួរសំណួរទៅកាន់លោកស្រីថា សូមដក-- គឺលោក ផាយ ដែលគាត់បានថា វៀតណាមបានប្រើប្រាស់ការឃោសនា ហើយលោកស្រីក៏និយាយថាវៀតណាមមានជំនាញក្នុងការឃោសនាខ្លាំងជាង។ ហើយលោកស្រីបានឆ្លើយថា បើចង់ដឹងការពិត ដល់ទៅមើលខ្លឹមសារសិន ខ្លឹមសារទើបជាការពិត។ ហើយដើម្បីគាំទ្រដល់ចម្លើយរបស់លោកស្រី លោកស្រីបានយកចម្លើយជនភៀសខ្លួនយកមកប្រើប្រាស់។ តើលោកស្រីតែងសំអាងទៅលើរឿងរ៉ាវរបស់ជនភៀសខ្លួនដើម្បីបង្ហាញនូវការពិត ឬក៏អត់។ ដូច្នេះត្រលប់ទៅសំណួរខាងដើម ថាតើវៀតណាមបានបន្តុបរដ្ឋាភិបាលមួយដោយប្រើប្រាស់មធ្យោបាយឃោសនាថា មានការសម្លាប់រង្គាលដល់របបកម្ពុជាប្រជាធិបតេយ្យដែរឬក៏អត់?

[១៦:០១:៣៥]

**ឆៈ** ខ្ញុំនឹងបង្ហាញជូនលោក។ លោកដកស្រង់នឹងលោក ដូក្លាស ផាយ ដែលសរសេរពីរឿងវ៉ាវ ខែតុលា ៧៨។ នៅឆ្នាំ៧៨ មានរឿងវ៉ាវពីជនភៀសខ្លួនយ៉ាងច្រើននៅឯតាមព្រំដែនកម្ពុជា-ថៃ។ ហើយលោកមក និយាយមកទៀតថារឿងនេះ គឺវាពាក់ព័ន្ធទៅនឹងរឿងដែលវៀតណាមបានបន្តុបរដ្ឋាភិបាលមួយដើម្បីឲ្យធ្វើការឃោសនា។

**សៈ** ហើយលោកស្រីឆ្លើយថា "ចាស វាការឃោសនាប៉ុនប្រសប់នេះគឺថាត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលដែលបន្តុបឡើងដោយវៀតណាម"។

**ឆៈ** ជារឿងមួយគួរឲ្យវិលមុខ។ ពេលណាអ្នកកាសែតអនុញ្ញាតឲ្យវិលមកប្រទេសវៀតណាម គេបើកទ្វាចំហ។ គេអនុញ្ញាតជាលើកទី១ ដែលគេបើកចំហអ៊ីចឹង។ គឺថាការឃោសនានៅពេលហ្នឹង គឺការឃោសនាវាអាចជារឿងប្រឌិតឡើង ប៉ុន្តែខ្ញុំមិននិយាយពីរឿងហ្នឹងទេ។ មានទួលស្លែងនៅទីនេះ មានកំណត់ហេតុពីទួលស្លែងបង្ហាញ។

**សៈ** និយាយពីរឿងទួលស្លែងជារឿងមួយផ្សេងទេ? ខ្ញុំចង់និយាយពីរឿងថាគេសម្លាប់ប្រជាជនដែលពាក់វ៉ែនតា អ្នកពាក់វ៉ែនតាត្រូវគេសម្លាប់ចោលអ៊ីចឹង។ គឺរឿងវ៉ាវជនភៀសខ្លួនលើកតាំងពីអ៊ីចឹងឡើង។

**ឆៈ** បើសិនជាសំណួរ នៅពេលនោះយើងមានៗសៀវភៅ នៅក្នុងសៀវភៅរបស់ខ្ញុំឈ្មោះ ម៉ិ កុម្ភូត ហ្នឹងគឺនិយាយប្រាប់ខ្ញុំនៅឆ្នាំ៧៩ ខ្មែរក្រហមត្រូវបានដួលរំលំ។ យើងនិយាយអំពីបញ្ហាប្រទេសតែមួយដែលប្រជាជនអាចរស់នៅ អាចធ្វើដំណើរ គ្មានការឃោសនាអីទេពេលនោះ។ ខ្ញុំអរគុណណាស់ដែល កុម្ភូត ដែលគាត់រស់រានមានជីវិត ហើយគាត់អាចឆ្លើយមកជាមួយខ្ញុំបាននោះ។

[១៦:០៤:១០]

**សៈ** មិនជាបញ្ហាអ្វីទេ ខ្ញុំមានសំណួរចុងក្រោយតូចមួយ។ លោកប្រធាន បើសិនជាអនុញ្ញាតទាក់ទងទៅនឹងចម្លើយៗទៅនឹងសំណួររបស់ខាងសហព្រះរាជអាជ្ញា និយាយអំពីការសម្លាប់ជនជាតិចាម។ លោកស្រីសរសេររឿងនេះនៅក្នុងសៀវភៅរបស់លោកស្រី ខ្ញុំសូមរំឭកឡើងវិញ។ ខ្ញុំសូមអានជូនលោកស្រីនូវសារមួយនៅក្នុងសៀវភៅរបស់លោកស្រីតែម្តង ត្រង់ទំព័រ២៥៣ គឺឯកសារ E3/20, ERN 00237958, ខ្មែរ ERN 00232334 ហើយបារាំង 00438511។ កថាខណ្ឌទី១ សៀវភៅរបស់លោកស្រីត្រង់ទំព័រ២៥៣ លោកសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់លោកស្រី៖ "បញ្ហាមួយរបស់ចាម គឺនៅភូមិភាគបូព៌ា សោ ភឹម ជាមេដឹកនាំភូមិភាគមានកិត្តិយសកេរ្តិ៍ឈ្មោះនៅត្រង់ថា ធ្វើឲ្យកម្មាភិបាល

របស់គាត់មានវិន័យ ប៉ុន្តែគាត់គ្មានការសម្តែងការអាណិតអាសូរណាមួយចំពោះជនជាតិចាមទេ។ ដោយសារតែភូមិភាគបូព៌ាអនុវត្តតាមគោលនយោបាយរបស់បក្ស ដូច្នេះភូមិភាគក៏បានអនុវត្តការធ្វើទុក្ខបុកម្នេញខាងសាសនា ប្រឆាំងនឹងចាម"។ តើនេះជាយោបល់លោកស្រីឬដែលថា ការសម្លាប់ចាមគឺថាភាគច្រើន ឬក៏ជាទូទៅប្រព្រឹត្តឡើងដោយភូមិភាគបូព៌ា គឺដោយ សោ ភឹម? លោកស្រីនិយាយអំពីការសម្លាប់ជាក់ស្តែងណាមួយទៅលើជនជាតិចាមដែលប្រព្រឹត្តឡើងដោយកងទ័ពភូមិភាគបូព៌ា ឬក៏អត់ទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ។

**ប្រធានអង្គជំនុំ៖**

បាទ សវនាការថ្ងៃនេះ ដល់ត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធទី១១ ខែកុម្ភៈ ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយថ្ងៃពុធនេះ ថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ អេលីហ្សាបេត បេកយ័រ បន្តទៀត។ សូមភាគីជ្រាប និងសូមអញ្ជើញចូលរួមតាមពេលវេលាកំណត់។

ហើយអង្គជំនុំជម្រះលោកស្រី អេលីហ្សាបេត បេកយ័រ ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកស្រីក្នុងនាម ក្នុងឋានៈជាអ្នកជំនាញនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់ទីកន្លែងដែលលោកស្រីស្នាក់នៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី អេលីហ្សាបេត បេកយ័រ វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ ហើយនិងឲ្យសុំអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែក នៅ -- ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ចូលមករួមសវនាការនេះវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*